# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ


ឆ្នាំទី ៣៣ លេខ ៤ ខែមេសា

ព.ស. ២៥០៤ ; គ.ស. ១៩៦១

ភ្នំពេញ

# ពិធីបុណ្យបូជាសពព្រះតេជព្រះគុណ  អ៊ុក អ៊ុន  មេគណ

## ខេត្តតាកែវ

---

កាលពីថ្ងៃទី ២១ ខែមេសា ១៩៦១ សម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ បានស្តេចយាងជាព្រះរាជាធិបតីភាព ក្នុងពិធីបុណ្យបូជាសពព្រះតេជព្រះគុណមង្គលទិព្វលោករង្សី អ៊ុក-អ៊ុន (សុទ្ធបញ្ញោ) រាជាគណៈ អតីតមេគណខេត្តតាកែវ ដែលប្រារព្ធធ្វើនៅវត្តសីហារតនារាម ។

នៅឱកាសនោះ គេសង្កេតឃើញ ផ្នែកខាងឥស្សរសមណៈគឺ: សម្តេចព្រះសង្ឃនាយកគណៈមហានិកាយ និងព្រះសង្ឃជាច្រើនរយអង្គ ។

ផ្នែកខាងឥស្សរជនជាអាទិ៍គឺ : ឯ.ឧ. គួ-រុន សមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក, សហជីវិន ស៊ិន - ប៊ុយកោ រដ្ឋលេខាធិការក្រសួងធម្មការ, សហជីវិន កុល - ឈិន, សហជីវិន អ៊ុន - គាំ ចៅហ្វាយខេត្តតាកែវ និងឥស្សរជនឯទៀតជាច្រើនដែលយើងពុំអាចកប់នាមឲ្យសព្វគ្រប់, បាននិមន្ត-អញ្ជើញទៅរួបរួមក្នុងពិធីនេះដែរ ។

ក្រោយដែលសហជីវិន ខេស-លឹម អតីតតំណាងរាស្ត្រ ជាប្រធានគណៈកម្មការបុណ្យ បានថ្លែងនូវជីវប្រវត្តិនៃព្រះសព និងវិយោគកថារួចហើយ, សម្តេចព្រះបិតាឯករាជ្យជាតិទ្រង់បានថ្លែងនូវព្រះសង្កថា ឥតព្រាងទុកមួយយ៉ាងវែង ហើយពីរោះក្បោះក្បាយ ។ បន្ទាប់មកទ្រង់ប្រារព្ធពិធីខមាទោស ដោយបូជាភ្ញីផ្កានិងគ្រឿងក្រអូបចំពោះព្រះសព រួចទ្រង់ប្រទានភ្លើង ។

តទៅ . . .

IOTHEQUE
P.P.

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ


ផ្នែកសាសនា　　បញ្ជីរឿង　　ទំព័រ

- វិបារណកថា អំពីគោលសំខាន់នៃព្រះពុទ្ធសាសនា លោក ផល-ទិត្យ រៀបរៀង ៣៥៧
- ពុទ្ធជីវប្បវត្តិ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . . ៣៦៨
- ព្រះនិព្វាន ឬនិរ៉ាណ លោកកុម្ម៉ង់ដង់ រូបែរត៍ រៀបរៀង ក្រមការ ជុំ-មៅ ប្រែ ៣៨១
- ព្រះអភិធម្មបិដក គម្ពីរព្រះយមក លោក ប៊ូ-ប៊ូ រៀបរៀង . . . ៣៩២
- មធុរសវាហិណី (ត) សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែ ព្រះញ.ឈឹន ពិនិត្យ . . . ៤០១
- មហោសថជាតក(ត):លោកអ៊ុម-ភនចម្លងពីសាស្ត្រាស្លឹករឹតព្រះពុទ្ធវង្សកឹម-តួរពិនិត្យ . ៤០៦

ផ្នែកអក្សរសាស្ត្រ

- វប្បធម៌ខ្មែរ (តមក) លោក លី-ធាមតេង រៀបរៀង . . . ៤១២
- ពាក្យខ្មែរប្រែពីបរទេស ដោយគណៈកម្មការវប្បធម៌ . . . . . . . . ៤១៦
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ៤១៧
- រឿងសាមកុក (តមក) ឧកញ៉ា នូ-កន ប្រែ . . . . ៤១៨
- រឿងមនុស្សចិត្តប្រែប្រួល លោក ប៉ូ-ប៊ូ រៀបរៀង . . ៤២៩
- រឿងចៅកំដិលហៅចៅគ្រឹប លោក ម៉ាន់-អេង រៀបរៀង ៤៤០
- រឿងព្រេងប្រទេសម៉ិចហ្សិក អំពីផ្លែព្រៃនឹងផ្លែស្រុក ភិក្ខុ ម៉ែន-រៀម ប្រែ . . ៤៤៥
- រឿងខ្លួកតាក្រហមក (តាមឯកសារទំនៀមទម្លាប់ខ្មែរ) . . . . . . ៤៥២

ផ្នែកកំណត់ទីងប្រវត្តិការណ៍

- ពិធីទទួលសៀវភៅ នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ . . . . . ៤៦៥


មួយឆ្នាំ មាន ១២ សៀវភៅ ថ្លៃជាវ ២៣០ រ០០

33e Année — No 4 — Avril 1961

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom-Penh

## Sommaire

### Partie religieuse

Pages

— Editorial "Les principes du Bouddhisme" par *M. PHAL TIT* . 357

— La Vie du Buddha (suite) par Vèn. *PANG-KHAT* . . . . 368

— Le Nirvana par le Commandant *ROBERT* . . . . . . . . . 381

— Prah Abhidhammapitaka (Kampi preah Yamaka) par *M. BOU-PO* . . . . . 392

— Madhurasavahini (suite) par Samdech Preah Dhammalikhita *LOUIS-EM*, revu et corrigé par Vèn. *NHÉAN-CHHOEUN* . . . 401

— Mahosatha Jataka (suite) relevé du manuscrit sur feuilles de latanier par *M. IM-PHON*, revu et corrigé par Vèn. *KEM-TO* . . . . 406

### Partie littéraire

— La Culture Khmère (suite) par *M. LY-THEAM-TENG* . . 412

— Activités de la Commission Culturelle . . . . . . . . . . . . . . 416

— Dictionnaire Sanscrit-Khmèr (suite) par Vèn. *PANG-KHAT* . . 417

— Histoire de Sam-Kok (suite) traduite par Oknha *NOU-KAN* . . . . . . . 418

— Histoirê d'un homme au caractère changeant par *M.BOU PO* 429

— Chau kreb le pâresseux, par *M. MANN ENG* . . . . . 440

— Légende du mexique "Le loup et le chien" par Vén *MEN-RIEM* . 445

— Nak-tà kraham-kàr d'après les documents de la commission des mœurs et coutumes . . . . . 452

### Notes et chroniques

La remise des livres par l'Ambassade le Chine Populaire à l'Université Preah Sihanouk Reach . . . . 456

Prix d'abonnement annuel (comprenant 12 numéros): 23$\$$00

## ផ្នែកសាសនា

### វិចារណកថា

# អំពីគោលសំខាន់នៃពុទ្ធសាសនា

លោក ដល ធិត្យ នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

សព្វថ្ងៃនេះ ទ្រឹស្តីខាងវិទ្យាសាស្ត្រ ដែលមានសម្ភារនិយមជាទីតាំង បានឡើងដល់កំរិតអតិបរមានៃការវិវឌ្ឍន៍ ៗ ឯទ្រឹស្តីខាងចិត្តនិយម បើកំណត់តាមភាគប្រតិបត្តិក៏ឃើញថា មានដំណើរយឺតជាទីបំផុត ៗ

ដោយករណីនេះ ទើបខ្ញុំចង់មករួមសន្ទនាជាមួយនឹងលោកអ្នកអានទូទៅ ដើម្បីជាសេចក្តីរំឭកដាស់តឿនមនោសញ្ចេតនានៃពលរដ្ឋខ្មែរយើង ដែលធ្លាប់ផ្តាច់ចិត្តយ៉ាងធ្ងន់ទៅក្នុងពុទ្ធសាសនា មកយូរកាលហើយ ឲ្យបានរឹងរឹតតែយល់ច្បាស់ឡើងវិញថា ពុទ្ធសាសនា ជាទ្រឹស្តីចិត្តនិយម ដែលយើងពេញចិត្តកាន់ប្រតិបត្តិតាមជាតំណពីបុព្វបុរសរបស់យើងមកនេះ មានគោលបំណង ជាគាំច្បាស់លាស់ ហើយធាំងជាសាសនាអាចប្រកប ផលឧត្តមប្រយោជន៍ ដល់យើងដែលជាពុទ្ធជនពិតមែនៗ

បច្ចុប្បន្នកាលនេះ យើងបានដឹងច្បាស់ថា មានមតិរបស់ជនខ្លះក្នុងលោកសម័យនេះ ដែលមិនត្រឹមតែមិនជឿពុទ្ធសាសនាប៉ុណ្ណោះទេ

ថែមទាំងបញ្ចេញរូបភាពយ៉ាងច្បាស់លាស់ដោយវោហារមិនគប្បី ជាហេតុ នាំពុទ្ធជនឲ្យរាកចិត្ត បែរចេញចាកព្រះពុទ្ធសាសនាទៀតផង ។ គោលសំខាន់បំផុតក្នុងខបំបែកបំបាក់សាសនិកសាមគ្គីរៀងនេះ គេខំដើរស្រាវជ្រាវរើរកប្រកតសំខាន់ ៗ នៃកំហុសខ្វះ ក្នុងវណ្ណកម្មរបស់ពុទ្ធជនយើងពីសម័យបុរាណ ដែលជាការនិពន្ធហួសកាលៈទេសៈទៅហើយ មកជាគោលការប្រតិវត្តន៍ គឺគេចាប់យកកំហុសទាំងនោះលើកឡើងបង្ហាញយុវជនខ្មែរយើងគ្រប់ប្រភេទថា “ពុទ្ធសាសនា មិនមែនជាលទ្ធិពិតទេ គឺជាលទ្ធិប្រកបដោយការល្ងង់ខ្លៅនៃមនុស្សបុរាណ ឬក៏ជាការបោកប្រាសនៃពួកមូលធននិយម ” ទៅវិញ ។ គេយកជញ្ជាំងផ្សែងខ្មៅមកបាំងភ្នែកយុវជនយើង ដែលនៅខ្វះយការបេះដឹងផ្លូវពុទ្ធសាសនា ហើយហ៊ានសំដែងចេញទ្រឹស្តីមួយដែលឥតច្បាស់លាស់ក្នុងខ្លួនសោះថា “ មនុស្សស្លាប់ហើយ សូន្យ, គ្មានបរលោក, គ្មានសួគ៌និព្វាន គ្មានបុណ្យ-បាបណា សម្រាប់មនុស្សស្លាប់ទៅហើយនោះឡើយ ” ។ គេពន្យល់ដោយបញ្ជាក់យ៉ាងមាំទៀតថា “ សម័យនេះ ជាសម័យបរមាណូ ជាសម័យស្ពុតនិក គឺជាសម័យហួសការជឿរបស់ស្រពេចស្រពិលស្រមើស្រមៃដែលមិនដឹងជានៅឯណានោះទៀតហើយ , គេត្រូវជឿយកតែរបស់ប្រត្យក្សមែន ៗ ប៉ុណ្ណោះ ” ។ មិនត្រឹមតែប៉ុណ្ណោះ គេហ៊ានបដិសេធ សីល-

ទាន ភាវនា ដែលជាគោលធំមួយផ្នែក នៃការប្រតិបត្តិរបស់ពុទ្ធសាសនា ថា " ជារបស់គ្មានផលទៅលោកឯណាសោះ " ទៀតផង ។ ឯអ្នកនិពន្ធសម័យបុរាណ ដែលរៀបចំអត្ថបទតាមលំអានពុទ្ធសាសនានោះ ត្រូវគេចាត់ទុកថាជា " មនុស្សល្ងង់ មានប្រែះនៅក្នុងខ្លួន មិនចេះរិះគិតរកសេចក្ដីពិតតាមហេតុ-ផល ចេះតែជឿគេទាំងងងឹតងងល់" ។ តើលោកអ្នកអានយល់ថា គេនិយាយសមដែរឬទេ ?

បើតាមយោបល់ផ្ទាល់ខ្លួនរបស់ខ្ញុំ ដែលជាពុទ្ធសាសនិកជនមួយរូបវិញ អស់លោកអ្នកនឹងឃើញច្បាស់តាមដំណើរសេចក្ដីដែលខ្ញុំសរសេរទុកខាងមុខនេះ ប៉ុន្តែមុនដំបូង ខ្ញុំគ្រាន់តែសូមចិត្តជនទាំងនោះ ឲ្យរើគំនិតពិនិត្យជាថ្មី នូវគោលសំអាងនៃពុទ្ធសាសនាឲ្យច្បាស់លាស់សិន សឹមវិនិច្ឆ័យថា "ល្អ ឬអាក្រក់" ព្រោះពុទ្ធសាសនា ជាវិស័យរបស់អ្នកដែលចេះដឹង បរិបូណ៌ដោយទស្សនៈ នឹងមានឧត្ដមគតិពិរេ ។ តែប៉ុណ្ណោះ ហើយនៅឆ្ងាយណាស់ អំពីពួកមនុស្សដែលមិនយល់ព្រះសទ្ធម្មពោលគឺសេចក្ដីពិតក្នុងសាសនា ។

តទៅនេះ ជាការបើកបញ្ហាក់ទ្រឹស្ដី ដែលគេប្រកាន់យកសព្វថ្ងៃនេះ នឹងជាសេចក្ដីបញ្ជាក់ឲ្យឃើញកស្តុតាងនៃពុទ្ធសាសនា ដើម្បីយកមកប្រកួតគារកសេចក្ដីពិត តែនៅខាងដើម សូមលោកអ្នកអានពិនិត្យយ៉ាងម៉ត់

ចត់នូវទ្រឹស្តីចាស់បុរាណ ២ ប្រភេទ ដែលកើតឡើងប្រែនសតវត្សរ៍មុនពុទ្ធសាសនាមកហើយនោះឲ្យច្បាស់លាស់សិន ។ ទ្រឹស្តី ២ ប្រភេទនោះគឺ

១– ទ្រឹស្តីថា: មនុស្ស ឬសត្វ ស្លាប់ហើយពិតជាសូន្យគ្មានទៅកើតក្នុងពិភពលោកឯណាទៀតឡើយ (ឧច្ឆេទទិដ្ឋិ);

២– ទ្រឹស្តីថា: មនុស្ស ឬសត្វ ស្លាប់ហើយត្រូវទៅកើតទៀត ប៉ុន្តែកើតមកទៀង គឺធ្លាប់កើតជាអ្វី ក៏មកកើតជានោះដដែល ឥតប្រែក្លាយពីសភាពដើមឡើយ ដូចជាធ្លាប់កើតជាមនុស្ស លុះស្លាប់ទៅ ក៏មកកើតជាមនុស្សវិញដដែល មិនប្រែក្លាយមកកើតជាសត្វឡើយ, ឯសត្វក៏ដូចគ្នា គឺមិនប្រែក្លាយទៅកើតជាមនុស្សវិញបានឡើយ (សស្សតទិដ្ឋិ) ។

ទ្រឹស្តីទាំង ២ ប្រភេទនេះ បើសង្កេតឲ្យល្អិតទៅ ក៏អាចយល់បានថា វានៅរួមចូលក្នុងគោលគំនិតតែមួយថា ការធ្វើបាប-បុណ្យ, អាក្រក់-ល្អគ្រប់យ៉ាង ជាការឥតអំពើ គឺគ្មានផលទៅក្នុងពិភពលោកឯណាទៀតឡើយ, ប្រៀបដូចជាអ្នកណាមួយធ្វើខុសនឹងច្បាប់ដែលមានសម្រាប់គេជាដើម អ្នកនោះត្រូវតែលៃគិតយ៉ាងម៉េច ឲ្យតែគេខ្វះទេក្នុងបច្ចុប្បន្ននេះ គឺជាការស្រេច ។ ដំណើរដូច្នេះហើយ បានជាទ្រឹស្តីទាំង ២ នេះ មាន

ពួកវណ្ណៈខ្ពស់ និងពួកមូលធននិយមទូទាំងសកលលោក នាំគ្នាទទួលយកទៅធ្វើតាមប្រតិបត្តិ ហើយទាំងជួយជ្រោមជ្រែងយ៉ាងមាំមួន ទៅជាទ្រឹស្តីល្អបំផុតក្នុងពិភពលោកនេះទៀតផង ព្រោះថា ពួកវណ្ណៈខ្ពស់ បើអនុវត្តតាមទ្រឹស្តីនេះ ក៏ស្រួលងាយដល់ការរស់នៅក្នុងឋានៈដ៏ថ្លៃរបស់គេៗ

លុះពេលខាងក្រោយមកជាច្រើនសតវត្សរ៍ ព្រះពុទ្ធបរមគ្រូនៃយើង កាលទ្រង់នៅជាព្រះសិទ្ធត្ថមហាសត្វនៅឡើយ ទ្រង់ចេញពីចំណោមពួកវណ្ណៈខ្ពស់ ( មូលធននិយម ), ដែលជាអ្នកបរិបូណ៌ដោយគ្រឿងកាមគ្រប់បែប ( កាមសុខល្លិកានុយោគ ), ហើយទ្រង់ប្រឹងដើរស្វែងរកឧបាយបំបាត់សេចក្តីទុក្ខរបស់ពិភពលោក ( នេក្ខម្មៈ ), រហូតទ្រង់បានធ្វើទុក្ករកម្មគ្រប់បែបឥតចន្លោះ តាមរបៀបលទ្ធិចាស់ ដែលគេធ្លាប់ប្រព្រឹត្តមកយូរកាលហើយ ដើម្បីពិសោធរកសេចក្តីពិត ក្នុងលទ្ធិទ្រឹស្តីទាំងអស់នោះ ប៉ុន្តែលទ្ធផលក៏បានផ្ទុយពីសេចក្តីព្យាយាមទៅវិញ គឺបានត្រឹមតែការនឿយលំបាកកាយទៅទទេប៉ុណ្ណោះ (អត្តកិលមថានុយោគ) ឥតបានផលពិសេសណាមួយ ដើម្បីយកមកដោះស្រាយពិភពលោកនេះ ឲ្យរួចពីសេចក្តីទុក្ខលំបាកបានសោះឡើយ ។ លុះទីអវសាន ទ្រង់ក៏ត្រូវតែលះចោលទ្រឹស្តីទាំងនោះចេញ ដោយទស្សនវិជ្ជាយ៉ាងខ្ពស់បំផុត ហើយទ្រង់ប្រតិបត្តិតាមផ្លូវល្មម ( មជ្ឈិមាបដិបទា ) ដែលកើតជាក់ច្បាស់អំពី

ការពិសោធន៍យ៉ាងម៉ត់ចត់របស់ព្រះអង្គ ៗ លុះផ្លូវល្អ ( អដ្ឋង្គិកមគ្គ ) កើតឡើងយ៉ាងនេះហើយ លទ្ធផលយ៉ាងល្អបណ្ដាច់ គឺសព្វញ្ញុតញ្ញាណ ( ប្រាជ្ញាដែលដឹងច្បាស់ឥតក្ខាត់នូវហេតុ-ផលគ្រប់យ៉ាង ) ក៏កើតឡើងដោយពេញលក្ខណៈ ឥតខ្ចោះ ចំពោះព្រះអង្គគ្មានលំបាក ៗ ក្រោយពីពេលនេះមក ព្រះអង្គក៏បានប្រកាសជាឧឡារិកនូវទ្រឹស្ដី ( សាសនា ) ដែលទ្រង់បានត្រាស់ដឹងហើយនោះដល់ពិភពលោក ៗ ការប្រកាសទ្រឹស្ដីថ្មីនៃព្រះពុទ្ធបរមគ្រូជាម្ចាស់នេះ ក៏លេចចេញអានុភាពយ៉ាងអស្ចារ្យហាក់ដូចជារន្ទះទាំង ៧ មកបាញ់ខ្ទប់ ទ្រឹស្ដីទាំងពីរខាងលើនេះឲ្យតាំងគ្រឿងចក្រមិនឲ្យធ្វើវិវឌ្ឍន៍ទៅបាន ហើយទៅទីបំផុត ទ្រឹស្ដីទាំងពីរនេះក៏វិលថយក្រោយទៅរកកន្លែងលាក់ខ្លួនពួនអាត្មាទៅវិញ ៗ ឯលទ្ធផលនៃការប្រកាសទ្រឹស្ដីរបស់ព្រះបរមគ្រូក៏ឃើញថា តាំងតែពីសម័យនោះមក មនុស្សលោកមានការវិវឌ្ឍន៍យ៉ាងខ្លាំងក្នុងការបំបាត់ចោលនូវពួកមូលធននិយម នឹងការរំលាយវណ្ណៈខ្ពស់-ទាបឲ្យចូលគ្នាបានជាដើម ហើយទាំងបានសម្រេចបុទ្ធិ អំណាចផ្សេង ៗ ដែលគេចផុតពីការរំលោភសិទ្ធិរវាងគ្នា នឹងការនៅរួមរស់ជាមួយគ្នាជាសុខយ៉ាងប្រពៃ រហូតដល់បានរួចផុតចាកសេចក្ដីទុក្ខលំបាកក្នុងពិភពលោក ( និព្វាន ) ជាច្រើនទៀតផង ៗ នេះឯងជាដំណើរនឹងលទ្ធផលនៃការប្រកាសទ្រឹស្ដីរបស់ព្រះពុទ្ធបរមគ្រូនៃយើង ៗ

ដូច្នេះ យើងអាចយល់បានដោយងាយថា ទ្រឹស្តីដែលបដិសេធផលនៃបាប-បុណ្យនេះ មិនមែនជាទ្រឹស្តីថ្មីទេ គឺជាទ្រឹស្តីចាស់បុរាណជាងគេយូរណាស់មកហើយ, ជាទ្រឹស្តីធ្លាប់ធ្វើជាគ្រឿងចក្រឲ្យពួកវណ្ណៈខ្ពស់ជិះជាន់លើពួកវណ្ណៈទាប, ជាទ្រឹស្តីដែលព្រះពុទ្ធទ្រង់លុបចោលទៅហើយ តាំងជាទ្រឹស្តីមានប្រែះចាប់ដិតនឹងរលាយខ្លួនបាត់ទៅហើយផង ប៉ុន្តែជាក៏ហួស ទ្រឹស្តីចាស់នេះបែរជាមានមនុស្សលោកគាត់ខ្លះ លើកយកមកក្រៀវខ្សែខាត់លាបលនបន្ទំថាជារបស់ថ្មី មិនទាន់មានប្រែះចាប់ទៅវិញ ។ គ្រង់នេះ សូមលោកអ្នកអានកុំសន្មត់ថា ខ្ញុំជាអ្នកប្រមាថបៀតបៀនមើលងាយលទ្ធិ ទ្រឹស្តី សាសនាឯទៀតឡើយ គឺខ្ញុំគ្រាន់តែចាប់បើកបង្ហាញនូវការកែបន្ទំថា ជារបស់គ្មានប្រែះចាប់ នៃមនុស្សខ្លះក្នុងលោកនេះ ដែលស្មានដោយឥតខ្លាសថា គំនិតរបស់ខ្លួនជាគំនិតត្រូវប៉ុណ្ណោះ ។ ចំណែកការត្រូវនឹងខុសរបស់ទ្រឹស្តីតាំងនេះ សូមលោកអ្នកអានមករួមគិតវិនិច្ឆ័យជាមួយនឹងខ្ញុំតទៅទៀត ដើម្បីឲ្យឃើញសំអាងរឹតតែច្បាស់លាស់ឡើង ។

កាលបើនឹងវិនិច្ឆ័យរកសេចក្តីពិតក្នុងរឿងនេះ យើងគប្បីនឹកស្រាវជ្រាវដល់រឿងកើត (ជាតិ) នឹងរឿងស្លាប់ (មរណៈ) មកជាមួយផង ព្រោះវាមានដំណើរទាក់ទងគ្នា ។ កាលណាយើងដោះស្រាយបញ្ហាការកើត (ជាតិ) នឹងបញ្ហាការស្លាប់ (មរណៈ) រួចហើយ; ការសម្រេចថា

ទ្រឹស្តីណាជារបស់ពិត ណាជារបស់មិនពិត នឹងផ្តល់នូវវត្ថុតាងជាសំអាងដល់យើងបានភ្លាម ។

តាមពិត ធម្មជាតិគ្រប់យ៉ាង មានរុក្ខជាតិ និងតិណជាតិជាដើម ដំបូងកើតចេញមកពីមូលធាតុ (អវិជ្ជា) ដែលរួបរួមផ្សំផ្គុំគ្នា (សង្ខារ) ឡើង ។ លុះដុះចេញជារូបកងសណ្ឋានទ្រង់ទ្រាយទៅតាមសភាពរៀងខ្លួនហើយ វាក៏ប្រឹងបញ្ចេញល្បឿនលូតលាស់ឡើងទៅទៀតតាមលំដាប់ ដោយស្រូបយកធម្មជាតិដដែលនេះជាអាហារចិញ្ចឹមខ្លួន ។

សូមបញ្ជាក់ថា ដើម្បីងាយយល់ ខ្ញុំសូមលើកយកតែពួករុក្ខជាតិម្យ៉ាងប៉ុណ្ណោះមកជាឧទាហរណ៍ ។ គឺតាមធម្មតា ពួករុក្ខជាតិ វាគ្មានចេះដឹងឈឺចាប់ ក្តៅត្រជាក់ ឬនិយាយស្តីអ្វីទេ, វាមិនចេះកំរើកដោយខ្លួនឯង មិនចេះដេក-ដើរជាដើមគ្រប់យ៉ាង ព្រោះវាជាធម្មជាតិគ្មានចិត្ត-វិញ្ញាណតិចតួច ដើម្បីជាគ្រឿងដឹងស្គាល់ដំណើរពិតពលោកនេះសោះឡើយ ប៉ុន្តែបើទុកជារុក្ខជាតិទាំងនោះ គ្មានមនោ-ចិត្ត-វិញ្ញាណឲ្យមាំមួនក៏ដោយ បើពិនិត្យទៅក៏គង់ឃើញមានមនោធាតុយ៉ាងស្អួចស្តើងមួយ ដែលមិនទាន់យកជាការបាននៅជាប់ក្នុងវានោះដែរ គឺក្នុងខណៈដែលធម្មជាតិ ដី ទឹក ភ្លើង ខ្យល់ អាកាសរួមចូលលាយឡំនឹងគ្នាយូរទៅ ផលនៃសម្បយោគធម្មជាតិនេះ ក៏ក្លាយចេញជាធម្មជាតិម្យ៉ាងឡើងទៀត គឺដុះចេញជារុក-

ជាតិមួយដើមឡើង ហើយរុក្ខជាតិនេះ មិនមែនមានតែកង់ដើម-ស្លឹក-មែកធាង ប៉ុណ្ណោះទេ វាមានធម្មជាតិម្យ៉ាងដែលនៅជាប់នឹងវា សម្រាប់បង្កប់បញ្ញាប្រហែលគ្នានឹងមនោរបស់មនុស្សដែរ តែវានៅស្ងួចស្តើងណាស់មិនមែនពេញលក្ខណៈដូចជាមនោរបស់មនុស្សឡើយ ។ ហេតុនេះបានជារុក្ខជាតិទាំងនោះ ចេះដឹងបញ្ចេញឫសរេចាក់ទៅរកចំណីអាហារដីជាតិមកចិញ្ចឹមដើមវា ឬដូចជារុក្ខជាតិខ្លះមានដើមនោនជាដើមដែលចេះបញ្ចេញដៃ រេទៅចាប់តោងបង្អោងឡើងបាន ។ ដូច្នេះ យើងសូមសន្មតហៅធម្មជាតិនោះថា មនោធាតុនៃរុក្ខជាតិ ចុះ ដើម្បីឲ្យងាយដល់ការយល់ ប៉ុន្តែ សូមកុំប្រឡំថា មនោធាតុនេះ ដូចជាមនោធាតុនៃមនុស្សឡើយ ព្រោះមនោធាតុនៃរុក្ខជាតិនេះ ទន់ខ្សោយ ហើយស្ងួចស្តើងពេកណាស់ មានការៈត្រឹមតែចេះរេបន្តិចបន្តួចប៉ុណ្ណោះ មិនអាចចេះដឹងស្គាល់ដំណើរសុខ-ទុក្ខជាដើមនៃពិភពលោក ដូចមនោធាតុរបស់មនុស្សឡើយ ។ លុះដល់រយៈកាលរស់នៅនៃរុក្ខជាតិដែលដុះមកនេះអស់គំរិតគឺរុក្ខជាតិនោះវាចាស់ខ្លាំង ឬក៏មានអ្វីមួយបៀតបៀន ធ្វើឲ្យវាខ្សោយអស់កំឡាំង មិនអាចនឹងស្រូបជញ្ជក់យកធាតុចំណីអាហារមកចិញ្ចឹមខ្លួនបាន ហើយវាក៏ត្រូវងាប់ ។ ឯមនោធាតុដែលនៅក្នុងរុក្ខជាតិនោះ កាលបើលំនៅខ្លួនត្រូវងាប់ហើយ វាមិនរលាយសូន្យទៅអស់ទេ គឺវានៅមានហុយ

ហើយចេញអណ្ដែតទៅកាន់ទីផ្សេង ៗ ដែរ ។ កាលដែលមនោធាតុយ៉ាងដ៏ទន់ល្អិតនេះ ចេញផុតពីលំនៅដើមហើយ វាក៏ត្រូវអណ្ដែតទៅរកធាតុដែលមានកំឡាំងគួរដល់ការស្រូបឆក់យកទៅ, លុះវាចូលទៅធ្វើសម្បយោគថ្មីជាមួយនឹងអ៊ុំមួយថ្មីមានទីទឹកប្ដីជាដើមហើយ ដោយកំឡាំងជំនួយពីធាតុឯទៀតតាមវដ្ដផ្សេង វាក៏បានកកជារូបកងសណ្ឋានថ្មីមួយឡើងទៀត ។ រូបថ្មីនេះ ក៏មានមនោធាតុដែលហុយហើរមកធ្វើសម្បយោគនោះជាគ្រឿងបញ្ជាដែរ ប៉ុន្ដែមនោធាតុនេះ ក្លាយទៅជាមានកំឡាំងខ្លាំងជាងមុនបន្ដិច ព្រោះវាចាស់ពេលវេលាជាងមុនមកហើយ ។ លុះរូបថ្មីនេះ ផុតរយៈកាលរស់នៅទៀត មនោធាតុដែលអាស្រ័យនៅក្នុងរូបវានោះ ក៏ត្រូវហុយចេញទៅធ្វើសម្បយោគជាមួយនឹងអ៊ុំមួយទៀតតាមដំណើរដូចគ្នា ហើយលុះកជារូបឡើង មនោធាតុនោះ ក៏រឹតតែមានកំឡាំងជាងមុនឡើងជាលំដាប់ ។ បេះតែមានការផ្លាស់ប្ដូររូប នឹងធាតុបែបនេះជាច្រើនលើកទៅ, មនោធាតុនោះ ក៏រឹតតែមានការបេះដូងខ្លាំងឡើងបន្ដិចម្ដង ៗ តាមលំដាប់ជាហូរហែ រហូតបានមកកើតជាសត្វ ដូចជាដង្កូវទឹក, មូស, សុច, ចាប, ព្រាប, ឆ្មា, ឆ្កែ, គោ, ក្របី, សេះ, ដំរី នឹងស្វាជាដើម ដែលចេះចាប់ផ្ដើមស្គាល់ដំណឹងដំណើរសុខ - ទុក្ខ នឹងវិតក្កងពិភពលោកឡើងកាលវិនាទី ។ នៅទីបំផុត ទើបបានមកកើតជាមនុស្ស ព្រោះមនោ

ធាតុថ្មីនេះ វាចំរើនឡើងដល់កំរិតល្មមហៅថា មនោ, ចិត្ត, វិញ្ញាណ បានហើយ ។ ការរីកចំរើននៃមនោធាតុនេះ បើនិយាយឲ្យងាយយល់ទៅ យើងគប្បីប្រៀបធៀបនឹងទារកតូច ៗ ចុះ, ព្រោះថា ទារកតូច ៗ ដែលទើបប្រសូតចេញពីឧទរមាតាមកថ្មី ៗ, មនោ, ចិត្ត, វិញ្ញាណ របស់វានៅទន់ខ្ចីណាស់ ឥតមានដឹង-មានស្គាល់អ្វីក្នុងពិភពលោកក្រៅពីការចេះត្រឹមតែស្រែកឃ្លាន នឹងស្រែកយំប៉ុណ្ណោះឡើយ ប៉ុន្តែ លុះវាចំរើនធំឡើងៗ ជាលំដាប់, មនោ, ចិត្ត, វិញ្ញាណ របស់វាក៏រីកចំរើនការចេះដឹង ស្គាល់ដំណើរ ដំណឹង នឹងវត្ថុក្នុងពិភពលោកកាន់តែច្បាស់ឡើងជាហូរហែដែរ យ៉ាងណាមិញ, មនោធាតុដែលផុសឡើងថ្មីនោះ ក៏វាមានការរីកចំរើនអំពីការទន់ខ្ចីល្ងិតល្ងង់មកកាន់ការចេះដឹង តាមហេតុការណ៍ដែលវាជួបប្រទះ នឹងតាមកាលវេលា ដែលកន្លងទៅជាលំដាប់ដូច្នោះដែរ ។ ចុះបើមនោធាតុ មានកំឡាំងពេញលក្ខណៈតាំងពីដំបូងជាលំដាប់រហូតដល់មកកើតជាមនុស្សបានហើយ កើតទៅមុខវាមានដំណើរការយ៉ាងណាទៅវិញ ? សូមលោកអ្នកអានចាំពិនិត្យគោលសំខាន់ទៅទៀត ។

(នៅមានត)

# សត្តិកេនិទានព្រហ្មធ្វេសនកឋាទី ១០

១- ទ្រង់ខ្វល់ខ្វាយតិច ២- ព្រហ្មអារាធនា ៣- ទ្រង់រំពឹងមើលសត្វលោក ៤- ទ្រង់ព្រោះព្រះបឋមទេសនា ៥. ទ្រង់ជួបឧបកាជីវក ។

## ១- ទ្រង់ខ្វល់ខ្វាយតិច

*លំដាប់នោះ ព្រះគតរស្តេចចេញចាកសមាធិទៅក្រោមរាជាយតនព្រឹក្ស ហើយស្តេចយាងចូលទៅកាន់អជបាលនិគ្រោធម្តងទៀត ស្តេចទៅដល់ហើយ ទ្រង់រំពឹងដល់ធម៌ដែលព្រះអង្គបានត្រាស់ដឹង ហើយទ្រង់ជ្រាបថា សត្វទាំងឡាយមិនងាយយល់ធម៌ព្រះអង្គបានទេ សមដូចសេចក្តីដែលទ្រង់ត្រាស់ចំពោះពោធិរាជកុមារ ថា* (១)

"ម្នាលរាជកុមារ! តថាគតត្រិះរិះថា ធម៌ដែលតថាគតត្រាស់ដឹងហើយនេះ ជាធម៌ជ្រាលជ្រៅដែលសត្វឃើញបាន ដោយកម្រ ដែលសត្វត្រាស់ដឹងបាន ដោយកម្រ ជាធម៌ស្ងប់រម្ងាប់

---

១-ពោធិរាជកុមារសូត្រ ម.ម. សៀវ. ២៤ ទំព័រ ៣៩ (វិន័យបិដកមហាវគ្គបឋមភាគ សៀវ- ៦ ទំព័រ ១៤) ។

ថ្លៃថ្លា មិនជាទីត្រាប់ចុះនៃតក្កៈបាន ជាធម៌ល្អិត ជាធម៌ដែលអ្នកប្រាជ្ញគប្បីដឹងបាន ។ ពួកសត្វទាំងនោះសុទ្ធតែនៅកំពុងរីករាយក្នុងអាល័យ កំពុងស្រើបស្រាលចំពោះកាមនៅឡើយ។

មួយទៀត បដិច្ចសមុប្បាទធម៌ គឺធម៌ជាបច្ច័យនៃគ្នានឹងគ្នាណា បដិច្ចសមុប្បាទធម៌នោះ ជាហេតុឲ្យពពួកសត្វដែលនៅរីករាយ ក្នុងអាល័យ នៅត្រេកត្រអាល ក្នុងអាល័យ នៅស្រើបស្រាលក្នុងអាល័យឃើញបានដោយក្រក្រៃពេកណាស់។

មួយវិញទៀត ធម៌ណា សម្រាប់រម្ងាប់បង់នូវសង្ខារទាំងពួង សម្រាប់លះបង់បោលនូវឧបធិគឺកិលេសទាំងអស់ ជាទីអស់ទៅនៃតណ្ហា ជាទីនឿយណាយចាករាគៈ ជាទីរលត់ទៅនៃសេចក្តីទុក្ខគឺព្រះនិព្វាន ធម៌ទាំងអម្បាលនេះ ជាហេតុនាំឲ្យពួកសត្វឃើញបានដោយក្រក្រៃពេកណាស់ ។ បើទុកជា តថាគតសំដែងធម៌ទៅ ក៏គង់សត្វទាំងឡាយដទៃ មិនអាចនឹងត្រាស់ដឹងនូវធម៌របស់តថាគតបានឡើយ សេចក្តីលំបាកនឹងសេចក្តីនឿយព្រួយនោះ មុខជានឹងមានដល់តថាគតមិនខាន ។

ម្នាលរាជកុមារ! កាលនោះ គាថាទាំងឡាយមិនស្ងួវជា

អស្ចារ្យណាស់ណាទេ ដែលតថាគតមិនដែលបានឮក្នុងកាលមុន ក៏កើតប្រាកដ ដល់តថាគត ថា

កិច្ឆេន មេ អធិគតំ
ហលន្ទានិ បកាសិតុំ
រាគទោសបរេតេហិ
នាយំ ធម្មោ សុសម្ពុធោ
បដិសោតគាមី និបុណំ
គម្ភីរំ ទុទ្ទសំ អណុំ
រាគរត្តា ន ទក្ខន្តិ
តមោក្ខន្ធេន អាវុតា ។

“ណ្ហើយបុះឥឡូវនេះ តថាគតគួរសំដែងធម៌ដែលតថាគតបានត្រាស់ដឹងហើយ ដោយសេចក្ដីលំបាកនេះបុះ សត្វទាំងឡាយដែលរាគៈទោសៈគ្របសង្កត់ហើយ មិនងាយនឹងត្រាស់ដឹង នូវធម៌នេះបានទេ សត្វទាំងឡាយ ដែលកំពុងត្រេកអរដោយរាគៈ ដែលងងឹតគឺអវិជ្ជាកំពុងរួបរឹត មិនឃើញនូវធម៌ដែលនាំឲ្យពួកសត្វដល់នូវព្រះនិព្វាន ជាធម៌ដ៏ល្អិតសុខុមជ្រាលជ្រៅ ដែលសត្វឃើញបានដោយកម្រនោះបានទេ ។

ម្នាលរាជកុមារ! កាលដែលតថាគត ពិចារណាឃើញ ដោយន័យដែលត្រិះរិះដូច្នេះហើយ ចិត្តក៏ឱនទៅ ដើម្បីសេចក្ដីខ្វល់ខ្វាយតិច មិនឱនទៅ ដើម្បីសំដែងធម៌ឡើយ" ។

២- ព្រហ្មអារាធនា

*សហម្បតីព្រហ្ម បានយល់ពុទ្ធអាធ្យាស្រ័យដូច្នេះហើយត្រិះរិះឃើញថា បើព្រះលោកនាថ មានព្រះទ័យខ្វល់ខ្វាយតិច ពុំសំដែងធម៌ទេ លោកនេះមុខជាវិនាសហើយ ទើបមកប្រាកដខ្លួនចំពោះព្រះមានព្រះភាគ មានសំពត់ព័ទ្ធឆៀងស្មាម្ខាង លុតជង្គង់ស្ដាំលើផែនដី ប្រណម្យអញ្ជលីហើយក្រាបទូលអារាធនាថា សូមព្រះអង្គមេត្តាប្រោសសំដែងធម៌ ដូចសេចក្ដីដែលទ្រង់ត្រាស់ចំពោះរាជកុមារថា*(១)

បពិត្រព្រះអង្គដ៏ចំរើន! សូមព្រះមានព្រះភាគ សំដែងធម៌ សូមព្រះសុគតសំដែងធម៌ ដ្បិតសត្វទាំងឡាយ ដែលមានភ្នែកមានធូលីគឺរាគាទិក្កិលេសដ៏ស្រាលតិច តែបើខានស្ដាប់ធម៌មុខជានឹងសាបសូន្យមិនខាន សត្វទាំងឡាយដែលបំរុងនឹងត្រាស់ដឹងនូវធម៌ ក៏គង់មានដែរ ។

---

១ ពោធិរាជកុមារសូត្រ រាជវគ្គ ម.ម. សៀវ- ២៤ ទំព័រ ៣៩៣ (វិន័យបិដកមហាវគ្គ សៀវ- ៦ ទំព័រ ១៦) ។

ម្នាលរាជកុមារ! សហម្បតីព្រហ្ម បានពោលពាក្យនេះ លុះពោលពាក្យនេះរួចហើយ ក៏ពោលពាក្យដទៃតទៅទៀតថា

ပាតុរហោសិ មគធេសុ បុព្វេ
ធម្មោ អសុទ្ធោ សមលេហិ ចិន្តិតោ
អបាបុរេ តំ អមតស្ស ទ្វារំ
សុណន្តុ ធម្មំ វិមលេនានុពុទ្ធំ
សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ ។

ពីមុនរៀងមក ធម៌ដែលជនទាំងឡាយ អ្នកប្រកបដោយមន្ទិល តែងគិតថា ធម៌មិនបរិសុទ្ធទេ កើតប្រាកដហើយក្នុងដែនមគធៈ សូមព្រះអង្គបើកនូវទ្វារនៃព្រះនិព្វានចុះ សត្វទាំងឡាយប្រុងចាំស្តាប់ធម៌ ដែលព្រះអង្គជាអ្នកប្រាសចាកមន្ទិលទ្រង់ត្រាស់ដឹង ( តាមលំអានព្រះពុទ្ធអំពីបូរាណ ) ដូចបុរសអ្នកមានបក្ខុ ឈរលើកំពូលភ្នំថ្មសុទ្ធ ក្រឡេកមើលឃើញប្រជុំជនដោយជុំវិញយ៉ាងណាមិញ បពិត្រព្រះអង្គអ្នកមានបញ្ញាល្អ ព្រះអង្គមានសមន្តចក្ខុ មានសេចក្តីសោកទៅប្រាសហើយ សូមទ្រង់ឡើងកាន់ប្រាសាទគឺធម៌ ពិចារណាមើលប្រជុំជន

អ្នកប្រឡីដោយសេចក្ដីសោក ដែលជាតិជរាកំពុងគ្របសង្កត់ មានឧបមេយ្យដូច្នេះដែរ, បពិត្រព្រះអង្គអ្នកមានព្យាយាម អ្នកឈ្នះសង្គ្រាម អ្នកនាំពួកសត្វ អ្នកមិនជំពាក់បំណុលគឺកាមសូមព្រះអង្គក្រោក សូមត្រាច់ទៅក្នុងលោក សូមព្រះមានព្រះភាគសំដែងធម៌ សត្វទាំងឡាយដែលបម្រុងត្រាស់ដឹងធម៌ក៏មាន ។

ម្នាលរាជកុមារ! គ្រានោះឯងតថាគតដឹងច្បាស់នូវសេចក្ដីអារាធនារបស់សហម្បតីព្រហ្មផង អាស្រ័យនូវសេចក្ដីករុណាដល់ពួកសត្វផង ទើបរមិលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ។

## ៣- ទ្រង់រំពឹងមើលសត្វលោក

*ព្រះសម្ពុទ្ធបានទទួលអារាធនាព្រហ្មហើយ ទ្រង់ប្រមើលមើលសត្វលោក ដូចសេចក្ដីដែលទ្រង់ត្រាស់ចំពោះពោធិរាជកុមារ ថា*(១)

ម្នាលរាជកុមារ! កាលតថាគត ប្រមើលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ក៏បានឃើញសត្វទាំងឡាយ ដែលមានភ្នែកមានធូលីគឺរាគាទិក្កិលេសតិចខ្លះ ច្រើនខ្លះ មានឥន្ទ្រិយក្លាខ្លះទន់ខ្លះ មានអាការល្អខ្លះ អាក្រក់ខ្លះ ជាសត្វដែលគួរឲ្យត្រាស់

១- ពោធិរាជកុមារសូត្រ រាជវគ្គ ម.ម. សៀវ. ២៤ ទំព័រ ២៩៤ ។

ដឹងបានដោយងាយខ្លះ ដោយក្រខ្លះ ជាអ្នកឃើញទោសនឹងភ័យក្នុងបរលោកខ្លះ ប្រៀបដូចជាផ្កាជលជាតិខ្លះ ផ្កាព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី តែងកើតក្នុងទឹក ចំរើនក្នុងទឹក លូតលាស់ក្នុងទឹក ខ្លះលិចទៅក្នុងទឹកនៅឡើយ ខ្លះឋិតនៅត្រឹមស្មើនឹងទឹក ខ្លះដុះខ្ពស់ឡើងពីទឹក មិនជាប់ជំពាក់ដោយទឹកទេ ។

ម្នាលរាជកុមារ! គ្រានោះតថាគតសំដែងនូវបទគាថានឹងសហម្បតិព្រហ្មថា

អបារុតា តេ អមតស្ស ទ្វារា
យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ
វិហឹសសញ្ញី បគុណំ ន ភាសឹ
ធម្មំ បណីតំ មនុជេសុ ព្រហ្មេ ។

ទ្វារនៃព្រះនិព្វានទាំងនោះ គឺតថាគតបើកហើយ សត្វទាំងឡាយណា មានសោតប្រសាទ សត្វទាំងឡាយនោះ ចូរបញ្ចេញនូវសទ្ធាមកចុះ ម្នាលមហាព្រហ្ម! តថាគតសំគាល់ថាលំបាក បានជាមិនសំដែងធម៌ឧត្តម ដែលតថាគតស្ទាត់

ហើយក្នុងសំណាក់មនុស្សទាំងឡាយ ។

ម្នាលរាជកុមារ ! គ្រានោះឯង សហម្បតិព្រហ្ម គិតថា អាត្មាអញជាបុគ្គលដែលព្រះមានព្រះភាគទ្រង់យល់ព្រម ដើម្បីសំដែងធម៌ហើយ លុះគិតរួចហើយ ក៏ថ្វាយបង្គំលាតថាគត ធ្វើប្រទក្សិណហើយក៏អន្តរធានបាត់ពីទីនោះទៅ ។

## ៤- ទ្រង់ប្រារព្ធព្រះបឋមទេសនា

*កាលសហម្បតិព្រហ្មក្រាបបង្គំលាវិលទៅវិញបាត់ទៅ ទ្រង់ប្រមើលមើលសត្វដែលមានឧបនិស្ស័យគួរទ្រង់ប្រោសមុន ដូចសេចក្តីដែលទ្រង់ត្រាស់ចំពោះពោធិរាជកុមារថា*(១)

ម្នាលរាជកុមារ ! តថាគតត្រិះរិះថា តថាគតគួរសំដែងធម៌ដល់អ្នកណាមុនហ្ន៎ ! អ្នកណាអាចនឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន? ទ្រង់ពិចារណាតទៅទៀតថា អាឡារកាលាមគោត្រ ជាបណ្ឌិតជាអ្នកឆ្លៀវឆ្លាស់ជាអ្នកមានប្រាជ្ញា មានភ្នែកមានធូលីគឺរាគាទិក្កិលេសតិចយូរមកហើយ បើដូច្នេះគួរតថាគតសំដែងធម៌ ដល់អាឡារកាលាមគោត្រមុនបុះ តាបសនោះ

១ ពោធិរាជកុមារសូត្រ រាជវគ្គ ម.ម. សៀវ ២៤ ទំព័រ ៣៩៦ ។

អាចនឹងត្រាស់ដឹងធម៌ ឆាប់រហ័សបាន ។

ម្នាលរាជកុមារ ! គ្រានោះមានទេវតាចូលមកប្រាប់តថាគតថា បពិត្រព្រះអង្គដ៏ចំរើន អាឡារកាលាមគោត្រ ធ្វើកាលកិរិយាក្បែយទៅ ៧ ថ្ងៃ ហើយ ។ ឯញាណទស្សនៈក៏កើតឡើងដល់តថាគតថា អាឡារកាលាមគោត្រ ធ្វើកាលកិរិយាទៅ ៧ ថ្ងៃមែនហើយ ។ តថាគតត្រិះរិះយ៉ាងនេះថា ឱអាឡារកាលាមគោត្រ មានសេចក្ដីវិនាសធំណាស់ ប្រសិនបើបានស្ដាប់ធម៌នេះ នឹងគប្បីត្រាស់ដឹងធម៌បានមួយរំពេច ។

ម្នាលរាជកុមារ ! តថាគតត្រិះរិះថា បើដូច្នោះតើតថាគតគួរសំដែងធម៌ដល់អ្នកណាមុនហ្ន៎ អ្នកណាអាចនឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ! តថាគតត្រិះរិះទៅទៀតថា ឧទ្ទករាមបុត្រ ជាបណ្ឌិតមានបញ្ញាឆ្លៀវឆ្លាស ជាមេធាវីមានភ្នែកមានធូលីគឺរាគាទិក្កិលេសតិចមកយូរហើយ បើដូច្នោះគួរតថាគតសំដែងធម៌ដល់ឧទ្ទករាមបុត្រមុនប៉ុន្មាន គាត់នោះនឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ ម្នាលរាជកុមារ ! គ្រានោះមានទេវតាចូលមកប្រាប់តថាគតថា បពិត្រព្រះអង្គដ៏ចំរើន ឧទ្ទករាមបុត្រ ធ្វើកាល-

កិរិយាក្សយទៅពីពេលព្រលប់ទៅហើយ ។ ញាណទស្សនៈក៏កើតឡើងដល់តថាគតថា ឧទ្ទករាមបុត្រ ធ្វើកាលកិរិយាពីព្រលប់ទៅម្សែនហើយ តថាគតត្រិះរិះថា ឱ! ឧទ្ទករាមបុត្រវិនាសធំណាស់ ប្រសិនបើបានស្តាប់ធម៌នេះ នឹងគប្បីត្រាស់ដឹងនូវធម៌ដោយឆាប់រហ័ស ។

ម្នាលរាជកុមារ! តថាគតត្រិះរិះទៀតថា បញ្ចវគ្គិយតាបស មានឧបការច្រើនដល់តថាគត ព្រោះបានបំរើតថាគតដែលកំពុងបញ្ជូនចិត្តទៅកាន់ព្យាយាម បើដូច្នោះគួរតែតថាគតសំដែងធម៌ដល់បញ្ចវគ្គិយតាបសមុនចុះ ។ ម្នាលរាជកុមារ! តថាគតត្រិះរិះឃើញថា ឥឡូវនេះ បញ្ចវគ្គិយតាបសនេះ នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ដោយទិព្វចក្ខុស្អាតកន្លងលើសចក្ខុរបស់មនុស្ស ។ ម្នាលរាជកុមារ! កាលនោះ តថាគតនៅក្នុងឧរុវេលប្រទេស តាមសមគួរដល់អធ្យាស្រ័យ ទើបបានបរទៅកាន់ចារិក សំដៅទៅរកក្រុងពារាណសី ។

## ៥– ទ្រង់ជួបឧបកាជីវក

*កាលព្រះតថាគតធ្វើដំណើរចេញពីឧរុវេលប្រទេស ឆ្ពោះទៅកាន់ក្រុងពារាណសីតាមផ្លូវ ទ្រង់បានជួបសន្ទនាជាមួយឧបកាជីវកដូចសេចក្តីដែលទ្រង់ត្រាស់ចំពោះពោធិរាជកុមារ ថា(១)*

ម្នាលរាជកុមារ ! មានអាជីវកម្នាក់ឈ្មោះឧបកៈបានឃើញតថាគតទៅកាន់ផ្លូវឆ្ងាយ ក្នុងចន្លោះគយាប្រទេស នឹងពោធិ-ព្រឹក្ស លុះឃើញហើយ បានពោលពាក្យនេះចំពោះតថាគត ថា ម្នាលអាវុសោ ! លោកមានឥន្ទ្រិយគួរជ្រះថ្លាណាស់ឆវិ-វណ្ណរបស់លោកបរិសុទ្ធផូរផង់, ម្នាលអាវុសោ ! លោកបួសចំពោះគ្រូណា? អ្នកណាជាគ្រូរបស់លោក! លោកពេញចិត្តនឹងធម៌របស់គ្រូណា! កាលឧបកាជីវក សួរយ៉ាងនេះហើយ តថាគតឆ្លើយតបទៅវិញឧបកាជីវកជាបទគាថាយ៉ាងនេះ ថា

សព្វាភិភូ សព្វវិទូហមស្មិ
សព្វេសុ ធម្មេសុ អនូបលិត្តោ ។ល។
អន្ធភូតស្មឹ លោកស្មឹ
អាហញ្ញឹ អមតទុន្ទុភឹ ។

---

១ ពោធិរាជកុមារសូត្រ រាជវគ្គ ម ម រៀង ៤៤ ទំព័រ . . .

តថាគតជាអ្នកគ្របសង្កត់នូវតេភូមិកធម៌ទាំងអស់ ត្រាស់ដឹងនូវចតុភូមិកធម៌ទាំងអស់ បានលះបោលនូវតេភូមិកធម៌ទាំងអស់ហើយ មានចិត្តផុតស្រឡះហើយព្រោះអស់តណ្ហា ដឹងច្បាស់នូវចតុភូមិកធម៌ដោយខ្លួនឯង (ហាំបាច់) ចំពោះបុគ្គលណា? តថាគតមិនមានអាចារ្យទេ មិនមានបុគ្គលដទៃ ស្មើនឹងតថាគតឡើយ ក្នុងលោកនេះព្រមទាំងទេវលោក មិនមានបុគ្គលប្រៀបផ្ទឹមនឹងតថាគតបានឡើយ ព្រោះតថាគតជាអរហន្តក្នុងលោក ជាសាស្តាខ្ពស់ផុត មានតែតថាគតមួយ ជាសម្មាសម្ពុទ្ធ តថាគតមានសេចក្តីត្រជាក់ មានភ្លើងកិលេសរលត់អស់ហើយ ឥឡូវ តថាគតទៅកាន់បុរីនៃពួកជនអ្នកកាសី ដើម្បីសំដែងធម្មចក្រ តថាគតនឹងទូងស្គរគឺអមតនិព្វាន ដល់សត្វលោកដែលងងឹតគឺអវិជ្ជាកំពុងគ្របសង្កត់ ។

ឧបកាជីវកតបថា ម្នាលអាវុសោ! អ្នកប្តេជ្ញាខ្លួនយ៉ាងណា អ្នកគួរដើម្បីបាននូវឈ្មោះថា “អនន្តជិនៈ អ្នកឈ្នះអនេកអនន្ត” យ៉ាងនេះ ។ ព្រះតថាគត តបថា

---

មាទិសា វេ ជិនា ហោន្តិ

យេ បត្តា អាសវក្ខយំ
ជិនា មេ តាទិសា ហោន្តិ
តស្មាហំ ឧបក ជិនោ ។

ជនទាំងឡាយណា បានដល់នូវអាសវក្ស័យ ជនទាំងនោះឈ្មោះថាជិនៈព្រោកដូចតថាគតដែរ ។ តថាគតបានឈ្នះបាបធម៌ទាំងអស់ហើយ

ម្នាលឧបកៈ ព្រោះហេតុនោះ ទើបតថាគតឈ្មោះថា "ជិនៈអ្នកឈ្នះ"

ម្នាលរាជកុមារ! តថាគតពោលយ៉ាងនេះហើយ ឧបកាជីវកពោលថា ម្នាលអាវុសោ! យ៉ាងហ្នឹងហើយ ថាហើយក៏ងក់ក្បាលលៀនអណ្តាត កាន់យកផ្លូវមួយផ្សេងចៀសចេញទៅ ។

( នៅមានត )

## ព្រះនិព្វាន ឬ និវ៌ាណ

## លោក កុម្មង់ជិង់ រ៉ូបែរត៍ រៀបរៀង

ក្រុមការ ជុំ-មៅ ប្រែជាភាសាខ្មែរ

( តនឹងចប់ )

---

បទទី ១ ថា កាលនោះមានពុទ្ធបរិស័ទ ១ អង្គ ចូលនិព្វានហើយ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សំដែងថា រូបក្ខន្ធនោះក្លាយអស់ទៅហើយ វេទនាខន្ធក៏ស្ងិតស្រពោនអស់ សញ្ញាខន្ធក៏រលត់ សង្ខារក្ខន្ធក៏ឈប់សម្រាក វិញ្ញាណក្ខន្ធក៏ចូលអាស្រ័យក្នុងទីជ្រក ។

បទទី ២ ថា កាលនោះមានពុទ្ធបរិស័ទ ១ អង្គ នាមថាគោធិកភិក្ខុ ចូលនិព្វានដោយការធ្វើនូវអត្តឃាដ ហើយព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះបន្ទូលប្រាប់ពុទ្ធបរិស័ទទាំងឡាយថា តើវិញ្ញាណរបស់គោធិកៈនេះទៅចូលជ្រកក្នុងទីណា? ។ គោធិកៈចូលនិព្វានហើយ វិញ្ញាណរបស់គោធិកៈនេះឥតសល់ជ្រកនៅក្នុងទីណាឡើយ ។

ក្នុងនិទានទាំង ២ បទខាងលើនេះ ខ្ញុំសំគាល់ឃើញថា បទទី ១ ដែលសំដែងថា វិញ្ញាណចូលឈប់សម្រាកនោះ មិនមែនត្រូវយល់ថាជាគ្មានវិញ្ញាណឬថាសូន្យវិញ្ញាណឡើយ ហើយបទទី ២ ដែលសំដែងថា វិញ្ញាណឥតសល់ជ្រកនៅក្នុងទីត្រង់ណានោះ ត្រូវយល់ថាឥតសល់នៅក្នុងភពយើងវិញ ព្រោះនិព្វានជាភពដទៃ ។

សេចក្ដីទាំងនេះ នាំយើងឲ្យនឹកឃើញពាក្យប្ញាខាងក្រោយនេះទៀត គឺពាក្យដែលថា ព្រះនិព្វានោះជាអ្វី? មានសណ្ឋានដូចម្ដេច? ព្រះសម្មាសម្ពុទ្ធសំដែងទុកថា អ្វី ៗ ទាំងរស់សុទ្ធតែមិនទៀង ជាអនិច្ចំ ទាំងអស់ ប៉ុន្តែមិនទៀងតែក្នុងលោកនេះទេ តពីសេចក្ដីនេះមក យើងត្រូវពិចារណាខ្លួនយើងថា ចុះអ្វី ៗ ដែលមិនមែនជាក្នុងលោកនេះ តើជាធាតុទៀងឬទេ ជាធាតុមិនស្លាប់ឬទេ ជាអមតធាតុឬទេ មានទុកាន ១ សំដែងថា ភិក្ខុវេ ម្នាលភិក្ខុទាំងឡាយអើយ សេចក្ដីដែលមិនកើតឡើង មិនកឡើង មិនតាក់តែងឡើង មិនបដិសន្ធិឡើងនោះមានពិតហើយ ប្រសិនបើគ្មានធម៌ដែលមិនកើតនោះទេ ជាតិដែលកើតឡើងហើយ រកទីបំផុតគ្មានឡើយ ប៉ុន្តែបើមានធម៌ដែលមិនកើតដូច្នេះហើយ ក៏មានទីបំផុតដូចគ្នា ។

ក្នុងគម្ពីរទាំងប៉ុន្មាន យើងមិនឃើញមានត្រង់សេចក្ដីណាដែលសំដែងឲ្យច្បាស់លាស់ជាងនេះទៅទៀតឡើយ យើងយល់ឃើញថាគួរតែទុកដាក់សេចក្ដីទៀង ដែលមានសភាពផ្ទុយគ្នានឹងសេចក្ដីមិនទៀងក្នុងលោកនេះថាជាគូគ្នានឹងព្រះនិព្វានដែលមិនមែនជាក្នុងលោកនេះ និព្វានគឺជាសេចក្ដីទៀងមិនប្រែប្រួល ជាសេចក្ដីដែលមិនកើតទៀត ជាសេចក្ដីដែលមិនតាក់តែងឡើងដោយអំពើកាលជាតិមុន ៗ ។

មុននឹងវិនិច្ឆ័យសេចក្ដីថា ច្បាស់ឬមិនច្បាស់តាមស្ថានដូចដែលបាន

BIBLIOTHEQUE P.P. D'EXTREME ORIENT

ពោលមកនេះ យើងត្រូវពិចារណារកសេចក្តីនេះ ១ សិន គឺសេចក្តី ដែលថាៈ ចុះហេតុអ្វីបានជាព្រះសព្វញ្ញូមិនបានសំដែងឲ្យច្បាស់ ប្រាកដ អំពីធាតុទាំងរស់ ដែលប្រាសចាករូបមួយទៅកាន់រូបមួយ ?, អំពីធាតុណាដែលទៅកាន់ព្រះនិព្វាន ហើយព្រះនិព្វាននោះដូចម្តេចខ្លះ ? ។

ដែលសួរយ៉ាងនេះ មិនជាខុសឆ្គងទេ ប៉ុន្តែយើងបានដឹងថាមាន សេចក្តីខ្លះ ដែលឥតប្រយោជន៍ដល់ព្រះសម្មាសម្ពុទ្ធ ព្រោះថាសេចក្តីទាំង នោះជាការហួសនិស្ស័យរបស់មនុស្សគឺប្រាជ្ញាចាក់មិនដល់ លើកតែព្រះ អរិយបុគ្គល ដែលលោកបានដល់ថ្នាក់បំផុតនៃព្រះអរហត្ត កាលណា តែមានពុទ្ធបរិស័ទណា ១ ទូលសួរព្រះអង្គអំពីសេចក្តីណាដែលប៉ះពាល់ ដល់បរមត្ថកថា នោះព្រះអង្គមិនព្រមឆ្លើយតាមពាក្យសួរឡើយ, លុះពុទ្ធ-បរិស័ទ ១ អង្គនាមថា មាលុង្ក្យាបុត្ត បង្គំទូលសួរព្រះអង្គ ។ មាន ព្រះបន្ទូលថា " ចុះតថាគតបានអនុញ្ញាតឲ្យអ្នកវិះគិតអំពីលោក តើទៀង ឬមិនទៀង មានទីបំផុតឬគ្មានទីបំផុត ? តថាគតបានអនុញ្ញាតឲ្យអ្នកគិត ថា ជីវៈឬធម្មជាតិដែលរស់នៅនោះមានសណ្ឋានដូចជារូបឬមិនដូច ? ព្រះ អរហន្តរស់នៅក្រោយពេលដែលរំលាយបញ្ចក្ខន្ធទៅឬមិនរស់នៅ ? ឬជា រស់នៅផងមិនរស់នៅព្រមគ្នា " ? ។ មាលុង្ក្យាបុត្ត ទូលតបវិញថា " ព្រះអង្គមិនបានអនុញ្ញាត ឲ្យគិតអំពីសេចក្តីទាំងប៉ុន្មាននោះឡើយ " ។ អើ ! បានជាតថាគតមិនបានពន្យល់អ្នកអំពីផ្លូវទាំងនេះ ព្រោះវិជ្ជាទាំងនេះ

ឥតបានប្រយោជន៍អ្វីដល់ផ្លូវព្រះអរិយៈឡើយ ហើយមិនមែនជាសេចក្ដីសុខ មិនមែនជាសេចក្ដីត្រាស់ដឹងទេ; ដែលមានប្រយោជន៍ក្នុងផ្លូវទាំងប៉ុន្មាននេះ គឺធម៌ដែលតថាគតបានសំដែងហើយអំពី ទុក្ខសច្ចៈ គឺសេចក្ដីពិតអំពីទុក្ខ ឬកិរិយាឈឺចាប់; ឯសមុទយសច្ចៈ គឺសេចក្ដីពិតអំពីកិរិយាដែលរលត់ទុក្ខ ឬរលត់សេចក្ដីឈឺចាប់; មគ្គសច្ចៈ គឺសេចក្ដីពិតអំពីផ្លូវដែលនាំទៅកាន់ទីរលត់ទុក្ខ ឬរំលត់សេចក្ដីឈឺចាប់ ដោយហេតុនេះ មាលុង្ក្យបុត្ត អ្វីៗ ដែលតថាគតមិនបានសំដែងនោះ ត្រូវទុកឲ្យនៅដូចដែលចុះ (មជ្ឈិមនិកាយ) ។

អ្នកដែលប្រាថ្នានឹងរិះគិតអំពីផ្លូវទាំងអស់ ដែលព្រះសម្មាសម្ពុទ្ធមិនបានសំដែង ដោយព្រះអង្គយល់ឃើញថាឥតប្រយោជន៍នោះ ត្រូវពិចារណាដល់សេចក្ដីដែលព្រះអង្គបានឆ្លើយនឹង មាលុង្ក្យបុត្ត ខាងលើនេះ ។ ឯរឿងក៏ដែរ កាលដែលព្រះបរមគ្រូប្រថាប់នៅក្នុងព្រៃសំសាបានោះ ធ្វើឲ្យយើងយល់បានថា: ព្រះអង្គបានរិះគិតអំពីសេចក្ដីទាំងនោះឥតចន្លោះ, កាលនោះព្រះអង្គសំដែងប្រាប់ពួកភិក្ខុបរិស័ទទាំងឡាយថា ឯស្លឹកឈើសំសាបាដែលតថាគតកាន់ក្នុងព្រះហស្ដ មានចំនួនតិចជាងស្លឹកដែលជាប់នៅលើដើមមានប្រការយ៉ាងណា ធម៌ដែលតថាគតបានសំដែងប្រាប់អ្នកទាំងឡាយកាលគ្នា ក៏មានប្រការដូច្នោះដែរ គឺធម៌ដែលបានសំដែងនោះ តិចតួចស្ដួចស្ដើងណាស់ ធម៌ដែលតថាគតបានរកឃើញ

ច្រើនជាអនេកឥតគណនា ។

ក្នុងគម្ពីរមិលិន្ទបញ្ហា យើងបានឃើញសេចក្ដីដែលនិយាយតគ្នាពីបទដែលសំដែងខាងលើមករួចហើយ គឺព្រះបាទក្រុងមិលិន្ទសង្ស័យ អំពីរឿងដែលព្រះសម្មាសម្ពុទ្ធមិនព្រមឆ្លើយប្រាប់ដល់ មាលុង្ក្យបុត្ត ហើយព្រះនាគសេនឆ្លើយតបទៅវិញថា ចំណោទឬសេចក្ដីចោទសួរនោះមាន ៤ យ៉ាង គឺ:

១- ចំណោទ ដែលគេអាចនឹងឆ្លើយប្រាប់ដោយត្រង់ ហើយឲ្យជាក់ច្បាស់ ។

២- ចំណោទ ដែលគេនឹងពន្យល់បានលុះតែពិនិត្យមើលដោយល័ក្ខឋាន ។

៣-ចំណោទ ដែលគេនឹងពន្យល់បានលុះតែធៀបទៅនឹងចំណោទឯទៀតដូចគ្នា ដែលបានរកឃើញហើយ ។

៤- ចំណោទដែលត្រូវតែជៀសវាងចេញឲ្យឆ្ងាយ ដូចជាសេចក្ដីចោទសួរអំពីលោកថា ផុតឬមិនផុត រូបនឹងជីវិតមានសណ្ឋានដូចគ្នាឬមិនដូច ។ល។

គឺសេចក្ដីដែលទូលសួរអំពីព្រលឹងនៅមានឬមិនមាន នឹងគុណជាតិរបស់ព្រះនិព្វាននោះ ចូលទៅក្នុងចំណោទដែលព្រះសម្មាសម្ពុទ្ធមិនព្រមទទួលឆ្លើយឡើយ ។

មុននឹងពិចារណាទៅឆ្ងាយពីនេះទៅទៀត យើងត្រូវពិចារណាមើលសេចក្ដីដែលថាមិនចំ ដែលគ្មាននរណាថាឲ្យប្រាកដបានថា ជាអ្វី ៗ នោះសិន ។ មិនមែនមានតែក្នុងក្បួនក្បាលពុទ្ធសាសនាទេ, ទោះបីក្នុងវិទ្យាសាស្ត្រប្រទេសអឺរ៉ុប ក៏មានសណ្ឋានដូចគ្នាដែរ, វេលាណាប្រាព្ធដល់សេចក្ដីដែលនិយាយអំពីវិញ្ញាណ ឬចិត្តនោះ; វេលានោះ សេចក្ដីមិនច្បាស់ប្រាកដក៏កើតឡើងភ្លាម ហើយគេរកយកវិធីយ៉ាងចង្អៀត មិនមែនជាវិធីយ៉ាងឆ្ងាយយល់មកនិយាយវិញ ។ មិនដឹងជាដោយហេតុអ្វី បានជារូបទាំងឡាយដែលមកប៉ះពាល់ដល់ចក្ខុ ហើយទៅបានឯសញ្ញាឯណោះជាអ្នកកត់សំគាល់វិញ; អំពីប្រាជ្ញាស្មារតីនោះយើងមិនអាចដឹងឡើយ; ក្នុងសាសនាកាតូលិកគេមិនបានពន្យល់អំពីឋានសួគ៌ នឹងឋាននរកឲ្យច្បាស់លាស់ទេ ហើយអ្នកដែលមើលសេចក្ដីអធិប្បាយ អំពីឋានទាំងនោះ បានសេចក្ដីផ្សេងពីគ្នា តាមយោបល់តែរៀងខ្លួន ព្រោះសេចក្ដីដែលពន្យល់នោះ មានសភាពព្រលាំមិនពិស្ដារ ឲ្យជាការដាច់ខាតឡើយ ។

តាមយោបល់យល់ឃើញរបស់យើង ដែលខំប្រឹងទាញយកមកនិយាយនោះ គឺយើងគិតនិយាយយ៉ាងណាឲ្យតែស្រួលស្ដាប់ ។ មុនដំបូងបង្អស់ ព្រះពុទ្ធសាសនាជាសាសនាដែលមានធម៌អាថ៌ ឆ្ងាយនឹងសិក្សារៀនសូត្រណាស់ វិធីដំបូងមិនមែនជាផ្លូវបរមត្ថទាំងអស់ ដែលស្ងួញ

ស្មាញក្ងិចក្ងក់នោះឡើយ ជាវិន័យជាក្បួនខ្នាតដែលធ្វើខ្លួនឲ្យរួចអំពីទុក្ខ ដោយការប្រព្រឹត្តតាមសិក្ខាបទផ្សេង ៗ ដែលមានសេចក្ដីពិតប្រាកដនៅក្នុងនោះ; ទាំងនេះហើយជាសម្បត្តិដើមរបស់ព្រះពុទ្ធសាសនា លុះកាលជាខាងក្រោយមកជាច្រើនសតវត្សរ៍ សេចក្ដីឆ្គល់ សេចក្ដីសង្ស័យរបស់មនុស្សនាំឲ្យធម៌ទាំងនោះបង្អៀតទៅអស់ ប្រឡំលទ្ធិសាសនាចូលគ្នាទៅទៀត បោះបង់សម្បត្តិដើមដែលស្រណុករៀនស្រណុកគិត ទៅយកឯសេចក្ដីដែលលំបាករៀនលំបាកគិតវិញ ៗ ឧបមាដូចជាគេចង់ដឹងថា តើតាបសដែលប្រាថ្នានឹងធ្វើនូវអត្តឃាដ (ការសម្លាប់ខ្លួនឯង) នោះត្រូវប្រើខ្សែ-កាំបិត-អាវុធ អត់បាយឲ្យស្លាប់-ឬលោតទៅក្នុងជ្រោះភ្នំ? ៗ ត្រង់នេះមានបែបដូចជាក្នុងប្រទេសអឺរ៉ុប ក្នុងមជ្ឈិមកាលដែរ គឺគេជជែកពិគ្រោះគ្នាអំពីការដែលឥតប្រយោជន៍ឥតសមហេតុសមផលនេះ ៗ អំពីសាសនាកាតូលិក មានជជែកហួសអំពីសេចក្ដីបញ្ញត្តិ ដែលព្រះគ្រិស្តបានលាក់ទុកទៅទៀត ៗ

ដូច្នេះ ឃើញថានិព្វាននេះ យើងគ្មានអ្វីជាប្រាកដឡើយ ឯគម្ពីរដីកានានា ក្រៅពីគម្ពីរទាំងប៉ុន្មានដែលបានពោលមកហើយ ក៏សំដែងតែត្រឹមថា ព្រះនិព្វាននេះជាភាពសណ្ឋានក្រៅអំពីមនុស្សលោកយើងនេះ ៗ

មាននិទាន ១ សំដែងថា ព្រះនិព្វាននោះ គឺជាកន្លែងដែលគ្មានទឹក, ដី, ភ្លើង, ខ្យល់, មិនមែនជាអាកាសទទេ, មិនមែនជាវិញ្ញាណ

ទេ, មិនមែនជាគ្មានអ្វីសោះ, មិនមែនជាសញ្ញា, មិនមែនជាអសញ្ញា, មិនមែនជាលោកឯណេះ, មិនមែនជាលោកឯណោះ មិនមែនជាយប់ មិនមែនជាថ្ងៃ ។

បើដូច្នេះ គថាគតមិនហៅថាមក មិនហៅថាទៅ មិនហៅថានៅ មិនហៅថាស្លាប់ មិនហៅថាកើត; ហៅថាគ្មានមេ គ្មានពូជធារ គ្មានអស់ គឺជាទីបំផុតនៃទុក្ខ ជាទីបំផុតនៃសេចក្ដីឈឺចាប់, គឺមិនមានបដិសន្ធិថ្មីទៀត ។ល។

ព្រះនាគសេនបានពន្យល់ទៅក្រុងមិលិន្ទថា ព្រះនិព្វាននោះ មិនអាចនឹងបណ្ដាលឡើងដោយហេតុអ្វីមួយឡើយ ព្រោះថាព្រះនិព្វាននោះ មិនមែនជាប្រជុំនៃធាតុផ្សេង ៗ ដែលអាស្រ័យនូវគ្នានឹងគ្នា នាំឲ្យមានភាពសណ្ឋាន ជាទីសំគាល់បានឡើយ ។

ព្រះនិព្វាននោះ មិនមែននៅកន្លែងលោកយើងនេះទេ ដោយហេតុនេះបានជាយើងមិនអាចដឹងបានដោយឥន្ទ្រិយគនៈរបស់យើង ដែលជាសេក្ខបុគ្គលនោះ ។ គម្ពីរសំយុត្តនិកាយសំដែងថា មហាសមុទ្រនោះជ្រៅណាស់នឹងកាសមិនបាន នឹងស្ទង់ក៏មិនបានហ៊ានណា រីឯព្រះនិព្វាននោះ មនុស្សដែលនៅជាសេក្ខបុគ្គលនៅឡើយ នឹងដឹងស្គាល់ថាដូច្នេះដូច្នោះ មិនបានដូច្នោះឯង ។ ព្រះអរហន្តដែលលោកដល់ហើយនូវព្រះនិព្វាននោះ មានជម្រៅនឹងកាសមិនបាននឹងស្ទង់មិនបាន ដូចយ៉ាងមហាសមុទ្រ

ដូច្នោះដែរ ។

កាលណាព្រះអរហន្ត លោកចេញពីចំរើនឈានសមាបត្តិមកវិញនោះ លោកបន្ទឹន្ទូវវាចាតែងថា ព្រះនិព្វានទោះជាទីរលត់នូវសេចក្តីទុក្ខ ជាទីសុខជាទីប្រសើរ ។ ប៉ុន្តែនឹងអធិប្បាយស្រាយសេចក្តីសុខនោះឲ្យបានយល់ដល់មនុស្សឯទៀត អំពីសេចក្តីសុខដែលបានសោយក្នុងពេលចូលឈានទោះផងមិនកើត ព្រោះតែកាលណាចេញពីឈានមកវិញហើយ ព្រះអរហន្តលោកមានកាយ អវយវៈ អាយតនៈ ឥន្ទ្រិយ នឹងសំដីភាសាតាមធម្មតាដូនដែលជាសេក្ខបុគ្គលដូច្នោះ ។ ដោយហេតុនេះហើយ បានជាគ្មានពាក្យអ្វីនឹងពោលប្រាប់ឲ្យបំ អំពីសេចក្តីសុខក្នុងព្រះនិព្វាននោះ បើដូច្នេះតើត្រូវវិនិច្ឆ័យសេចក្តីថា ព្រះនិព្វាននោះគ្មាននៅសល់វិញ្ញាណអ្វីដែលមិនមែនជាវិញ្ញាណធម្មតាទេឬអ្វី ? ។

ប្រាជ្ញារបស់មនុស្សយើង ដែលនៅជាបុថុជ្ជននៅឡើយ មិនអាចនឹងយល់បានឡើយ អំពីធម្មជាតិអ្វីដែលសល់នៅរបស់ព្រះនិព្វាន ។ បើដូច្នេះយើងនឹងថាព្រះនិព្វាននោះគ្មាននៅសល់គុណធម៌អ្វីសោះ ក៏ថាមិនបាន មានអ្នកប្រាជ្ញជាតិអឺរ៉ុបម្នាក់ឈ្មោះ ម៉ាគក្ស-មុល្លែរ ដែលជាអ្នកប្រាជ្ញមួយរូបខាងលទ្ធិព្រះពុទ្ធសាសនា បានថាតែងទុកថា ព្រះនិព្វាននេះ យើងនឹងថាជាអ្វីមិនបាន យើងគ្រាន់តែដឹងថា មានព្រះនិព្វានប៉ុណ្ណោះ តែគ្មានអ្នកណាមួយអាចនឹងដឹងឲ្យប្រាកដថាដូច្នេះដូច្នោះបានឡើយ ។

មនុស្សខ្វាក់ព្រោះតែខ្លួនមើលមិនឃើញពណ៌ទៀត ឬលឿង នឹងថាមនុស្សដែលមានភ្នែកក្តីមើលមិនឃើញដូចខ្លួន ឬក៏គ្មានពណ៌យ៉ាងនេះយ៉ាងនោះក៏ថាមិនបាន ( សង្ស័យក្រៃ ) ។

ចំណែកខាងព្រះអរហន្តក្នុងសាសនាកាតូលិក ដែលបានធ្វើឈានដ៏ជ្រៅជ្រះ ហើយនៅវេលាដែលចេញពីឈានមកវិញ ក៏មិនអាចនឹងអធិប្បាយ អំពីសេចក្តីដែលប្រទះឃើញក្នុងវេលាដែលចូលឈាននោះប្រាប់យើងបានឡើយ ។

ដើម្បីនឹងបញ្ជាក់សេចក្តីនេះយើងត្រូវដឹងថា និព្វានលើដីដែលហៅថាឧបាទិសេសនិព្វានឬនិព្វានរបស់ព្រះអរហន្តនោះគឺជាអារម្មណ៍របស់លោកដែលប៉ះពាល់នូវអមតៈ គឺសេចក្តីពិតប្រាកដ សេចក្តីទៀងជានិច្ច ឥតកើត ឥតស្លាប់, នៅវេលាដែលលោកកំពុងធ្វើឈាន ព្រះអរហន្តលោកបានដល់វិះដៅ ស្ទើរតែនឹងផុតពីលោកយើងទៅហើយ ដោយអំណាចឧត្តមវិជ្ជាឬដោយប្រាជ្ញាញាណយ៉ាងខ្ពស់ដែលលោកបានដល់ នៅវេលាដែលលោកកាំងចូលឈានសមាបត្តិនោះ ។ ឈាននោះឯងនាំទៅប៉ះផ្ទាល់នឹងព្រះនិព្វាន ក្នុងវេលានោះលោកបាននូវញាណមួយយ៉ាងដែលអាចនឹងកត់សំគាល់ផ្ទាល់តែម្តងបាន មិនបាច់ត្រូវការដល់ខន្ធទាំងឡាយឡើយ ។

ចំណែកខាងនិព្វានឥតសល់ ដែលហៅថា អនុបាទិសេសនិព្វាន

ឬបរិនិញ្វាវិញនោះ គឺជាសេចក្ដីដែលទៀងជានិច្ច សេចក្ដីដែលពិតប្រាកដ សេចក្ដីដែលគ្មានបច្ច័យតាក់តែងតទៅទៀត ។ យើងមិនអាចនឹងយល់បានថា នៅវេលាក្រោយដែលបុគ្គលទំលាយខន្ធទៅ តើអ្វីដែលចេញពីខ្លួននោះទៅ ? ត្រង់នេះទៀតយើងក៏មិនបានដឹងជាយ៉ាងដូចម្ដេច ? ព្រោះប្រាជ្ញាបុថុជ្ជនមិនអាចនឹងឈ្វេងយល់បានឡើយ យើងត្រូវត្រឡប់សំទៅរកសេចក្ដីដែលនិយាយអំពីផ្នួរជាតិ ពីភពមួយទៅភពមួយវិញ ត្រង់នេះទំនងជាគ្រាន់តែផ្នួរបញ្ជូនផ្ដល់ប៉ុណ្ណោះ គឺថាជាកិរិយាដែលញ័ររញ្ជួយដែលក្រិតទុកហើយអំពីជាតិមុនប៉ុណ្ណោះ ឥតមានធាតុអ្វីរបស់មនុស្សទៅជារណបក្នុងកិរិយាដែលផ្នួរជាតិនោះឡើយ ។

សេចក្ដីយល់ឃើញនេះ ហាក់ដូចជាប្រកបនឹងគោលចារិករបស់ក្បួនវិជ្ជាក្នុងសម័យថ្មី ដែលអធិប្បាយអំពីកិរិយាដកបន្ទយនៃចិត្តដែលរឹងត្អឹងចេញ ។ ៚

# ព្រះអភិធម្មបិដក

## គម្ពីរព្រះយមក

លោកប៊ូ - ប៊ូ ប្រែរៀបរៀង

នមត្ថុ សុគតស្ស

សត្ថុបវរោ ទេវានំ ទេវទេវោ សុកលយោ
កថាវត្ថុប្បករណំ ទេសយិត្វា រណញ្ជហោ
យមស្ស វិសយាតីតោ នានាយមកប្បដិមណ្ឌិតំ
អភិធម្មំ បករណំ យមកំ នាម ទេសយិ ។

គាថានេះ នឹងបានវិសជ្ជនាក្នុងគម្ពីរព្រះយមកៈជាគំរប់ប្រាំមួយតទៅ ដំណើរសេចក្តីតាមព្រះបាលីថា ទេវទេវោ សម្តេចព្រះមានព្រះភាគ ជាវិសុទ្ធិទេវតា ដ៏ប្រសើរជាងទេវតាទាំងបីពួក គឺព្រះអរហន្តទាំងឡាយ ជាវិសុទ្ធិទេវតា ១ ពួក ទេវតាទាំងឡាយដែលកើតជាឧបបាតិកកំណើត ១ ពួក ព្រះមហាក្សត្រទាំងឡាយ ដែលទ្រង់សោយរាជសម្បត្តិ លើផ្ទៃផែនដីជាសម្មតិទេវតា ១ ពួក ។ រណញ្ជហោ សម្តេចព្រះមានព្រះភាគ កាប់ចំបុកនូវគន្លងនៃកិលេសកាម ដ៏ជាប់ជំពាក់នៅក្នុងខន្ធសន្តាន យមស្ស វិសយាតីតោ ព្រះអង្គកន្លងបង់នូវវិស័យនៃមច្ចុរាជ លោកនាថោ ទ្រង់ព្រះនាមថាលោកនាថ ព្រោះហេតុជាទីពឹងរបស់សព្វសត្វ កថាវត្ថុប្បករណំ ទេសយិត្វា កាលព្រះអង្គត្រាស់

សំដែងព្រះសទ្ធម្មវិសេសទេសនា នូវគម្ពីរព្រះកថាវត្ថុបករណ៍ចប់ចុះហើយ លំដាប់ពីនោះ ទើបទ្រង់ទេសនានូវគម្ពីរព្រះយមកបករណ៍តទៅទៀត ព្រះអង្គសំដែងគន្ថសុភល័យពិតពៃសម្តេចអមរិន្ទទេវរាជ ករ ផ្ទះបរ ដេរ ព្រះបរមលោកនាថត្រាស់ទេសនាដោយសង្ខេប ប្រដាប់ដោយយមកមានប្រការផ្សេង ៗ រាប់ចូលក្នុងព្រះអភិធម្មបិដក ៗ

មានពាក្យបុច្ឆាថា កោ ចេត្ថ យមកំ គម្ពីរនេះឈ្មោះថា យមកដោយអត្ថមានប្រការដូចម្តេច ?

មានពាក្យវិសជ្ជនាថា យមកា ចេត្ថ គម្ពីរនេះបានជាឈ្មោះ ថាយមកព្រោះអត្ថថា សម្តេចព្រះមានព្រះភាគត្រាស់ទេសនាជាគូ ៗ នឹង គ្នា គឺបុច្ឆាក៏ជាគូ វិសជ្ជនាក៏ជាគូ ហេតុនោះ បានជាគម្ពីរនេះឈ្មោះថា យមកប្រៀបដូចដើមរាំងទាំងគូ ហៅថាយមកសាលា នឹងប្រៀបដូចយម-កបាដិហារ្យ ដែលសម្តេចព្រះបរមសាស្តាធ្វើក្រោមដើមស្វាយនៃនាយ ឧយ្យានបាលឈ្មោះគណ្ឌាមព្រឹក្ស ព្រះអង្គធ្វើបាដិហារ្យបណ្តាលឲ្យទឹក នឹងទអគ្គីកើតឡើងជាគូ ៗ គ្នា ឯយមកបាដិហារ្យនោះមានឧបមាដូចម្តេច គម្ពីរព្រះយមកនេះទ្រង់ត្រាស់ទេសនាជាគូ ៗ នឹងគ្នា មានឧបមេយ្យដូច្នោះ ដែរ ៗ អាស្រ័យហេតុព្រះពុទ្ធអង្គទ្រង់ត្រាស់ទេសនាជាគូ ៗ នឹងគ្នាយ៉ាង នេះ បានជាគម្ពីរនេះឈ្មោះថាយមក; ឧសវិធេន វិភត្តំ គម្ពីរព្រះ យមកនេះ សម្តេចព្រះមានព្រះភាគត្រាស់ទេសនា ចែកចេញទៅដោយ

អំណាចនៃយមក ១០ ប្រការគឺ:

| | |
|---|---|
| ១-មូលយមក | ៦-សង្ខារយមក |
| ២-ខន្ធយមក | ៧ អនុសយយមក |
| ៣-អាយតនយមក | ៨-ចិត្តយមក |
| ៤-ធាតុយមក | ៩ ធម្មយមក |
| ៥ សច្ចយមក | ១០-ឥន្ទ្រិយយមក (១) ។ |

មូលយមក ព្រះពុទ្ធអង្គទេសនាជាគូគ្នានៅខាងដើមយមកទាំង៩ ។ ខន្ធយមក ព្រះពុទ្ធអង្គទេសនាដោយខន្ធទាំងប្រាំជាគូគ្នា ។ អាយតនយមក ព្រះពុទ្ធអង្គទេសនាដោយអាយតន ១២ ជាគូ ៗ គ្នា ។ ធាតុយមក ព្រះពុទ្ធអង្គទេសនាដោយធាតុ ១៨ ជាគូ ៗ គ្នា ។ សច្ចយមក ព្រះពុទ្ធអង្គទេសនា ដោយព្រះចតុរារិយសច្ចជាគូ ៗ គ្នា ។ សង្ខារយមក ព្រះពុទ្ធអង្គទេសនាដោយសង្ខារទាំង ៣ គឺ: កាយសង្ខារ ១, វចីសង្ខារ ១, មនោសង្ខារ ១ ជាគូ ៗ គ្នា ។ អនុសយយមក ព្រះពុទ្ធអង្គទេសនាដោយអនុស័យ ៧ មានកាមរាគានុស័យជាដើម ជាគូ ៗ គ្នា ។ ចិត្តយមក ព្រះពុទ្ធអង្គទេសនាដោយចិត្ត ៨៩ ដួងជាគូ ៗ គ្នា ។ ធម្មយមក ព្រះពុទ្ធអង្គទេសនាដោយចេតសិកធម៌ ៥២ ជាគូ ៗ គ្នា ។ ឥន្ទ្រិយយមក ព្រះ

---

១- ពាក្យក្នុងគម្ពីរព្រះអភិធម្មនេះ ត្រូវអានតាមរបៀបភាសាបាលីថាយមកៈ មូលៈ កុសលៈ ។ល។ មិនបាច់ប្រើយុគលពិន្ទុទេ ។

ពុទ្ធអង្គទ្រង់ទេសនាដោយឥន្ទ្រិយ ២២ ជាគូ ៗ គ្នា ។

អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា ព្រះពុទ្ធអង្គទេសនានូវព្រះអរិយសច្ច, សង្ខារ, អនុស័យ, ចិត្ត, ចេតសិក និងឥន្ទ្រិយជាគូៗ គ្នា ហេតុនោះទើបឈ្មោះថា សច្ចយមក, សង្ខារយមក, អនុសយយមក ចិត្តយ-មក, ធម្មយមក, និង ឥន្ទ្រិយយមក, ដោយលំដាប់គ្នា ។

ក្នុងយមក ១០ ប្រការ មានមូលយមកជាដើម មានឥន្ទ្រិយយមកជាបរិយោសាននោះ មានយមកបែកចេញទៅទៀតជាច្រើនក្រៃលែង និងអធិប្បាយក្នុងមូលយមកជាមុន ។

មានពាក្យបុច្ឆាថា គោះធម្ម ព្រោះអត្ថដូចម្ដេច បានជាឈ្មោះថា មូលយមក ?

មានពាក្យវិសជ្ជនាថា មូលធម្ម យមកនេះឈ្មោះមូលយមក ព្រោះអត្ថថាជាដើមជាទីតាំងនៃយមកទាំងឡាយ ៗ មានពាក្យអធិប្បាយថា ព្រះពុទ្ធអង្គទេសនាយមកនេះ ទុកជាខាងដើម ហើយទើបទ្រង់សំដែងយមកទាំងឡាយដទៃទៀត ឲ្យបែកខ្វែកចេញ ទៅទៀតជាច្រើនក្រៃលែង ហេតុដូច្នោះ យមកនេះទើបបានឈ្មោះថា មូលយមក ។ ឯមូលយមកនេះព្រះពុទ្ធអង្គទេសនាប្រដាប់ដោយវារៈ ២ ប្រការគឺ ឧទ្ទេសវារ ១ និទ្ទេសវារ ១ ។

ឧទ្ទេសវារនោះ គឺទេសនាដោយបំប្រួញ លើកឡើងសំដែងតែខ្លីៗ ប៉ុណ្ណោះឈ្មោះថា ឧទ្ទេសវារ ។

ដែលទេសនាដោយពិស្តារ បែកចេញជាពួក ៗ ទៅទៀតឈ្មោះថា ឆនិទ្ទេសភាគ ។

ឯមូលយមក មានយមកជាបរិវារបែកចេញទៅទៀតជា ៣ ប្រការ គឺ អត្ថយមកា ១ ធម្មយមកា ១ បុច្ឆាយមកា ១ ជាបរិវារ នៃមូលយមកទាំង ៣ ប្រការ ។

អត្ថយមកនោះ ព្រះពុទ្ធអង្គសំដែងនូវសេចក្តី ២ ប្រការគឺកុសល ១ មូលនៃអកុសល ១ ។

ធម្មយមកនោះ ព្រះពុទ្ធអង្គសំដែងនូវបាលីជាគូ ៗ គ្នា ត្រាស់ជាអនុលោមបដិលោមត្រឡប់ទៅត្រឡប់មក ព្រះបាលីដែលសំដែងនោះ ជាអនុលោមទីមួយ ជាបដិលោមទីមួយ អាស្រ័យហេតុនេះ ទើបបាន ឈ្មោះថា ធម្មយមកា ។

បុច្ឆាយមកនោះ ព្រះពុទ្ធអង្គទេសនាបុច្ឆាជាគូ ៗ សួរម្តងមួយ ២ ៗ ជាគូ ៗ គ្នា ហេតុនោះទើបឈ្មោះថា បុច្ឆាយមកា ។

យមកទាំង ៩ ប្រការ មានខន្ធយមកជាដើម មានឥន្ទ្រិយយមកជា បរិយោសាន មានយមកបរិវារបែកចេញទៅទៀតជា ៣ ប្រការគឺ អត្ថ-យមកា ១ ធម្មយមកា ១ នឹង បុច្ឆាយមកា ១ ដូចគ្នា ។

យមក ៣ គឺ: អត្ថយមកា ១ ធម្មយមកា ១ បុច្ឆាយមកា ១ នោះ ក្នុងយមកមួយ ៗ មានន័យបួន ៗ គឺមូលន័យ ១ មូលកន័យ ២ មូលមូល-

ន័យ ១ មូលមូលកន័យ ១ ជាន័យ ៤ ប្រការ ។

ន័យទាំង ៤ នោះ ក្នុងន័យមួយ ៗ មានយមកបរិវារបី ៗ គឺ: មូល-

យមក ១ ឯកមូលយមក ១ អញ្ញមញ្ញមូលយមក ១ ។

យមកទាំង ៣ នោះ ក្នុងយមកមួយ ៗ មានបុច្ឆាពីរ ៗ គឺ:

អត្ថសង្ឃ័យ ១ អត្ថសន្និដ្ឋាន ១ ។

យមកដែលជាពួកធំមួយ ៗ នោះ មានន័យបួនជាបរិវារហើយមាន

បុច្ឆា ២៤ មានអត្ថ ៤៨ ដូចគ្នាទាំង ១០ យមក ។

ពណ៌នាយមកទាំងនេះ ប្រាថ្នានឹងឲ្យឃើញជាពួកជាក្រុមគ្នា ហេតុ

នោះ អ្នកប្រាជ្ញចូលកំណត់ចាំទុកក្នុងសន្ដានចុះ ។

## មូលយមក

ពណ៌នាក្នុងមូលយមកខាងដើម សេចក្ដីថា លោកនាថ៉ោ សម្ដេច

ព្រះមានព្រះភាគជាទីពឹងរបស់សត្វក្នុងសកលលោកធាតុ ព្រះអង្គត្រាស់

ទេសនាតាំងផ្ដើមជាបុច្ឆាមុនដំបូងថា យេ កេចិ កុសលា ធម្មា

ធម៌ទាំងឡាយណាជាកុសល ធម៌ទាំងឡាយនោះជាមូលនៃកុសល, ធម៌

ទាំងឡាយណាជាមូលនៃកុសល ធម៌ទាំងឡាយនោះ ជាមូលនៃកុសល

ឬ ? ត្រាស់បុច្ឆាដូច្នេះហើយ ទើបត្រាស់វិសជ្ជនាដោយព្រះអង្គឯងថា

អាមន្តា អើ ! ធម៌ទាំងឡាយពួកណាមួយជាកុសល ធម៌ទាំងឡាយ

ពួកនោះឯងជាមូលនៃកុសល, ធម៌ពួកណាដែលជាមូលនៃកុសល ធម៌

ពួកនោះឈ្មោះថាកុសល ។ ត្រាស់វិសជ្ជនាដោយព្រះអង្គឯងដូច្នេះហើយ ទើបត្រាស់បុច្ឆាតទៅទៀតថា កតមេ ធម្មា កុសលា ធម៌ទាំងឡាយដែលថាជាមូលនៃកុសលនោះ គឺធម៌ពួកណា ? ទើបត្រាស់វិសជ្ជនាថា តយោ ធម្មា កុសលា ធម៌ទាំងឡាយបីប្រការ ជាមូលនៃកុសលបី ។ ទើបត្រាស់បុច្ឆាថា ធម៌ទាំងបីប្រការដែលឈ្មោះថាជាមូលនៃកុសលបីប្រការនោះ តើបានដល់ធម៌ពួកណា ? ទើបត្រាស់វិសជ្ជនាថា ធម៌បីប្រការដែលជាមូលនៃកុសលនោះគឺៈ អលោភោ ១, អទោសោ ១, អមោហោ ១ ។

មានពាក្យព្រះអដ្ឋកថាចារ្យ ពោលបន្ថែមសេចក្ដីអនុលោមតាមព្រះពុទ្ធដីកានៃសម្ដេចព្រះបរមទសពល ដើម្បីនឹងញុំាងកុលបុត្រអ្នកកើតខាងក្រោយ ឲ្យបានដឹងសេចក្ដីដោយងាយ ។ អធិប្បាយថា មូលន្តិ បតិដ្ឋា មូលសព្ទនោះ ប្រែថាឫស, គល់, ទីតាំង ។ ធម៌ទាំងបីប្រការគឺៈ អលោភោ, អទោសោ, អមោហោ នោះជាឫស ជាគល់ ជាទីតាំងនៃកងកាកុសលទាំងពួង ។ អាស្រ័យធម៌បីប្រការនេះឯងជាមូល បានជាកុសលទើបកើតឡើងបាន ប្រៀបដូចឫសនៃដើមឈើដែលជាទីកើតជាទីតាំងនៃដើមឈើ មូលំ និស្សយា ចម្កាព្រឹក្សាជាតិទាំងអស់ រមែងអាស្រ័យនូវឫសទើបដុះឡើងបាន បើគ្មានឫសកែវទេ មិនអាចនឹងដុះលូតលាស់ឡើងបានឡើយ ។ សេចក្ដីនេះដូចម្ដេច ? កុសល-

ធម៌ទាំងឡាយទាំងពួងនឹងកើតមានឡើងបាន ក៏អាស្រ័យតែធម៌បីប្រការគឺ អលោភោ ១, អទោសោ ១, អមោហោ ១ ។ បើធម៌ទាំងបីប្រការនេះគ្មានទេ ការកុសលទាំងពួងក៏គ្មានដែរ ។ ការកុសលនឹងកើតមានឡើងបាន ក៏អាស្រ័យនូវធម៌បីប្រការ ដូចជាដើមឈើអាស្រ័យឫសនោះដែរ ។

## អលោភោ

អលព្ភតីតិ អលោភោ ធម៌ដែលឈ្មោះថា អលោភោ នោះ បាននឹងហេតុមិនប្រាថ្នាមិនចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃ ។ អទោសោ នោះ បាននឹងសភាពគ្មានចិត្តប្រទូសរ៉ាយអ្នកដទៃ នឹងទ្រព្យសម្បត្តិរបស់គេ ។ អមោហោ នោះ គឺការមិនវង្វេង មិនប្រាសចាកស្មារតី ។

អលោភោ នាមហេតុ សេចក្ដីមិនលោភកើតមានក្នុងសន្ដានចិត្តរបស់អ្នកណា ជាហេតុនឹងឲ្យអ្នកនោះបរិច្ចាគទានបាន ដោយហោចទៅសូម្បីខ្លួនមិនបានឲ្យ បើឃើញគេឲ្យ ក៏មានចិត្តត្រេកអរដែរ ជួយអនុមោទនាទានរបស់គេ លុះបានអនុមោទនាទានហើយ ក៏នឹងបានតាំងនៅក្នុងបុញ្ញកិរិយាវត្ថុ ។ ការបំពេញទាននោះអាស្រ័យតែចិត្តមិនលោភ ហេតុនេះ អលោភោ ទើបរាប់ចូលក្នុងមូលនៃកុសល ។ អលោភោ មានក្នុងសន្ដានចិត្តហើយ ជាហេតុនឹងឲ្យរួចផុតពីសេចក្ដីទលិទ្រ ហើយនឹងឲ្យជាទីស្រឡាញ់របស់ទេវតានឹងមនុស្សទាំងឡាយ ហេតុតែបានបរិច្ចាគទាន ។

ទានំ ធលិទ្ធុបហារិកាំ ទានទីងនាំឲ្យកំចាត់បង់ចេញនូវសេចក្តីទលិទ្រ កំសត់ទុគ៌ត ។ ទានំ ពន្ធុតិ ចាថេយ្យំ ទានទីងឲ្យបានខ្ចប់វេចស្តាយស្បៀងជាប់តាមខ្លួនទៅក្នុងផ្លូវកន្តារ គឺសង្សារវដ្ត បើមិនទាន់ដល់ព្រះនិព្វានដរាបណា ក៏មិនបានក្រលំបាកអត់ឃ្លានគ្មានអាហារ ទីងបរិបូណ៌ដោយទ្រព្យសម្បត្តិ គ្រប់ជាតិគ្រប់ភពដរាបនោះ ។ ទានំ សហាយ សម្ភតំ ទានជាមិត្រសំឡាញ់ដើរផ្លូវទៅ រហូតដល់ឆ្លងមហណ្ណពទៅដល់ត្រើយ ។ ទានំ អោក្កបជំ វរំ ទានជាផ្លូវសម្រាប់ដើរទៅកាន់អមតវិថី ។

ការបំពេញទាននេះ បុគ្គលមិនងាយនឹងធ្វើបានទេ ទាល់តែមិនលោភហើយពិចារណាឃើញជាក់ច្បាស់ថា ផលទានដែលអាត្មាបានបំពេញនោះ នឹងបានធ្វើជាស្បៀងទៅខាងមុខ ឃើញដូច្នេះទើបបំពេញទានបាន ។ បុគ្គលអ្នកបំពេញទាន បានឲ្យភោជនាហារជាទាននោះ បានឈ្មោះថាឲ្យជីវិត, ឲ្យអាយុ, ឲ្យកម្លាំង, ឲ្យបញ្ញា, ព្រោះថាភោជនាហារកាលណាបរិភោគរួចហើយ ក៏អាចរក្សាជីវិតឲ្យចំរើនវឌ្ឍនាការ ញុំាងអាយុឲ្យនៅយូរអង្វែងបាន, នឹងឲ្យមានកម្លាំងមាំមួន ព្រោះបានបរិភោគភោជនាហារ លុះតែបានបរិភោគអាហាររួចហើយ ទើបធ្វើការងារឲ្យសម្រេចទៅបាន ។

(នៅមានត)

# សម្ដេចព្រះធម្មលិខិត លី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈឹន ពិនិត្យ

(តមក)

---

ឯសម្ដេចព្រះជម្ពូទីបេស្សរាធិបតីធម្មាសោករាជ ព្រះអង្គបានទតឃើញហេតុនោះហើយ ក៏ដល់នូវសេចក្ដីស្ញប់ស្ញែងភ័យស្លុតក្នុងព្រះហឫទ័យ ទើបរំពឹងគិតថាៈ កុមារដែលមានឫទ្ធិអានុភាពយ៉ាងនេះ ជាបុគ្គលអាចនឹងសម្លាប់យើងហើយដណ្ដើមយកនូវរាជសម្បត្តិអំពីយើង សោយរាជ្យបានដោយងាយឮដ៏អនាគតដ៏ខាងមុខពុំលែងឡើយ ដូច្នេះត្រូវតែយើងសម្លាប់កុមារនេះជាមុនទើបបាន ។

ព្រះបរមក្សត្រិយ៍ទ្រង់ព្រះចិន្ដាដូច្នេះហើយ ក៏ត្រឡប់មកកាន់ព្រះនគរវិញ, លុះបានចូលមកដល់នគរហើយ ក៏ត្រាស់ឲ្យហៅ វិសមលោមកុមារ ចូលមកកាន់សំណាក់ព្រះអង្គ ហើយបង្គាប់អាមាត្យទាំងឡាយថាៈ ម្នាលអ្នកទាំងឡាយដ៏ចំរើន ត្រូវអ្នកទាំងឡាយចាប់ចងកុមារនេះនាំយកទៅដាក់ក្នុងពន្ធនាគារឃុំរក្សាទុកកុំឲ្យចេញទៅណារួចឡើយ ។ ឯអាមាត្យទាំងឡាយ ក៏បានធ្វើតាមបង្គាប់ព្រះបរមក្សត្រិយ៍នោះឯង ។

គ្រាន់តែ វិសមលោមកុមារ ដេកនៅក្នុងគុកនេះ អស់វេលាកន្លងទៅបានបួនខែគត់ ក្រោយនោះព្រះបាទធម្មាសោករាជព្រះអង្គ

ត្រាស់បង្គាប់អាមាត្យឲ្យយកឫស្សីមកចងជាបាច់ចំនួនហុកសិបបាច់ ក្នុងមួយបាច់ហុកសិបដើម ៗ ប្រវែងហុកសិបហត្ថ ហើយប្រមូលឲ្យមូលគ្នាជាដុំឲ្យដាក់ស្នូលដែកវាងក្នុងហើយលើកឡើងបញ្ឈរនៅមុខព្រះលាន ទើបព្រះអង្គត្រាស់បង្គាប់អាមាត្យឲ្យទៅដោះ វិសមលោមកុមារ ចេញអំពីគុកនាំចេញមកកាន់សំណាក់ព្រះអង្គ ហើយទ្រង់ត្រាស់បង្គាប់ជាថ្មីទៀតថា: ម្នាលអ្នកទាំងឡាយដ៏ចំរើន ត្រូវអ្នកបង្ខំឲ្យកុមារកាន់យកដាវនេះកាប់បាច់ឫស្សីទាំងហុកសិបបាច់ឲ្យដាច់ខ្ទី ៗ ប្រមាណបួន ៗ ធ្លាប់ឲ្យត្រឹមគ្នា បើកុមារនេះកាប់ពុំបានដាច់ទេ ត្រូវអ្នកទាំងឡាយសម្លាប់កុមារនេះ កុំវានឡើយ ៗ

ឯវិសមលោមកុមារ លុះបានស្តាប់ព្រះពជឱង្ការត្រាស់បង្គាប់ដូច្នោះហើយ ក៏សន្ទនាចំពោះអាមាត្យទាំងនោះថា: បពិត្រអ្នកទាំងឡាយខ្លួនខ្ញុំបានដេកនៅក្នុងពន្ធនាគារជាយូរហើយ ត្រូវអត់បាយអត់ទឹកលំបាកដោយអាហារ ខ្ញុំស្រេកឃ្លានពន់ពេកណាស់ ដូច្នេះ ត្រូវតែខ្ញុំបរិភោគបាយ ផឹកទឹកឲ្យឆ្អែតជាមុនសិន ទើបកាប់បាច់ឫស្សីនេះជាខាងក្រោយ ៗ

ពួកអាមាត្យបានស្តាប់ហើយ ក៏ពោលតបវិញថា: ឥឡូវនេះយើងគ្មានអាហារណាសម្រាប់ឲ្យអ្នកបរិភោគទេ ៗ កុមារស្តាប់ហើយពោលថា: បើដូច្នេះខ្ញុំសុំលាទៅផឹកទឹកក្នុងស្រះបោក្ខរណីនេះសិន ៗ

អាមាត្យទាំងឡាយក៏ទទួលព្រមថា: សាធុ ៗ ប្រពៃហើយ ៗ ក៏នាំ

កុមារទៅកាន់ស្រះបោក្ខរណីនោះឯង ។

ចំណែកខាងវិសមលោមកុមារ ក៏ចុះទៅក្នុងស្រះបោក្ខរណីបានឆ្ងូតហើយមុជចុះទៅកាន់បាតស្រះបរិភោគកក់ដីពបដល់ឆ្អែត ផឹកទឹករួចស្រេច ទើបត្រឡប់ឡើងមកវិញយកដៃចាប់ដងដាវ នៅវេលាដែលមហាជនទាំងអស់ក៏គុងប្រជុំគ្នាចាំមើល ហើយស្ទុះលោតឡើងឮដ៏អាកាសកំពស់ប្រមាណ ៨០ ហត្ថ ដោយកំឡាំងឆាប់រហ័សហើយចុះមកកាប់បាច់ឫស្សីទាំងអស់ឲ្យដាច់ជាកំណាត់តូច កំណាត់ធំ ប្រមាណបួន ១ ធ្នាប់ដោយដាវ តាំងពីចុងដល់គល់ ស្រាប់តែបានឮសំឡេងក្រឹកៗ ដោយត្រូវស្នូលដែកនៅខាងក្នុង លុះបានដឹងហើយ ក៏បោះដាវចោលទ្រហោយំបំរះនទៀលក្នុងកាលនោះឯង ។

ទើបរាជបុរសទាំងឡាយគេសួរថា: ព្រោះហេតុអ្វី បានជាអ្នកយំ? ព្រះរាជកុមារក៏និយាយប្រាប់ទៅរាជបុរសទាំងនោះថា: បានជាខ្ញុំយំ ព្រោះខ្ញុំគិតថា: បណ្តាបរិស័ទច្រើនដល់ម្ល៉េះ មិនមានបុរសណាមួយ មានសន្តានល្អស្រឡាញ់រាប់អានខ្ញុំដល់ម្នាក់សោះ ប្រសិនបើមានបុរសមានសន្តានល្អ គង់នឹងនិយាយប្រាប់ខ្ញុំថា:ខាងក្នុងបាច់ឫស្សីទាំងនេះ មានស្នូលដែកបង្កប់នៅខាងក្នុង, ចំណែកខ្ញុំ លុះបានដឹងហើយក៏នឹងប្រុងប្រយ័ត្នកាប់បាច់ឫស្សីទាំងឡាយនេះ ឲ្យដាច់ជាកំណាត់តូច កំណាត់ធំប្រមាណបួន ១ ធ្នាប់បានដោយពិត ។

លំដាប់នោះ ព្រះបាទធម្មាសោកពេជព្រះបរមក្សត្រិយ៍ទ្រង់បានទតមើលនូវអំពើដែលរាជកុមារបានធ្វើជាអស្ចារ្យដូច្នោះហើយ ព្រះអង្គក៏មានព្រះរាជហឫទ័យសោមនស្សជ្រះថ្លា បានព្រះរាជទានទ្រព្យសម្បត្តិ មានប្រមាណច្រើន ហើយព្រះអង្គតាំងឲ្យអភិសេក វិសមលោមកុមារ ឲ្យស្ថិតនៅក្នុងឋានៈជាព្រះឧបរាជក្នុងកាលនោះហោង ។

ឯកំឡាំងរបស់ វិសមលោមកុមារ នោះបានឈ្មោះថាជាលាភបាននូវសម្បត្តិដ៏វិសេសយ៉ាងនេះឯង ។

ពាក្យបុច្ឆាសួរថា: កំឡាំងនេះទីងថាជាកំឡាំងនៃជាតិទីងគោត្រជាដើមក៏ទេ ទីងថាជាកំឡាំងនៃអំពើទុច្ចរិតទាំង ១០ មានបាណាតិបាតជាដើមក៏ទេ កំឡាំងរបស់ វិសមលោមកុមារ នេះ ជាកំឡាំងកើតមកអំពីតេអ្វី ?

វិសជ្ជនាថា: កំឡាំងនេះជាកំឡាំងកើតមកអំពីសេចក្តីសុចរិតដែលកុមារបានឲ្យទានបាយជាដើម ដល់ព្រះភិក្ខុសង្ឃក្នុងសាសនាព្រះពុទ្ធកស្សបនោះឯង ។ ឯ វិសមលោមកុមារ លុះបានទទួលទីជាឧបរាជហើយ សោយមហាសម្បត្តិដ៏ប្រសើរយ៉ាងនេះ ក៏មានព្រះហឫទ័យជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បានធ្វើសក្ការបូជាដល់ភិក្ខុសង្ឃជាច្រើន មានព្រះមហាមោគ្គលីបុត្តតិស្សត្ថេរជាអាទិ៍ ដោយអំណាចនៃទានវត្ថុមានចីវរបិណ្ឌបាតសេនាសនគិលានភេសជ្ជៈជាដើមហើយ បានរក្សាសីលប្រាំសីលប្រាំបី

ជាប់ពុំដាច់ដរាបដល់អស់អាយុទៅ ក៏បានឡើងទៅសោយសម្បត្តិទិព្វក្នុងស្ថានទេវលោកនាយ ដោយសមគួរតាមបុញ្ញកម្មរបស់ខ្លួនដោយពិត ៗ

ព្រោះហេតុដូច្នោះ ព្រះអរហន្តទាំងឡាយ លោកពោលជាបទព្រះគាថាដូច្នេះថា:-

ឯវំ តិវិធំ សុចរិតំ សុមនោ ការិត្វា
លភតិ ពលនេកវិកវស្ស កុមារកោ សោ
តុម្ហេ ធីរា សុចរិតំ វិកភទ្ទុបំ
ការិត្វាន និព្វុតិបទការណំ ករោថ ។

អធិប្បាយថា ឯវិសមលោមកុមារនោះ មានចិត្តល្អជ្រះថ្លា បានធ្វើនូវអំពើសុចរិតទាំង ៣ ប្រការយ៉ាងនេះហើយ ជាបុគ្គលបាននូវកំឡាំង គួរដល់ការបាននូវសម្បត្តិច្រើនជាអនេកនឹងគណនាគ្រាប់ពុំបានឡើយ ៗ អ្នកទាំងឡាយដែលមានព្យាយាម បើបានបំពេញនូវសុចរិតឲ្យល្មមសមគួរដល់សម្បត្តិរបស់ខ្លួនហើយ បានឈ្មោះថាបានបំពេញនូវហេតុជាឧបាយដើម្បីដល់នូវព្រះនិព្វាន ជាទីរលត់នូវកងទុក្ខទាំងពួងបានដោយពិត ៗ

សំដែងរឿងនិទានវិសមលោមកុមារ ឧបកដជាតំរប់បី ក្នុងវគ្គទីពីរ ក៏ចប់សេចក្ដីជាសង្ខេបតែប៉ុណ្ណោះឯង ៗ

---

(នៅមានត)

## មហោសថជាតក

# លោក អ៊ុម-ភន បម្លងពីសាស្ត្រាស្លឹករឹត

*ព្រះពុទ្ធវង្ស គិប-តូរ ពិនិត្យ*

( តមក )

---

លំដាប់នោះព្រះមហាក្សត្រទ្រង់ផ្តើមនូវសិរីមន្ទកបញ្ហា ស្តេចសូត្រនូវបទព្រះគាថា ជាបឋមថា:

បញ្ញាយុបេតំ សិរីហា វិហីនំ
យសស្សិនំ វាបិ អបេតបញ្ញំ
បុច្ឆាមិ តំ សេនក ឯតមត្ថំ
កមេត្ថ សេយ្យោ កុសលា វទន្តិ ។

សេនក ហៃអាចារ្យសេនកអើយ ! អញនឹងដណ្ដឹងអាថ៌ប្រស្នានោះនឹងព្រះស្ដែង, រីអ្នកមួយដ៏ប្រកបនូវប្រាជ្ញា ហើយថយលែងយស-សម្បត្តិបរិវារ, រីអ្នកមួយមានយសសម្បត្តិបរិវារច្រើន ហើយប្រាសចាកប្រាជ្ញា; រីអ្នកទាំងពីរនេះ តើអ្នកឯណាប្រសើរ ? ។

អាចារ្យសេនក ស្ដាប់អាថ៌ប្រស្នានោះហើយ លុះនូវអំណាចនៃអាត្មា ឆ្លើយនូវអាថ៌ប្រស្នាទូលព្រះមហាក្សត្រជាបទព្រះគាថាថា:

ធីរា ច ពាលា ច ហវេ ជនិន្ទ
សិប្បូបបន្នា ច អសិប្បិនោ ច

សុជាតិមន្តោបិ អជាតិមស្ស
យសស្សិនោ បេសកោ ករោតិ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញោ និហីនោ សិរិមាវ សេយ្យោតិ ។

បពិត្រគន្ធនគ្រថ្លៃប្រសើរអើយ ! អ្នកប្រាជ្ញក្តី អ្នកខ្លៅក្តី អ្នកមានសិល្បសាស្ត្រក្តី អ្នកឥតសិល្បសាស្ត្រក្តី អ្នកមានជាតិឧត្តមក្តី អ្នកមានជាតិថោកថយក្តី; អ្នកទាំងអម្បាលនេះ សឹងដំណើរបំរើអ្នកមានយស, ហេតុនោះខ្ញុំយល់ហើយ ខ្ញុំថាអ្នកមានប្រាជ្ញា ឥតសម្បត្តិមិនប្រសើរ អ្នកដែលមានសិរីសម្បត្តិនោះទើបប្រសើរ ។

ស្តេចស្តាប់ពាក្យអាចារ្យសេនកដូច្នោះហើយ, ស្តេចមិនដណ្តឹងទៅអាចារ្យទាំង ៣ នោះឡើយ, ហេតុដ្បិតអំពីមុនមកស្តេចរែងដណ្តឹងកិច្ចការអ្វីមួយហើយ អាចារ្យទាំង ៣ សឹងឆ្លើយតាមពាក្យអាចារ្យសេនក ហេតុនោះ ស្តេចមិនដណ្តឹងឡើយ, ស្តេចដណ្តឹងទៅកាន់ពោធិសត្វថា: មហោសធ បណ្ឌិត ម្នាលបាមហោសថ! អ្នកប្រាជ្ញគាប់មានប្រាជ្ញាមិនចេះថយយល់អាថ៌ប្រស្នាទាំងពួង អញនឹងដណ្តឹងថា អ្នកខ្លៅមានបរិវារច្រើន, អ្នកមានប្រាជ្ញាហើយហ៊ាននូវសម្បត្តិ, អ្នកទាំងពីរនេះតើឯណាប្រសើរ ? ។

លំដាប់នោះ, ពោធិសត្វទូលថា បពិត្រមហារាជអើយ ! សូម

អញ្ជើញស្តេចស្តាប់ ខ្ញុំនឹងសំដែងថ្វាយព្រះអង្គហោង ៗ ទើបពោធិសត្វ សូត្រនូវព្រះគាថានេះថា :

បាបានិ កម្មានិ ករោន្តិ ពាលា
ឥធមេវ សេយ្យោ ឥតិ មញ្ញមានា
ឥធលោកទស្សី បរលោកំ អទស្សី
ឧភយត្ថ ពាលោ កលិមគ្គហេសិ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញាវ សេយ្យោ ន យសស្សី ពាលោតិ ៗ

សេចក្តីថា: បពិត្រមហារាជអើយ ! រីអ្នកកំឡៅទាំងឡាយ ក៏សឹងទុកចិត្តថា សម្បត្តិប្រសើរ ហើយក៏ធ្វើនូវអំពើបាបទាំងឡាយយល់តែលោកិយនេះ ហើយមិនយល់បរលោក ហើយកាន់យកនូវការអកុសលអំពលញដ៏លោកនេះ, ហេតុដូច្នោះ ខ្ញុំថា អ្នកមានប្រាជ្ញាប្រសើរ រីឯអ្នកខ្លៅមានយសបរិវារច្រើននោះពុំប្រសើរឡើយ ៗ

ស្តេចស្តាប់ពាក្យពោធិសត្វទូលដូច្នោះហើយ, ស្តេចមិលមើលទតទៅកាន់អាចារ្យសេនកថា ឥឡូវនេះ, មហោសថថា អ្នកប្រកបនូវប្រាជ្ញា ឯងនោះឧត្តមប្រសើរ ៗ ឯអាចារ្យសេនកឯង តើថាដូចម្តេច ? អាចារ្យសេនកស្តាប់ហើយទូលថា បពិត្រមហារាជអើយ ! រីមហោសថនេះ នៅក្មេងក្តាត់ ផុំក្លិនក្សីរអំពីមាត់នៅឡើយ ទឹងបេះអ្វីព្រះអង្គ ; សូម

ព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យខ្ញុំជាអ្នកចាស់ទុំបរមបូរាណ នឹងនិទានថ្វាយ និយាយពីមហាសេដ្ឋីមួយឈ្មោះ គោវិន្ទ ស្ថិតនៅឯនគរនេះ មានទ្រព្យ ៨០ កោដិឃ្លាំង មានអ្នកផងទាំងឡាយមកគាល់ហៅ នៅបំរើជាប្រក្រតី, សេដ្ឋីនោះមានរូបអាក្រក់ក្តាត់ ឥតកូនប្រុស-ស្រី មិនចេះសិល្បសាស្ត្រអ្វីដល់តិច ឥតសាច់ផៅ កាលណាស្រដីទៅមានទឹកមាត់នោះហូរហៀរចេញពេញថ្ពាល់ទាំងសងខាង មាននាងពីរនាក់ពាក់នូវគ្រឿងប្រ-ដាប់ល្អចំណាប់ដូចស្រីសួគ៌ មុខគួរតែអាណិតពិតពិលរម៉ិលមើលនូវលំអ ហើយកាន់យកនូវផ្កានីលុប្បលរីកថ្មី នៅសងខាងសេដ្ឋីនោះ តែងនឹងទទួលជូតទឹកមាត់នោះបោះចោលដោយបង្អួចទៅក្រៅ, រីអ្នកប្រមឹកស្រាផងទាំងពួង ដើរទៅកាន់រោងស្រាហើយប្រាថ្នាចង់បានផ្កានីលុប្បល ទៅដល់ផ្ទះគោវិន្ទសេដ្ឋី ស្រដីហៅទៅថា បពិត្រអ្នកគោវិន្ទសេដ្ឋីអើយ ! រី-គោវិន្ទសេដ្ឋីនោះស្ថិតនៅទៀបមាត់បង្អួច ស្តាប់ឮពាក្យអ្នកប្រមឹកស្រាផងទាំងឡាយហៅទៅដូច្នោះ មហាសេដ្ឋីនោះក៏ឆ្លើយថា ហៅអ្វី ? ស្រដីតែម្ល៉ោះហើយ ទឹកមាត់នោះហូរហៀរសសៀរអំពៀរចេញពេញថ្ពាល់ទាំងសងខាងនោះ, រីស្រីដែលស្អាងនោះ ជូតទឹកមាត់នឹងផ្កានីលុប្បលចោលទៅដល់លង្វែកផ្លូវ អ្នកប្រមឹកស្រារើសទៅលាងទឹកយកទៅសៀតត្រចៀកអាត្មា ហើយដើរទៅកាន់រោងស្រានោះហោង ៗ រីអាចារ្យសេនកនាំឧទាហរណ៍មកអធិប្បាយនិយាយនូវប្រការអម្បាលនេះហើយ ទូលព្រះ

មហាក្សត្រថា បពិត្រក្សត្រថ្លៃប្រសើរអើយ ! វីគោវិន្ទសេដ្ឋីនោះ គាត់មានប្រាជ្ញាអ្វី គាត់ជាអ្នកកំឡៅទេហ៎ះ ហេតុតែមានសម្បត្តិ ទើបគាត់មានអ្នកផងមកចាំបំរើជាបរិវារ ហេតុនោះខ្ញុំថា អ្នកដែលប្រកបនូវសិរីសម្បត្តិនោះប្រសើរ ។

ស្តេចស្តាប់ពាក្យអាចារ្យសេនកទូលដូច្នោះហើយ មានព្រះបន្ទូលទៅទឹងពោធិសត្វថា ត៏ ធិ សំ តាត មហោសថ បណ្ឌិត ហៃមហោសថអ្នកប្រាជ្ញអើយ ចាំទឹងឆ្លើយម្តេចទៅ ? វីចៅមហោសថអ្នកប្រាជ្ញទូលព្រះមហាក្សត្រថា ទេវ បពិត្រព្រះមហាពជអើយ ! វីអាចារ្យសេនកនេះ គាត់ដឹងអ្វីព្រះអង្គ; ឧបមាដូចក្អែកក្អែករកបាយគេ ឬហាក់ដូចឆ្កែស្រែករកអាហារមិនយល់ មហាមុត្តរំ គឺដំបងដ៏ធំត្រូវត្រង់ក្បាលនោះឡើយ, បពិត្រអម្ចាស់ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ខ្ញុំទឹងឆ្លើយថ្វាយ ទើបពោធិសត្វសូត្រជាបទព្រះគាថា ដូច្នេះថា :

លទ្ធា សុខ មជ្ជតិ អប្បបញ្ញោ
ទុក្ខេន ផុដ្ឋោបិ បមោហមេតិ
អាគន្តុនា សុខទុក្ខេន ផុដ្ឋា
សោ វេធតិ វារិចរោវ ឃម្មេ
ឯតម្បិ ធិស្វាន អហំ វទាមិ
បញ្ញោវ សេយ្យោ ន យសស្សិ ពាលោតិ ។

បពិត្រមហារាជអើយ ! រីអ្នកឥតប្រាជ្ញា មានសក្តិយសសរិពិធសម្បត្តិក្តួច ស្មាគើ ហើយធ្វើបាបរំលោយឆ្ងរខ្លួនរំងូង កាលណាទុក្ខមកដល់ខ្លួនហើយ ក៏នឹកញ៉ររំប្រប់ ឧបមាដូចត្រីលើកឡើងអំពីទឹកបោលទៅត្រវកំដៅថ្ងៃ មាន ប្រការម្តេចមិញ, ហេតុនោះ ខ្ញុំយល់ហើយខ្ញុំថា អ្នកមានប្រាជ្ញានោះប្រសើរ, រីអ្នកកំឡៅអន្ធពាល ហើយមានយសបរិពារនោះពុំប្រសើរឡើយ ។

ស្តេចស្តាប់ហើយ មានព្រះបន្ទូលទៅអាចារ្យសេនកថា ហៃអាចារ្យសេនកអើយ ! អ្នកនឹងឆ្លើយម្តេចគេទៅ ? រីអាចារ្យសេនកទូលថា បពិត្រមហារាជអើយ ! រីមហោសថនេះនឹងដឹងអ្វីព្រះអង្គ, រីមនុស្សផងខ្ញុំមិនស្រដី នៅបំរើអ្នកធំសំរើចបានសម្បត្តិ មានទ្រព្យច្រើន ហេតុឧបមាបទប្រាជ្ញាប្រយោជន៍ ដូចឈើមានផ្លែពិសាជា ហើយមានសត្វបក្សីបក្សាគណនា ក៏ចោមរោមពិតក្តីគេក្សានោះហោង; រីឈើនោះ គឺមានប្រាជ្ញាអ្វី, ហេតុតែមានផ្លែពិសា ឧបមាដូចមានសម្បត្តិ, ហេតុនោះខ្ញុំយល់ហើយខ្ញុំថា អ្នកមានប្រាជ្ញាឥតសម្បត្តិពុំប្រសើរឡើយ, រីអ្នកកំឡៅមានសម្បត្តិនោះ ប្រសើរ ។

(នៅមានត)

## ផ្នែកអក្សរសាស្ត្រ

### វប្បធម៌ខ្មែរ

# សារៈសំខាន់នៃបណ្ណាល័យ

លោក លី · ជាមតេង

សមាជិកក្រុមអភិបាល សមាគមអ្នកនិពន្ធខ្មែរ

រៀបរៀង

ក្នុងទស្សនាវដ្ដីយើងលេខមុន ខ្ញុំបានលើកយកសារៈប្រយោជន៍នៃសារមន្ទីរមកអធិប្បាយយ៉ាងហូរហែ ដើម្បីជួយទាញសតិអារម្មណ៍របស់ជនរួមជាតិយើង ឲ្យចាប់ក្ដីកនឹកដល់គ្រឹះស្ថានដ៏ស្តុកស្ដម្ភនេះ កុំឲ្យមានចិត្តគិតទុកដាក់ថាទីជាទីស្មសានឡើយ ៗ តទៅនេះ ខ្ញុំសូមលើកយកសារៈសំខាន់នៃបណ្ណាល័យមកអធិប្បាយម្ដង ព្រោះជនជាតិយើងភាគច្រើននៅពុំទាន់យកចិត្តទុកដាក់ខាងមន្ទីរនេះនៅឡើយ ៗ ជាកស្តុតាងនៅក្នុងបណ្ណាល័យនីមួយៗ ពុំសូវឃើញមានអ្នកអានចេញចូលញឹកញាប់ទេ ច្រើនតែឃើញនៅស្ងាត់ជ្រងំ មានអ្នកខ្លះដល់ទៅមិនទាំងដឹងថាទីនេះគេធ្វើអ្វី មានប្រយោជន៍អ្វីផង ៗ

សព្វថ្ងៃនៅពជធានីយើង មានបណ្ណាល័យធំៗ ពីរ ដែលជារបស់រាជការគឺ: បណ្ណាល័យជាតិ និងបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ៗ បណ្ណាល័យទាំងពីរនេះ មានសៀវភៅនិងក្បួនខ្នាតក្រាំងសាស្ត្រា ទាំងភាសា

ជាតិ ទាំងភាសាបរទេស ជាច្រើនម៉ឺនក្បាលដំកល់នៅក្នុងទូធំៗ ៗ ប៉ុន្តែ មានអ្នកចេញចូលអាន, ខ្ចីយកទៅអាន មានចំនួនស្តួចស្តើងណាស់ ហើយបើមានខ្លះក៏កាគច្រើន ច្រើនតែជាជនបរទេសថែមទៀត ៗ ត្រង់នេះ ក៏ជាភស្តុតាងមួយទៀត បង្ហាញឲ្យឃើញថាជាតិយើងពុំទាន់យកចិត្តទុកដាក់នឹងបណ្ណាល័យនៅឡើយ ៗ តែទោះបីយ៉ាងនេះក៏ដោយ រាជរដ្ឋាភិបាលយើងក្រោមព្រះកិច្ចដឹកនាំយ៉ាងភ្លឺស្វាង នៃសម្តេចព្រះប្រមុខរដ្ឋបិតាឯករាជ្យជាតិរមែងខិតខំកសាងបណ្ណាល័យនេះ ឲ្យកាន់តែមានច្រើនឡើងទៀត ដូចបង្កើតឲ្យមាននៅតាមក្រុមផ្សេងៗ ដើម្បីជាប្រយោជន៍ដល់ការស្រាវជ្រាវរបស់ក្រុមទាំងនោះ ទីងកសាងបានជាបណ្ណាល័យយ៉ាងទំនើបមួយ នៅក្រុងកំពង់ចាម ៗ

បើយើងឃើញដូចនេះ យើងល្បងពិចារណាបន្តិចទៅមើល ថាតើហេតុអ្វីបានជារាជរដ្ឋាភិបាលខិតខំយ៉ាងហ្នឹង ៗ មិនមែនជាការអាថ៌កំបាំងសោះ បើយើងបោលភ្នែកក្រឡេកទៅមើលអារ្យប្រទេសនានា ជាពិសេសគឺប្រទេសដែលទើបតែកសាងឯករាជ្យថ្មីៗ ដូចប្រទេសយើងដែរៗ យើងឃើញថាមន្ទីរនេះ ហុចផលប្រយោជន៍ឲ្យដល់អ្នកស្រុកសន្ធឹកណាស់ ហើយជាការអប់រំមួយយ៉ាងស្ងប់ស្ងាត់ ហើយជ្រួតជ្រាបបានផលជាបំផុតៗ ព្រោះថា មនុស្សនឹងមានបញ្ញាស្មារតីឡើង ដើម្បីឲ្យបានជាពលរដ្ឋវិសេសបាន អាស្រ័យតែមានចំណេះវិជ្ជាភ្លឺស្វាង ពោលគឺជម្រះឲ្យអស់នូវអវិជ្ជា

ងងឹតងងល់អំពីសន្តានចិត្ត ៗ បើពុំដូច្នោះទេ តើនឹងអាចគិតគូអ្វីឲ្យជ្រះស្រឡះសមបំណងបាន ? ៗ យើងដឹងទៀតថា ការបណ្តុះនិស្ស័យចំពោះកុមារ-កុមារី ត្រូវមានមាតាបិតាគ្រូបាធ្យាយជាអ្នកណែនាំ ! ចុះបើមនុស្សចាស់វិញ ហួសអាយុ ហួសវ័យពីការប្រៀនប្រដៅរបស់មាតាបិតាគ្រូអាចារ្យហើយ តើមានអ្វីជាអ្នកដឹកនាំខ្លួនប្រាណទៀត ? គឺមានតែសៀវភៅគម្ពីរដីកាក្បួនខ្នាតនានានេះឯង ជាគ្រូបាអាចារ្យរបស់យើង ៗ ឯក្បួនខ្នាតទាំងនោះ ពុំអាចមានគ្រប់គ្រាន់ផ្ទាល់ខ្លួនម្នាក់ ៗ ទេ ហេតុនេះគឺមានតែបណ្ណាល័យហ្នឹងហើយ ជាអ្នករក្សាទុកផ្គត់ផ្គង់ក្បួនខ្នាតទាំងនេះឲ្យដល់យើង ៗ បានសេចក្តីថា មានតែបណ្ណាល័យនេះហើយ ជាអ្នកដុះខាត់សតិបញ្ញាយើងឲ្យភ្លឺថ្លាគ្រប់មុខវិជ្ជា គ្រប់កិច្ចការទាំងពួង ៗ ចំពោះក្បួនខ្នាតដែលជាប្រភពនៃអារ្យធម៌របស់ជាតិវិញ ក៏មានតែទីនេះឯង ជាអ្នករក្សាឃុំគ្រងទុកឲ្យបានយូរយារពេលទៅមុខបាន ៗ ប្រសិនជាពលរដ្ឋនិយមរៀសគិតរកក្បួនខ្នាតកំដរខ្លួន គ្រាន់នឹងបង្កើនវិជ្ជាក្នុងខ្លួនរៀងពលអាត្មា នោះប្រទេសក៏ពិតជាបានសម្បូណ៌ដោយអ្នកមានប្រាជ្ញាវាងវៃពួតដៃគ្នាដើរតាមផ្លូវត្រូវ ឆ្ពោះទៅកាន់វឌ្ឍនធម៌បានយ៉ាងរួសរាន់ ៗ

អាស្រ័យហេតុទាំងនេះហើយ បានជាប្រទេសផងទាំងឡាយ គេតែងទុកបណ្ណាល័យជាឃ្លាំងវិជ្ជា ជាជង្រុកចំណេះប្រាជ្ញាសំរាប់បណ្តុះពលគ្នា ដែលគេធ្លៀតពេលរៀយ ១ ទៅសំងំអានឬកត់ត្រាគោលគំនិត ឬ

វិជ្ជាណាដែលគេនៅងឿងឆ្ងល់ រហូតដល់ទៅទុកបណ្ណាល័យជាការចាំបាច់របស់ជីវភាពគេ គឺថាឲ្យតែមានភូមិនៅត្រង់ទីណា គេតែងតែបង្កើតឲ្យមានបណ្ណាល័យនៅទីនោះ ៗ ចំណែករាជរដ្ឋាភិបាលយើង ដោយយល់ច្បាស់នូវសារៈសំខាន់នៃបណ្ណាល័យដូច្នេះហើយ បានជាសព្វថ្ងៃតែងតែប្រឹងប្រែងកសាងមន្ទីរនោះ ឲ្យមាននៅគ្រប់ខេត្ត ក្នុងព្រះរាជ-អាណាចក្រ នឹងជួយឧបត្ថម្ភកន្លែងដែលមានស្រាប់ ឲ្យរឹងរឹតតែបានធំទូលាយឡើង ៗ

# ពាក្យខ្មែរប្រែចេញពីបរទេស

## ដោយគណៈកម្មការវប្បធម៌

(តមក)

| | | |
|---|---|---|
| Déluge | *n. m.* | ភ្លៀងរំលា |
| Orage | *n. m.* | ព្យុះភ្លៀង |
| Tempête | *n. f.* | ព្យុះសមុទ្រ |
| Typhon | *n. m.* | ព្យុះសង្ក្រាក |
| Embrun | *n. m.* | មេឃអ័ព្ទ |
| Bourrasque | *n. f.* | ពលវាត |
| Ouragan | *n. m.* | វេគវាត |
| Brouillard | *n. m.* | អ័ព្ទ |
| Crachin | *n. m.* | រលឹមរុយ ៗ; រលឹមរោយ ៗ |
| Brume | *n. f.* | អ័ព្ទងងឹត |
| Cyclone | *n. m.* | ខ្យល់កំបុតត្បូង |
| Trombe | *n. f.* | ខ្យល់កួចទឹក |
| Aseptique | *n. et a.* | អបូតិករ |
| Septique | *n. et a.* | បូតិករ |
| Plâtre | *n. m.* | សម្រោបម្នាងសិលា |
| Réanimation | *n. f.* | ប្រពោធនកម្ម |
| Stérilisation | *n. f.* | និទ្ទោសកម្ម, វញ្ឈនកម្ម |
| Magasin stérile | | ឃ្លាំងនិទ្ទោស, ភណ្ឌាគារវញ្ឈ |
| Approvisionnement | *n. m.* | សំវិធានការ, ការបំរុងទុក |
| Pansement | *n. m.* | វណរោបន៍ |
| Brossage | *n. m.* | ការជម្រះ |
| Médecin-résident | | គ្រូពេទ្យប្រចាំទី |

*(នៅមានទៀត)*

# វចនានុក្រមសំស្រ្កឹត.ខ្មែរ

*ព្រះមហា ប៉ាង - ខាត់ រៀបរៀង*

( តមក )

អតិប្រៀសយៅវន គុ. ដែលនៅកំពុងពេញពាល ។

អតិពន្ធុរ គុ. ដែលងក្រៃពេក, ដែលវិលវល់ក្រៃលែង ។

អតិពល អតិពលវន្ត, អតិពលិន, គុ. អតិពល, ដែលមាន

កម្លាំងក្រៃពេក, ដែលមានពលក្រៃពេក ។ *អតិពលា*,

ស្ត្រី. ឈ្មោះមន្តមាយាកា; ឈ្មោះបុត្រីនៃទក្ស ។ *អតិពលាគត្ឫ*

គុ. ដែលធ្វើដោយកម្លាំង ក្រៃលែង ។

អតិពហុ គុ. ដែលច្រើនក្រៃពេក ។

អតិពាធិ ឆាគុ. បៀតបៀនក្រៃពេក ។

អតិពាប គុ. ដែលពាបក្រៃពេក ។

អតិពីភត្ស អតិពិភត្សិត គុ. ដែលខ្ពើមរអើមក្រៃលែង (រស) ។

ប៉ុំ. កិរិយាខ្ពើមក្រៃលែង ។

អតិព្បហិត គុ. ដែលខ្ពស់ក្រៃលែង ។

អតិពោធិសត្វ គុ. ដែលជាពោធិសត្វក្រៃលែង ។ ប៉ុំ ពោធិសត្វ

ក្រៃលែង ។

អតិព្រូ ឆាគុ. ពោលក្រៃលែង, ដេរ, ប្រទេច ។

(នៅមានត)

# រឿងសាមកុក

## កណ្ឌទី ៤៤

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ |
| អ្នកវាងវៃឆ្លាសបើបានអាន |
| នឹងបេះឧបាយកលបំណាន |
| ទាំងមានសន្តានស្នេហាជាតិ ។ |

ជីវយីឮដូច្នោះក៏ប្រឹក្សានឹងទាហានទាំងពួងថា អស់អ្នកយល់ឃើញដូចម្ដេច? ទាំងអស់គ្នាក៏ឆ្លើយថា ដែលឡោសុកឆ្លើយជំរាបលោកនោះត្រូវហើយ ជីវយីក៏ព្រមឲ្យឡោសុកទៅ ។

ឡោសុកក៏លាជីវយី នាំទាហានប្រហែល ១០ នាក់ ទៅឯស្រុកឡាំកុនជួបនឹងជូឡុង, ឡោសុកថា អ្នកចូលទៅជំរាបឡៅពីថា ខ្ញុំមានការមកជួប ជូឡុងថា ឥឡូវឡៅពីនឹងខុងបេងនាំគ្នាទៅនៅស្រុងកេងជីវហើយ ឡោសុកក៏នាំទាហានស្រូតទៅឯស្រុកកេងជីវ ឃើញទង់ដោតនៅលើសើនបន្ទាយជុំវិញ ឡោសុកក៏នឹកថា ជម្រះប្រាជ្ញាខុងបេងនេះជ្រៅឆ្ងាយណាស់កម្រនឹងរកបាន ហើយក៏ប្រាប់នាយទ្វារថា យើងត្រូវការ

ចូលទៅជួបនឹងឡៀពីនាយទ្វារ រួចក៏ចូលទៅដំកបតាមដំណើរ ខុងបេង ឲ្យបើកទ្វារទទួលឡោស៊ុកចូលទៅជួបនឹងខុងបេង ។ ក៏អញ្ជើញឲ្យទៅអង្គុយក្នុងទីដ៏សមគួរ តែឡៀពីនោះ ខុងបេងឲ្យនៅខាងក្នុង ឡោស៊ុកគំនាប់ខុងបេងហើយថា ដែលចូឆូលើកពលទាហានប្រហែល ១០០ ម៉ឺនមកនោះ មិនមែននឹងប៉ងធ្វើអន្តរាយបំពោះតែស្រុកកាំងតាំងប៉ុណ្ណោះក៏ទេ ចូឆូគិតប្រាថ្នានឹងចាប់យកខ្លួនឡៀពីជាតួដើមហេតុ វេលានោះស៊ុនគួននឹងជីវយីក៏មានចិត្តអាណិតឡៀពី ទើបច្រឹក្សាគ្នាយល់ព្រមឲ្យជីវយីលើកកងទ័ពចេញមកតទល់នឹងចូឆូ ប្រាថ្នានឹងជួយឡៀពីឲ្យរួចពីសេចក្ដីស្លាប់ ទាំងនឹងបានការពារក្សាស្រុកកាំងតាំងផង ដែលស៊ុនគួន-ជីវយីធ្វើការសង្គ្រាមគ្រានេះ លោកក៏ល្មមជ្រាបយល់ហើយ គឺថាការដែលធ្វើនោះ បានខាតបង់របស់ទ្រព្យសព្វសារពើគ្រប់មុខជាច្រើនណាស់ លុះទោយិន, ទោហាងបែកទ័ពទៅទៀត ស្រាប់តែលោកនឹងឡៀពីមកជ្រែកដណ្ដើមយកស្រុកកេងជីវ, ស្រុកសុងយ៉ុង, ស្រុកឡាំកុនដោយស្រួលទទេដូច្នេះ មិនសមគួរសោះ ខ្ញុំយល់ឃើញថាខុសនឹងប្រវេណី ទើបមកដំកបដើម្បីជាផ្លូវគៀនរំលឹកស្មារតីឲ្យលោកយល់ ។

ខុងបេងតបថា ខ្លួនអ្នកជាមនុស្សមានជម្រះប្រាជ្ញា គួរឬ ? មកនិយាយដូច្នេះ ឯស្រុក ៣ ដំបន់នេះ បើស្រុករបស់ចូឆូ ខ្ញុំក៏នឹងលើកទៅឲ្យស៊ុនគួនតែម្ដង មិនបាច់ចាំអ្នកមកគៀនគ្រេនដូច្នេះទេ តែថាគឺ

ស្រុកទាំង៣នេះ ជារបស់ឡៅតៀវអ្នកក៏ដឹងយល់ស្រាប់ថា ឡៅតៀវនឹងឡៅពីជាសាច់សាលោហិតនឹងគ្នា ទោះបើឡៅតៀវស្លាប់ទៅហើយក្តី ក៏មានឡៅគីជាបុត្រារស់នៅត្រូវតែទទួលមត៌ក បានជាខ្ញុំនឹងឡៅពីចំស្រុកមកជ្រែកយកស្រុកទាំង ៣ ដំបន់នេះ ទុកប្រយោជន៍ឲ្យឡៅគីតាមប្រវេណីពីបូរាណ ដែលអ្នកមកថាខ្ញុំឆ្លើយខុសនោះមិនបាន ឡោស៊ុកថា ស្រុកទាំង ៣ នេះ ជារបស់ឡៅតៀវក៏មែនហើយ តែថាឡៅគីជាបុត្រទៅឈរនៅឯស្រុកកាំងហែ នឹងបានមកនៅស្រុកទាំងនេះក៏ទេ ហេតុម្តេចបានជា
៧ លោកថាយកទុកឲ្យឡៅគីទៀត ខុងបេងថា អ្នកនឹងចង់ឃើញឡៅគីឬ? ឥឡូវឡៅគីឈឺហើយ ក៏ឲ្យមនុស្សគ្រាហ៍ឡៅគីចេញមក ឡៅគីក៏និយាយនឹងឡោស៊ុកថា ខ្ញុំសូម[illegible] ព្រោះខ្ញុំឈឺនឹងទៅគំនាប់គោរពនឹងលោកមិនកើត ហើយក៏ឲ្យគ្រាហ៍ខ្លួនទៅក្នុងវិញ ឡោស៊ុកក៏និយាយនឹងខុងបេងថា ដែលលោកបានប្រកាសមកមុននោះក៏ត្រូវហើយ តែបើឡៅគីមានអាយុរស់តទៅ ក៏ត្រូវបានស្រុកទាំងនេះជាជំនួសបិតា ចុះបើសិនណាឡៅគីស្លាប់ទៅវិញ លោកនឹងថាដូចម្តេច ខុងបេងថា បើសំណាងបុណ្យឡៅគីរស់នៅបានតែ ១ ថ្ងៃ ២ ថ្ងៃក្តី ខ្ញុំក៏ត្រូវតែជួយទំនុកបំរុងតាមការ បើអស់បុណ្យវាសនាឡៅគីទៅហើយ សឹមគិតតទៅទៀត ។

ឡោស៊ុកក៏ធ្វើមសួរបញ្ឆោតបញ្ចាក់ដោយចង់ដឹងច្បាស់ថា បើឡៅគី

អស់បុណ្យទៅហើយ លោកនឹងបង្វិលស្រុកដំបន់នេះឲ្យស៊ិនគួនឬ? ខុនបេងក៏ទទួលពាក្យបែបបន្ទំថាល្អហើយ ៗ ក៏អញ្ជើញឡោសុកឲ្យបរិភោគអាហារផឹកស្រាជាមួយគ្នា ឡោសុកលុះបរិភោគរួចហើយក៏លាខុនបេងត្រឡប់ទៅដល់បន្ទាយវិញ ហើយយកសេចក្តីទៅជំរាបដីវយីស្តាប់គ្រប់ប្រការ ដីវយីឮដូច្នោះក៏និយាយថា ឡោគីនោះនៅក្មេងនៅឡើយ កាលណានឹងដល់នូវសេចក្តីស្លាប់ឆាប់ ហេតុម្តេចអ្នកទៅប្រញាប់សន្យាដូច្នេះ ឡោសុកតបថា ឯខ្លួនឡោគីនោះក៏ឈឺធ្ងន់ណាស់ទៅហើយ សេចក្តីនេះខ្ញុំសុំកុំឲ្យលោកព្រួយចាំខ្ញុំ គិតយកស្រុកទាំង ៣ ដំបន់នេះ មកឡើងស្រុកកាំងតាំងឲ្យបាន ដីវយីថា អ្នកគិតឃើញយ៉ាងម្តេច បានជាថាដូច្នេះ ឡោសុកតបថា ឡោគីនោះនៅក្មេងក៏មែន តែចូលចិត្តផឹកស្រាលេងស្រីដែលបង្កើតកេតឈឺនោះព្រោះទោសទាំង ២ ប្រការនេះ ខ្ញុំយល់ឃើញថាអាយុឡោគីមិនយឺនទៅមុខដល់កន្លះឆ្នាំឡើយ បើស្លាប់កាលណាហើយខ្ញុំនឹងទៅទារយកស្រុកទាំង ៣ ដំបន់នេះឲ្យបានវិញ ៗ

ខណៈនោះមានបំរើសេះ កាន់សំបុត្រស៊ិនគួនមកឲ្យដីវយីសេចក្តីថា ស៊ិនគួនលើកទ័ពទៅធ្វើសង្គ្រាមឯស្រុកហ័បប៉ា បានតតាំងច្បាំងនឹងទៀវលៀវទាហានចូចួនៅមិនទាន់ចាញ់ឈ្នះ ឲ្យដីវយីរំលែកទាហានលើកទៅជួយនឹងបានធ្វើការតទៅ ដីវយីដឹងដូច្នោះ ក៏ចាត់ចែងបែងទាហានឲ្យទៀកៅជានាយកងលើកទៅជួយស៊ិនគួន ឯដីវយីក៏នៅដេកឈឺ ទើបលើក

កងទ័ព ត្រឡប់ទៅស្រុកឆសេងកុន ខាត់កំពង់ស្រុកកាំងតាំង ។

ឯឡេវពីកាលបានស្រុក ៣ ដំបន់ហើយ ក៏តាំងចិត្តគិតបំរុងរក្សាអាណាប្រជានុរាស្ត្រឲ្យបានសេចក្ដីសុខ លុះនៅមក ថ្ងៃ ១ ឡេវពីក៏ប្រឹក្សានឹងខុងបេងនូវអស់ទាហានទាំងពួងថា យើងនឹងរិះគិតប្រការម្ដេច ទើបនឹងរក្សាស្រុករកងជីវទុកបាន, ហើយនឹងបានគិតការទំនុកបំរុងផែនដីតទៅ ខុងបេងនឹងទាហានទាំងពួងនៅមិនទាន់ឆ្លើយថាប្រការម្ដេច អ៊ុីជៀឆ្លើយថា ខ្ញុំបាទសូមជំរាបលោកខ ១, ឡេវពីឮដូច្នោះក៏មានអំណរណាស់ ដោយគិតដល់គុណអ៊ុីជៀដែលបានប្រាប់ហេតុ កាលនៅស្រុកសុងយុងនោះ ឡេវពីក៏ចាប់ដៃអ៊ុីជៀឲ្យឡើងទៅអង្គុយជាក់ខាងលើហើយ សួរថាអ្នកនឹងប្រាប់ ខសេចក្ដីអ្វីដល់យើងក៏ឲ្យថាទៅចុះ អ៊ុីជៀឆ្លើយថា ខ្ញុំបាទដឹងថាកងផែនស្រុករកងជីវនេះមានសែម៉ានៅ ៥ នាក់ជាបងប្អូននឹងគ្នា ឯម៉ាបេកជាប្អូននោះ មានចិត្តដៃខ្លាំងពូកែណាស់ តែម៉ាលៀងជាបងមិនសូវខ្លាំងពូកែទេ តែមានជម្រះប្រាជ្ញាជ្រាលជ្រៅវៃវាង បើលោកយកបានមកទុកជាទីប្រឹក្សានឹងទាហាននឹងបានជួយជាកំឡាំងមាំមួនឡើងទៀត ឡេវពីឮដូច្នោះក៏ត្រេកអរណាស់ ទើបប្រើទាហានទៅហៅម៉ាលៀងមកជួប ហើយឲ្យអង្គុយទីសមគួរ ក៏គំនាប់គ្នាទៅវិញទៅមក ឡេវពីនិយាយថា ផែនដីសព្វថ្ងៃនេះកើតកែវរៃចលាចលផ្សេងៗ យើងគិតនឹងទំនុកបំរុងឲ្យបានសេចក្ដីសុខរក្សាមកក្សត្រ បានជាជួបមករកទៅក្នុងស្រុករកងជីវនេះ ប្រាថ្នានឹង

រិះគិតការតទៅ ផែ្តយើងនៅព្រួយចិត្តដ្បិតនឹងគិតការពារប្រការម្តេច ទើបនឹងបានឲ្យអាណាប្រជាពន្ធុរាស្ត្របានសេចក្តីសុខ ម៉ាលៀងឆ្លើយថា ឯកេងជីវនេះជាមុខសឹកសង្គ្រាមគ្រប់ទាំង ៤ ទិស កម្រដែលនឹងគិតការពាររក្សាឲ្យបានស្រួល គួរលោកតាំងឡៅតីឲ្យធ្វើចៅហ្វាយស្រុកកេងជីវជាបណ្តោះអាសន្ន ហើយពន្យល់ឲ្យទៅបញ្ចុះបញ្ចូលមនុស្សខ្ញុំរាជការចាស់របស់ឡៅពៀវឲ្យចូលមកប្រមូលគ្នាជាសេនាទាហានឲ្យច្រើន ទើបរាស្ត្រទាសទាំងពួងនឹងបាននៅជាសុខតាមប្រក្រតី ព្រោះឃើញថាឡៅតីជាចៅហ្វាយស្រុកកេងជីវស្រាប់ហើយ ទើបឲ្យវាត់កងទ័ពទៅវាយយកស្រុកខាងទិសទក្សិណដែលឡើងដល់ស្រុកកេងជីវនេះ គឺស្រុកប៉ិឡេង, ស្រុកទៀងសា, ស្រុកហ៊ុយអៀង, ស្រុកឡេងឡេង, ទាំង ៤ ដំបន់នេះសឹងប្រកបដោយមាសប្រាក់ នឹងស្រូវអង្ករចំណីត្រីសាច់បរិបូណ៌ណាស់បើបានហើយនឹងជួយជាកំឡាំងតទៅ ។

ឡៅតីក៏សួរថា អ្នកនឹងឲ្យយើងទៅវាយយកស្រុកណាជាមុន ម៉ាលៀងឆ្លើយថា សុំឲ្យរៀបកងទ័ពលើកទៅវាយយកស្រុកឡេងឡេងជាមុនព្រោះជាដើមផ្លូវ ហើយទើបវាយយកស្រុកប៉ិឡេងជាបន្ទាប់ ឯស្រុកទៀងសា នឹងស្រុកហ៊ុយអៀងនោះនៅខាងទិសឯលិច ឲ្យលើកទៅវាយជាក្រោយក៏បាន ឡៅតីយល់ឃើញផង ទើបតាំងឲ្យម៉ាលៀងជាទីប្រឹក្សាឲ្យឡៅតីជាចៅហ្វាយស្រុកកេងជីវ តែឲ្យទៅនៅស្រុកសុងយ៉ុង នឹងបាន

បញ្ចុះបញ្ចូលមនុស្សឡេវតៀវទុកជាកំឡាំង ហើយឡេវពីក៏ប្រឹក្សានឹងខុងបេងនូវអស់ទាហានទាំងពួងតាមពាក្យម៉ាលៀង ខុងបេងក៏យល់ត្រូវផង ឡេវពីក៏ឲ្យហៅគួនព្រៀមកពីស្រុកស៊ិនយ៉ុង ឲ្យមកនៅរក្សាស្រុកកេងជីវ ហើយឡេវពីក៏ប្រមូលទាហានបាន ១ ម៉ឺន ៥ ពាន់ ឲ្យតឿវហ៊ុយជាកងមុខ ខ្លួនឡេវពីនឹងខុងបេងជាកងល្អង ជូឡុងជាកងក្រោយ ហើយក៏លើកទ័ពទៅតាំងនៅជិតស្រុកឡេងឡេង ៗ

ឯឡេវតៅបៅហ្វាយស្រុកឡេងឡេង លុះដឹងថាឡេវពីលើកកងទ័ពមក ក៏ប្រឹក្សានឹងឡេវហៀនជាបុត្រថា ឡេវពីលើកកងទ័ពមកទីងច្បាំងយកស្រុកយើង តើនឹងរិះគិតប្រការម្ដេច? ឡេវហៀនឆ្លើយថា ពួលបី, គេនិយាយថា ឡេវពីមានទាហានឯកឈ្មោះទៀវជូឡុងមានថ្វីដៃខ្លាំងពូកែណាស់ តែកូនទាហានមានតិច ឯស្រុកយើងនេះគុះអេងក៏ជាទាហានឯក ស៊ូទីងពលបាន ១ ម៉ឺន នឹងខ្លាចអ្វីដល់ឡេវពីនោះ ខ្ញុំបាទនឹងសុំយកការសារចេញទៅពយឲ្យបែកទាល់តែបាន ៗ

ឡេវតៅបានឮដូច្នោះក៏ពេញចិត្ត ទើបចាត់ទាហានឲ្យឡេវហៀនចំនួន ១ ម៉ឺន ឡេវហៀនក៏លាបិតាឡើងសេះនាំទាហានចេញទៅ ចម្ងាយផ្លូវប្រហែល ១០០ សិន (៤ គី) ទើបឲ្យតាំងបន្ទាយនៅជើងភ្នំ ១ ៗ ខុងបេងឃើញកងទ័ពស្រុកឡេងឡេងលើកចេញមក ក៏ឡើងជិះរទេះកាន់ក្លុកពេបសត្វមានទង់លឿងដោតលើរទេះ ១ ហើយនាំទាហានចេញទៅ

ដល់មុខបន្ទាយ គុះអេងឃើញដូច្នោះក៏ឡើងសេះកាន់ពូថៅធំលើកទាហានចេញមកហើយស្រែកថា អាពួកចោរ ហេតុម្តេចបានជាហ៊ានលើកទ័ពកងចូលមកក្នុងដែនស្រុករបស់ចៅហ្វាយអញ ឯងមិនខ្លាចស្លាប់ទេឬ? ខុងបេងឮដូច្នោះក៏ឆ្លើយតបថា ខ្លួនអញឈ្មោះខុងបេងនៅដែនស្រុកឡុំ-យ៉ុង គ្រាដែលចូឆូលើកពល ១០០ ម៉ឺន ជាក្បួនទ័ពគោកទ័ពទឹកមកនឹងវាយយកខែត្រខណ្ឌខាងទិសទក្សិណនេះ អញគិតកលឧបាយតែ ខ ១ ក៏ដុតកងទ័ពចូឆូបានទាំងទ័ពគោកទ័ពទឹក ដែលចៅហ្វាយអញលើកកងទ័ពមកនេះ បើឯងព្រមអង្វរលន់តួដោយល្អក៏នឹងរួចជីវិត ៗ

គុះអេងបានឮដូច្នោះក៏ខឹងណាស់ឆ្លើយថា អញដឹងឯងហើយ ឯងកុំអួតអាងអ្វីឡើយ កាលចូឆូបែកទ័ពទៅនោះ ព្រោះគំនិតរបស់ជីវយីទេ ហើយបរសេះចូលដេញចូលទៅនឹងចាប់ខ្លួនខុងបេង ៗ ក៏ប្រើអ្នកបររទេះឲ្យថយរទេះត្រឡប់ក្រោយ គុះអេងក៏បរសេះដេញទៅដល់ជើងកំពែង ឃើញទង់លឿងដែលដោតលើរទេះនោះ កំបាំងបាត់ទៅក្នុងកៀនភ្នំ ឃើញឯទៀវហ៊ុយបរសេះពំលំពែងចេញមកស្រែកថា ខ្លួនអញឈ្មោះទៀវហ៊ុយ ឯងអាចមកតស៊ូនឹងដៃអញឬ? គុះអេងឮដូច្នោះក៏ខឹងណាស់ បរសេះចូលទៅប្រយុទ្ធនឹងទៀវហ៊ុយមិនបានក៏បំផាយសេះរត់ទៅ ទៀវហ៊ុយក៏ដេញជិតតាមពីក្រោយ គុះអេងខំស្រូតៈទៅដល់មាត់ផ្លូវ ទទួលឮសំឡេងស្រែកហោអឺងកងឡើង ហើយឃើញទាហានសន្ធាំងផ្លូវចេញមកស្ទាក់ពីមុខ

ដូច្នេះស្រែកថា អញឈ្មោះដូច្នេះ មកចាំយកជីវិតឯងហើយ ៗ ក៏ដេញទាហានឲ្យព័ទ្ធឡោមជុំវិញ តុះអេងទាល់ច្រកនឹងរកផ្លូវចៀសទៅមិនរួច ក៏ចោលពូថៅចុះពីដៃ ហើយលោតចុះពីលើខ្នងសេះបួលមកគំនាប់ដូច្នេះ ៗ ក៏ឲ្យទាហានចងតុះអេងជាប់ ហើយនាំយកខ្លួនទៅជូនឡៅពីក្នុងបន្ទាយ ឡៅពីក៏បង្គាប់ឲ្យយកខ្លួនតុះអេងទៅសម្លាប់ចេញ ខុងបេងដឹងដូច្នោះក៏ហាមឃាត់ឡៅពីឲ្យបង្អង់ ហើយសួរពិចារណាតុះអេងថា បើខ្លួនអ្នកឯងព្រមនៅនឹងចៅហ្វាយ យើង ៗ នឹងលែងឲ្យរួចខ្លួនទៅវិញ ហើយត្រូវខំរិះគិតយកខ្លួនឡៅហៀនមកឲ្យយើងនឹងបាន ឬ មិនបាន ? តុះអេងក៏ថា បើលោកទុកជីវិតខ្ញុំបាទហើយ ខ្ញុំបាទនឹងរិះគិតយក, ខ្លួនឡៅហៀនមកជូនលោកឲ្យទាល់តែបាន បើលោកបានខ្លួនឡៅហៀនក៏ដូចជាខ្លួនឡៅគៅជាបិតាដែរ ៗ

ខុងបេងសួរថា អ្នកឯងនឹងទៅគិតធ្វើប្រការម្តេចនឹងបានឡៅហៀននោះ? តុះអេងថា ពេលយប់ក្នុងថ្ងៃនេះ ឲ្យលោកលើកកងទ័ពទៅប្លន់បន្ទាយឡៅហៀនចុះ ខ្ញុំបាទនឹងធ្វើជាកលសឹកខាងក្នុង ចាប់យកខ្លួនឡៅហៀនមកជូនលោក ឡៅពីឮដូច្នោះក៏និយាយនឹងតុះអេងថា ពាក្យនេះយើងយល់ឃើញថាមិនមែនទេ គឺអ្នកឯងកែងយកតែជីវិតឲ្យរស់ ៗ ខុងបេងថា តុះអេងនេះជាមនុស្សមានពាក្យសត្យពិតត្រង់ណាស់ ល្មមនឹងជឿស្តាប់បាន ហើយក៏ឲ្យស្រាយចំណងចេញលែងទៅ តុះអេងលុះទៅ

ដល់បន្ទាយក៏ពណ៌នាសេចក្ដីទាំងពួងឲ្យឡៅហៀនស្ដាប់គ្រប់ប្រការ ។

ឡៅហៀនថា យើងនឹងរិះគិតប្រការម្ដេចទើបស្រួល? គុះអេងថា លោកកុំវិតក្កជាទុក្ខព្រួយឡើយ ខ្ញុំបាទនឹងគិតកែវឲ្យបាន ក្នុងថ្ងៃនេះ ទាហានឡៅពីនឹងលើកមកតាមពាក្យខ្ញុំបាទនិយាយ យើងត្រូវតែលះបង់ចោលបន្ទាយនេះចេញ ហើយលើកទាហានចេញទៅពួនបង្កប់ខាងក្រៅបន្ទាយជា ២ កង បើឃើញទាហានឡៅពីលើកមកយើងនឹងលើកចេញមកវាយខ្ទប់ទាំងសង្ខាង ឡៅហៀនយល់ឃើញត្រូវ ក៏ឲ្យធ្វើតាមពាក្យគុះអេង លុះវេលាយាម ២ បាយ ឃើញទាហានឡៅពី ១ កងកាន់គប់ចម្បើងគ្រប់ដៃ លបទៅដុតបន្ទាយនេះឡើង ឡៅហៀននឹងគុះអេងក៏លើកទាហានវាយខ្ទប់ទាំងសង្ខាងចូលមក ពួកទាហានឡៅពីក៏លបរត់ទៅ ឡៅហៀននឹងគុះអេងតាមទៅមិនទាន់ក៏វិលត្រឡប់មកជិតដល់បន្ទាយវិញ ភ្លើងនោះក៏ឆេះភ្លឺខ្លាំងឡើង ក្រឡេកមើលទៅឃើញទៀវហ៊ុយជិះសេះមកឈរស្កាត់ពីមុខ ។

ឡៅហៀនក៏និយាយនឹងគុះអេងថា ឡៅពីលើកទ័ពមកលុកបន្ទាយយើង តែទាហានដែលនៅក្នុងបន្ទាយឡៅពីនោះស្ងួតស្ងៀមណាស់ បើយើងនឹងលើកទៅប្លន់យកបន្ទាយឡៅពីវិញក៏នឹងបានដោយងាយ គុះអេងយល់ឃើញត្រូវ ក៏លើកទៅប្លន់យកបន្ទាយឡៅពី លុះលើកទៅដល់ពាក់កណ្ដាលផ្លូវ ក៏ប្រទះនឹងជូឡុងលើកទាហានមកស្កាត់ពីមុខ ជូឡុង

កំបរសេះពុះទំលាយយកកងទ័ពសម្លាប់ទាហានទន្ទ្រានចូលទៅ ហើយ
យកលំពែងចាក់ត្រូវតុះអេងធ្លាក់ពីលើសេះស្លាប់ ឡេវហៀនឃើញដូច្នោះ
ក៏តក់ស្លុតកន្លងចិត្តបំផាយសេះរត់ទៅជួបនឹងទៀវហ៊ុយ ។ ចូលតច្បាំងហើយ
ក៏ព័ទ្ធចាប់ឡេវហៀនបាន ចងយកខ្លួនទៅឲ្យខុងបេង ខុងបេងក៏ពិចារ-
ណាសួរឡេវហៀនថា យើងចាប់តុះអេងបាន ហើយ យើងដោះលែង
ទៅវិញ ក៏ត្រឡប់គិតប្រទូសរ៉ាយបញ្ឆោតយើងដោយអំពើទុច្ចរិត ឡេវ
ហៀនថា ដែលតុះអេងធ្វើការបញ្ឆោតលោកនោះ ជាតម្រិះរិះគិតរបស់
តុះអេងខ្លួនឯង ៗ ខុងបេងក៏ឲ្យស្រាយចំណងឡេវហៀនចេញ ហើយ
យកអាវព្រៃយ៉ាងល្អឲ្យឡេវហៀនពាក់ រួចហៅឲ្យឡើងតុបរិភោគអា-
ហារ ហើយថា យើងនឹងបើកលែងអ្នកឯងឲ្យទៅទៀត ដើម្បីឲ្យទៅប្រាប់
បិតារបស់អ្នកឯងឲ្យចេញមកលន់តួបំណុះចុះចូលយើង ដោយសុភាពល្អ
បើអ្នកឯងទៅហើយមិននាំបិតាចេញមកទេ យើងនឹងលើកទ័ពចូលទៅ
វាយយកស្រុក ហើយនឹងកាប់សម្លាប់គ្រប់គ្រួសារនូវបណ្ដាញាតិបងប្អូន
ឲ្យអស់កុំឲ្យសល់ ។

(ទៅមានត)

## រឿងមនុស្សចិត្តប្រែប្រួល

## យុងបណ្ណាគារកុះ ប៊ូ-ប៉ូ រៀបរៀង

ថ្ងៃមួយ អ្នកកើត នាងរស់ បរិភោគបាយល្ងាចរួច អង្គុយនិយាយគ្នាអំពីរបរចិញ្ចឹមជីវិតរាល់ថ្ងៃ ។ នាងរស់ជាប្រពន្ធសួរអ្នកកើតជាប្តីថា យើងគិតដូចម្តេចអំពីដីចម្ការយើង ១ ក្បាល នៅឃុំថ្មគ ស្រុកល្វាឯម ខែត្រកណ្តាល យើងដាំពោតខ្លួនឯងទៀត ឬក៏ជួលដីនោះឲ្យគេធ្វើទៅក្នុងឆ្នាំថ្មីខាងមុខនេះ ? ។

អ្នកកើត- យើងធ្វើដីនោះខ្លួនឯងមិនបានទេ ព្រោះដីនៅឆ្ងាយពីផ្ទះយើងក្នុងឃុំកោះរះនេះផង យើងកាន់តែចាស់ណាស់ហើយ លំបាកដើរទៅដើរមកណាស់ផង ជួលឲ្យគេធ្វើវិញទៅស្រួលជាង ។

នាងរស់- ខ្ញុំគិតឃើញថា កុំជួលឲ្យគេអីវាខាតណាស់ ព្រោះចម្ការនោះខ្លាញ់ ដាំពោតមួយឆ្នាំ ៗ បានផលច្រើន យើងឲ្យ ដីប្រែ ទៅធ្វើម្នាក់វាចុះ ដ្បិតវាឈប់រៀនហើយ គ្រាន់នឹងផ្សងផ្សំប្រាក់ទុករកប្រពន្ធឲ្យវា ដ្បិតវាពេញកម្លោះហើយ ។

អ្នកកើត- ទេ ! អញមិនឲ្យ ដីប្រែ ទៅធ្វើចម្ការទេ ឲ្យវាទៅធ្វើរដ្ឋការឯភ្នំពេញវិញ គ្រាន់បានប្រាក់ខែចិញ្ចឹមប្អូនវាតូចៗ បីនាក់ផង ចិញ្ចឹមយើងចាស់ៗ ធ្វើការលែងកើតផង ។

នាងរស់- បើដូច្នោះ, ស្រេចលើគំនិតគាត់ចុះ ខ្ញុំមិនដឹងទេ តែ

ខ្ញុំយល់ថា ជីប្រែ វាធំហើយ មិនត្រូវបណ្ដោយឲ្យវានៅឆ្ងាយពីខ្លួនទេ ដ្បិតចាស់ទុំលោកថា ចិត្តមនុស្សបុថុជ្ជនគ្រប់រូបតែងតែប្រែប្រួល ម្ដងគិតឃើញយ៉ាងនេះ ម្ដងគិតឃើញយ៉ាងនោះ មិននៅទៀងតែម្យ៉ាង ៗ ទេ ។

អ្នកតាកើត ឯងយល់យ៉ាងនេះគួរហើយ ប៉ុន្តែត្រូវហៅវាមកសួរឲ្យដឹងចិត្តគំនិតវាសិន តើវាចូលចិត្តយ៉ាងណា ។

ជាងរស់–ហៅ ជីប្រែ មកជិតសួរថា តាំងពីឯងឈប់រៀនមករវាង ២ ខែហើយ ឯងមានគំនិតគិតទុកដូចម្ដេចដែរឬទេ ? ។

ជីប្រែ– បាទ ! ខ្ញុំគិតខ្លះដែរ ម៉ែ ! គិតថាខ្ញុំឈប់រៀនហើយ ត្រូវមកនៅផ្ទះជួយធ្វើចម្ការម៉ែ ។

ជាងរស់– អើ ! បើឯងចូលចិត្តធ្វើចម្ការក៏ធ្វើចុះ, ប៉ុន្តែ ខ្លួនឯងពេញកម្លោះហើយ ល្មមគិតរកប្រពន្ធ បើឯងពេញចិត្តកូនចៅអ្នកណា ប្រាប់ម៉ែចុះ ម៉ែនឹងទៅស៊ើបសួរស្ដីដណ្ដឹងគេទុកឲ្យឯង ។

ជីប្រែ–ម៉ែ! កុំគិតគូពីរឿងប្រពន្ធកូនអី ខ្ញុំមិនព្រមយកប្រពន្ធទេ ។

ជាងរស់– ម៉េចក៏ឯងថាដូច្នោះ ? កើតមកជាប្រុសត្រូវតែមានប្រពន្ធ កើតមកជាស្រីត្រូវតែមានប្ដី ទើបសមគួរតាមទម្លាប់អ្នកស្រុកដូចពាក្យចាស់ទុំលោកថា ចូលស្ទឹងតាមបត់ ចូលស្រុកតាមប្រទេស ។ បើឯងមិនយកប្រពន្ធទេ ម៉េចក៏ឯងមិនទៅបួសនៅក្នុងវត្តដូចលោកសង្ឃទៅ ។

ដីប្រែ - ទេ ! ខ្ញុំមិនបួសទេ ព្រោះខ្ញុំចង់មកនៅផ្ទះជួយធ្វើរបរម៉ែ ។

ធានំរស់ - បើឯងមិនបួសទេ ត្រូវតែឯងយកប្រពន្ធខានមិនបាន កុំឲ្យខុសពីអ្នកស្រុក បុះឯងគិតឃើញដូចម្តេចបានជាមិនព្រមយកប្រពន្ធ ប្រាប់ម្តាយផង ម្តាយឆ្ងល់នឹងចិត្តឯងណាស់ ។

ដីប្រែ— ខ្ញុំមិនដែលទុកចិត្តស្និទ្ធស្នាលនឹងស្រីណាទេម៉ែ ! ប៉ុន្តែ កាលខ្ញុំកំពុងរៀនក្នុងសាលា នោះ លោកគ្រូនិទានពីរឿងស្រីឲ្យខ្ញុំស្តាប់ ខ្ញុំក៏ចាប់ខ្លាចស្រីតាំងពីពេលនោះមក គិតថាលែងយកប្រពន្ធមួយជាតិ ។

ធានំរស់ បុះលោកគ្រូឯងនិទានពីរឿងស្រីថាម៉េចខ្លះ ឯងដំ-ណាលឲ្យម៉ែស្តាប់ផងមើល ? ។

ដីប្រែ— ម៉ែចាំស្តាប់ខ្ញុំដំណាលពីរឿងស្រីដែលមានពុតត្បុតចិត្ត មិនស្មោះត្រង់នឹងប្តី សូម្បីប្តីស្រឡាញ់ខ្លាំងណាស់ ស្ទើរតែលេបទៅទុកក្នុងពោះហើយ ក៏នៅតែប្រែចិត្តក្បត់ប្តី ទៅលួចសហាយស្មន់នឹងប្រុសដទៃទៀតដូចជា ៖

## ១– រឿងស្រីក្នុងស្មុគ្រ(១)

កាលពីព្រេងនាយ ព្រះពោធិសត្វលះបង់ទ្រព្យសម្បត្តិចេញបួសជាតាបសឫសី បានសម្រេចឈានអភិញ្ញាសមាបត្តិជាលោកិយ គង់នៅក្នុងព្រៃហិមពាន្ត ។

---

១- សមុគ្គជាតក ក្នុងនិបាតជាតក របស់ព្រះពុ ស. សៀវភៅលេខ ឬ ១/១០ ។

គ្រានោះ មានយក្សម្នាក់នៅក្នុងព្រៃជិតអស្រមរបស់តាបស តែង
ចូលទៅស្ដាប់ធម៌តាបសជារឿយ ៗ លុះស្ដាប់ធម៌រួចហើយ ទៅឈរនៅ
ត្រង់ផ្លូវបំបែក ដែលមនុស្សដើរកាត់ទៅមកតាមដងព្រៃនោះ បើបាន
ឃើញមនុស្សណា ក៏ចាប់អ្នកនោះបរិភោគជាអាហារ ។ ថ្ងៃមួយ មាននាង
កុលធីតាម្នាក់រូបរាងល្អស្អាតបាតកំពុងពេញក្រមុំ នៅស្រុកមួយក្នុងដែន
កាសី នាងនាំពួកបរិវារទៅសួរមាតាបិតាឯនគរពារាណសី យាត្រាកាត់
ព្រៃទៅតាមផ្លូវដែលយក្សនៅចាំស្កាត់នោះ ខ្លួននាងជិះលើរទេះគោ ឯពួក
បរិវារដើរពីមុខរទេះខ្លះ ពីក្រោយរទេះខ្លះ ។ យក្សក្រឡេកឃើញនាងបរ
រទេះទៅដល់កន្លែងនោះ ក៏ក្រឡាខ្លួនយ៉ាងធំសំបើមគួរឲ្យខ្លាច រត់ដេញ
តាមរទេះ ។ ពួកបរិវារមើលទៅឃើញយក្សធំណាស់ ដេញពីក្រោយ
ក៏កិតភ័យយ៉ាងខ្លាំង នាំគ្នារត់បោលនាងកុលធីតាអស់ ។ នាងកុលធីតា
នៅក្នុងរទេះតែម្នាក់ឯង ។ យក្សដេញតាមទាន់ហើយ ឃើញនាងរូបល្អ
ស្អាតក៏ចាប់ចិត្តស្រឡាញ់ ទើបនាំយកនាងទៅឯគោហាល់នៅខ្លួនទុកធ្វើ
ជាភរិយារួមសង្វាសជាមួយគ្នារៀងមក ។ យក្សស្រឡាញ់នាងកុលធីតា
នោះណាស់ ខំស្វះស្វែងដណ្ដើមយកសំពត់អាវអាហារគោជន និងគ្រឿង
មាសពេជ្រពីមនុស្សអ្នកដំណើរ មកឲ្យប្រពន្ធបរិភោគប្រើប្រាស់ មិន
ហ៊ានឲ្យខ្វះខាត បើប្រពន្ធបង្គាប់ឲ្យធ្វើដូចម្ដេច ចេះតែធ្វើតាមទាំងអស់
មិនប្រកែកឲ្យទាស់ចិត្តប្រពន្ធទេ បើចេញទៅទីណាឆ្ងាយពីគោហា តែង

យក្សប្រពន្ធជាប់ទៅជាមួយផង មិនហ៊ានទៅចោលប្រពន្ធទេ ខ្លាចគេមកលួចស្រឡាញ់ប្រពន្ធ ៗ យក្សគិតថា កុំឲ្យលំបាករក្សាប្រពន្ធពេកត្រូវអញលេបទុកក្នុងពោះទើបស្រួលទៅណាមកណា កុំឲ្យប្រពន្ធឃើញប្រុសដទៃ ក្រែងស្រឡាញ់គេចោលខ្លួន ៗ ថ្ងៃមួយ យក្សរកបានស្គុ ១ យកមកឲ្យប្រពន្ធចូលទៅនៅក្នុងស្គុ ហើយលេបស្គុនោះទៅទុកក្នុងពោះ ៗ

ខាងក្រោយមក យក្សទៅងូតទឹកឯស្រះ លុះទៅដល់មាត់ស្រះហើយ យក្សខ្វាក់ស្គុពីក្នុងពោះចេញក្រៅ ហើយដឹកដៃប្រពន្ធឲ្យចុះងូតទឹកក្នុងស្រះដុះលាងខ្លួនប្រាណឲ្យប្រពន្ធស្អាតបាតហើយ នាំប្រពន្ធមកឲ្យអង្គុយលើមាត់ស្គុគ្រសិតសក់លាបប្រេងម្សៅនៅក្រៅស្គុ ឲ្យត្រូវខ្យល់អាកាសបន្តិច ៗ យក្សគយគន់មើលនាយអាយ មិនឃើញមានប្រុសណាម្នាក់នៅក្បែរស្រះនោះសោះ ក៏ផ្តាំប្រពន្ធឲ្យអង្គុយចាំ ហើយចុះទៅងូតទឹកស្រះ ងូតបណ្តើរក្រឡេកមើលមកប្រពន្ធបណ្តើរ ខ្លាចក្រែងប្រពន្ធដើរទៅណា លុះឃើញប្រពន្ធអង្គុយស្ងៀមលើមាត់ស្គុហើយ ក៏អស់សង្ស័យ ទើបមុជទឹកហែលលេងទៅឆ្ងាយពីប្រពន្ធបន្តិច ៗ

ជួនជាគ្រានោះ មានពិទ្យាធរម្នាក់សៀតព្រះខាន់នៅចង្កេះហោះឯអាកាស មកជិតកាត់រំលងលើក្បាលនាងប្រពន្ធយក្ស ៗ នាងក្រឡេកឃើញបក់ដៃហៅពិទ្យាធរឲ្យចុះមក ដោយចិត្តនាងល្មោភនឹងកាមគុណ

ខ្ទាំង ៗ ពិទ្យាធរដឹងអាការនាងនោះ កំចុះមកក្តាមបំបាំងខ្លួននឹងស្ត្រគ សម្រេចកិច្ចស្រេចហើយ នាងឲ្យពិទ្យាធរចូលទៅពួនសម្ងំក្នុងស្ត្រគ រួចនាងអង្គុយលើមាត់ស្ត្រគបែរមុខមើលទៅយក្សប្តីធ្វើបុកព្រះងើយ លុះនាងឃើញយក្សឡើងពីទឹកដើរមកជិតឃើញខ្លួននាងច្បាស់ហើយ នាងកំចូលក្នុងស្ត្រគអង្គុយសង្កត់លើពិទ្យាធរ យកសំពត់ដណ្តប់គ្របជិតខ្លួនមិនឲ្យយក្សឃើញពិទ្យាធរ ៗ យក្សមកដល់ក្នុងទឹកសង្ស័យឃើញបន្ថិចនោះ សំគាល់ថាប្រពន្ធបរិសុទ្ធណាស់នៅក្នុងស្ត្រគតែម្នាក់ឯងគត់ កំចាប់គ្របស្ត្រគបិទជិតហើយលេបទៅទុកក្នុងពោះខ្លួនទៅ រួចដើរត្រឡប់មកលំនៅខ្លួនវិញ លុះមកដល់ជិតអស្រមតាបសគិតថា អញបានចូលទៅជួបសាប់ធម៌តាបសជាយូរថ្ងៃហើយ ព្រោះរវល់ខ្វល់តែស្រឡាញ់ប្រពន្ធ ពេលនេះគួរតែអញចូលទៅសួរសុខទុក្ខលោកម្តង គិតហើយកំដើរដប្រង់ចូលទៅរកតាបស ៗ

ចំណែកតាបសគង់នៅក្បែរទ្វារអស្រម ក្រឡេកឃើញយក្សដើរចូលទៅពីចម្ងាយ កំជ្រាបច្បាស់ថា យក្សនេះលេបមនុស្សស្រីម្នាក់នឹងពិទ្យាធរប្រុសម្នាក់ទុកក្នុងពោះ ទើបស្រែកសួរទៅយក្សថា នែអ្នកទាំងបី អ្នកដើរនាំគ្នាមកពីណា ម៉េចក៏បាត់យូរម្ល៉េះ? អ្នកទាំងបីចូលមកអង្គុយឯណេះសិន ៗ យក្សឮតាបសស្រែកសួរខ្លួនដូច្នោះនឹកងឿងណាស់ថា ខ្លួនក្បួរដើរមកតែម្នាក់ឯងគត់ [illegible] តាបសនេះ សួរថាអ្នក [illegible] ម្តង ៗ

ឲ្យរួចពីមាត់ទៅទេ គិតហើយដើរចូលទៅដល់ក្រាបថ្វាយបង្គំទូលសួរថា បពិត្រព្រះករុណា! លោកម្ចាស់សួរថាអ្នកទាំងបីមកពីណាដូច្នេះ តើសួរអ្នកណា បើខ្ញុំព្រះករុណាមកតែម្នាក់ឯងគត់យ៉ាងនេះ? តាបសឆ្លើយថា បើអ្នកចង់ដឹងរឿងអាត្មានឹងប្រាប់អ្នក, ចូរអ្នកប្រុងស្តាប់ចុះ ទើបតាបសប្រាប់ថា ខ្លួនអ្នកឯងម្នាក់, ប្រពន្ធសំឡាញ់ក្នុងស្នគ្រដែលអ្នកឯងលេបទៅលាក់ទុកក្នុងពោះម្នាក់, ពិទ្យាធរឈ្មោះវាយុបុត្រ ជាសហាយរបស់ប្រពន្ធអ្នកនៅជាមួយគ្នាក្នុងស្នគ្រម្នាក់ទៀត ជាគំរប់បីនាក់, ខ្លួនអ្នកតាំងចិត្តថា អញនឹងរក្សាការពារប្រពន្ធ កុំឲ្យមានប្តីច្រើនក្នុងស្នគ្រ ហើយមិនហ៊ានទុកខាងក្រៅលេបទៅលាក់ក្នុងពោះ បែរជាលេបទាំងប្រុសសហាយរបស់ប្រពន្ធឲ្យទៅនៅជួបគ្នាក្នុងពោះទៀត ។

យក្សបានឮតាបសប្រាប់ដូច្នោះ តក់ស្លុតណាស់គិតថា ធម្មតាពួកពិទ្យាធរជាអ្នកមានគិចកលមាយាច្រើន បើប្រសិនជាវាមានកាំបិតឬព្រះខាន់ជាប់ទៅនៅដៃផង មុខជាវាចាក់វះពោះអញរត់ចេញទៅ អញនឹងស្លាប់មិនខាន គិតខ្លាចយ៉ាងនេះហើយ ក៏ខ្ជាក់ស្នគ្រចេញមកក្រៅវិញភ្លាម ដាក់នៅមុខតាបស ហើយបើកគ្របស្នគ្រឡើងមើល ក៏ឃើញពិទ្យាធរនៅក្នុងស្នគ្រជាមួយប្រពន្ធ ។ ឯពិទ្យាធរគ្រាន់តែយក្សបើកគ្របស្នគ្រភ្លាម ក៏កាន់ព្រះខាន់ស្ទុះ សាកមន្តគាថាហោះហើរទៅតាមអាកាសបាត់ទៅ [illegible] ព្រៃ [illegible] ហោះ [illegible]

ÉCOLE FRANÇAISE D'EXTRÊME-ORIENT BIBLIOTHÈQUE P.P.+

ត្រូវណាស់ និយាយសរសើរគុណតាបសថា លោកម្ចាស់ជាអ្នកប្រព្រឹត្តធម៌ដ៏ខ្ពង់ខ្ពស់ បានជាមានប្រាជ្ញាមោះមុតរាបជ្រាបរាប់ពីកំបាំងល្អិតសុខុមបែបនេះបានយ៉ាងច្បាស់លាស់ ឯខ្ញុំព្រះករុណាជាមនុស្សប្រព្រឹត្តអាក្រក់ បានជាគ្មានប្រាជ្ញាមិនដឹងកិរិយាប្រពន្ធក្នុងពោះក្បត់ចិត្តលួចមានសហាយ ព្រោះខ្ញុំព្រះករុណាវង្វេងស្មារតី ទៅក្នុងអំណាចកាមគុណខ្លាំងណាស់ នាំឲ្យវង្វេងដល់ម្ល៉េះ ស្រឡាញ់ប្រពន្ធស្មើជីវិតទាល់តែលេបទៅលាក់ទុកក្នុងពោះខ្លួន តែបែរជាប្រពន្ធនោះក្បត់ចិត្តគិតប្រទូសរ៉ាយខ្លួនវិញ ទៅត្រេកត្រអាលនឹងប្រុសដទៃ គិតសម្លាប់ប្ដីដែលចិញ្ចឹមរក្សាពល់ថ្ងៃ កុំតែបានលោកម្ចាស់ប្រាប់រឿងនេះឲ្យដឹង កុំអីខ្ញុំព្រះករុណាស្លាប់ខឹងដៃពិទ្យាធរមិនខាន, គួរឲ្យស្ដុតចិត្តណាស់! ប្រុសណាប្រាថ្នាឲ្យបានសេចក្ដីសុខចំរើនដល់ខ្លួន ប្រុសនោះត្រូវតែប្រុងប្រយ័ត្នពីរឿងស្រឡាញ់ស្រីឲ្យណាស់ កុំនៅប្រទូកប្រឡូកនឹងស្រី ព្រោះថាបើដក់ចិត្តស្រឡាញ់ស្រីជ្រុលពេកហើយ មុខជាខូចចំណេះវិជ្ជា, ខាតលាភសក្ការៈ, ឬធ្លាក់បុណ្យសក្ដិមិនខាន ។

តាបសឆ្លើយថា នែយក្ស! អ្នកថាដូច្នោះមិនត្រូវសព្វគ្រប់ទេ ដ្បិតប្រុសក្ដី ស្រីក្ដី មានល្អមានអាក្រក់ដូចគ្នា មិនមែនសុទ្ធតែល្អឬអាក្រក់ទាំងអស់គ្នាទេ ស្រីដែលល្អក៏មានច្រើន ធម្មតាប្រុសនឹងចៀសវាងពីស្រីមិនផុតទេ ចំណែកស្រីវិញក៏ចៀសវាងពីប្រុសមិនរួចដែរ អ្នកទាំងពីរត្រូវ

តែពឹងពាក់ប្រាស្រ័យជាប់ទាក់ទងគ្នា ជានិច្ចតាមធម្មតាលោក ហេតុនេះ ប្រុសនឹងស្រឡាញ់ស្រីយកធ្វើជាប្រពន្ធ ឬស្រីនឹងស្រឡាញ់ប្រុសយកធ្វើជាប្ដី ត្រូវតែសង្កេតឲ្យម៉ត់ចត់ ឲ្យដឹងលក្ខណៈប្រុសស្រីនោះថាល្អ ឬអាក្រក់ជាមុនសិនកុំចេះតែស្រឡាញ់ឥតគំនិត ។

យក្សព្រួតាបសពន្យល់ដូច្នោះហើយ ក៏ដាច់ចិត្តលែងស្រឡាញ់នាងកុលធីតាបណ្ដេញឲ្យដើរចេញពីខ្លួនទៅ រួចថ្វាយបង្គំលាតាបសវិលទៅលំនៅខ្លួនវិញ ។

រឿងស្រីក្នុងស្មុគចប់ប៉ុណ្ណោះ

ម៉ែព្រួទេ ! មកពីខ្ញុំព្រួរឿងស្រីក្នុងស្មុគនេះហើយបានជាខ្ញុំខ្លាចស្រីណាស់ តាំងចិត្តថាលែងយកប្រពន្ធមួយជាតិ ស៊ូនៅតែម្នាក់ឯងល្អជាងកុំឲ្យកើតទុក្ខដោយសារតែប្រពន្ធ ។

ធាងវរស់ — ងើបមើលមុខ ជីប្រែ, ឯងថានោះមិនត្រូវសោះ ស្រី ៗ ក៏មានខូចកាចអាក្រក់ដូចប្រុស ៗ ដែរ, ប៉ុន្តែមិនមែនសុទ្ធតែខូចកាចអាក្រក់ទាំងអស់គ្នាទេ ស្រីដែលល្អមានច្រើនជាងស្រីអាក្រក់ ប្រសិនបើស្រី ៗ សុទ្ធតែខូចទាំងអស់នោះ គ្មានអ្នកណាតាំងវង្សត្រកូលកើតទេ ដូចជាគេមានប្ដីប្រពន្ធ កើតកូនពូនជាចៅនៅពេញភូមិកោះរះថ្នុគនេះឯង ឃើញដែរឬទេ ឯស្រីខូចក៏មានខ្លះដែរ, ប៉ុន្តែមានមួយ ៗ ចាស់ទុំលោកប្រដៅឲ្យចៀសវាងស្រីខូច ដូចមានសុភាសិតថា : «កុំទាត់ស្របង្បៀ

កុំប្រដៅស្រីឡូក ហេតុនេះ ត្រូវឯងយកប្រពន្ធទៅចុះ ម៉ែនឹងរើសកេស្រីដែលមានគំនិតមារយាទល្អត្រឹមត្រូវឲ្យឯង តាមសុភាសិតបុរាណថា ធុរៈជាការគេរៀនហើយ ឲ្យមើលដៅពង្ស ។

ជីប្រែ– ទេ! ទេ! ម៉ែ! ខ្ញុំមិនព្រមយកប្រពន្ធទេ សូមម៉ែលែងគិតគូទៅ កុំរកស្ដីដណ្ដឹងកូនចៅអ្នកណាឲ្យសោះ ។

អ្នកតារកេះតា–ដេកស្ដាប់កូនប្រកែកនឹងម្ដាយដាច់អហង្ការដូច្នោះ តឹងទ្រូងពេក ទ្រាំមិនបាន ក្រោកអង្គុយ ទាញស្លាត្រថ្នាំមូរបារីស្លឹកសន្ដែក ១ ធំ បឺតហុយទ្រលោម ឆ្លើយកាត់កូនភ្លាមថា ឯងស្បថលែងយកប្រពន្ធមួយជាតិនោះ អញមិនជឿសោះ ថ្ងៃនេះឯងថាមិនយក ក្រែងដល់ទៅថ្ងៃប៉ុន្មានឆ្នាំក្រោយ ឯងប្រែចិត្តព្រមយកវិញ ដ្បិតចាស់ទុំថា ចិត្តមនុស្សប្រុសស្រីគ្រប់រូបតែងតែប្រែប្រួលជាធម្មតា មិននឹងនៅឲ្យទៀងទាត់តែម្យ៉ាង ១ ទេ ម្ដងគិតឃើញយ៉ាងនេះ ម្ដងគិតឃើញយ៉ាងនោះ ដូចខ្លួនអញនេះជាតិ កាលអញបួសកំពុងតែរកពយនឹងផ្នួស អញតាំងចិត្តថាបួសមួយជីវិត លែងសឹកមកយកប្រពន្ធ ព្រោះឃើញអ្នកស្រុកមានប្ដីប្រពន្ធលំបាកណាស់ ណាព្រួយនឹងរកស៊ី ណាមួយព្រួយនឹងប្ដីប្រពន្ធកូនចៅឈឺចាប់ស្លាប់ទៅ កើតទុក្ខសោករកសុខគ្មាន បើនៅបួសខ្លួនតែមួយគ្មានកើតទុក្ខព្រួយចិត្តនឹងអ្នកណាទេ ចិត្តអញ ប្ដេជ្ញាយ៉ាងនេះរួចមកហើយ ប៉ុន្តែ ខុំបស្រឡះ ដ្បិតខ្លះក្រោយមកមានគេធ្វើឲ្យចាស់ចិត្តកើត

ទឹងលែងចង់បួសក៏សឹក លុះសឹកមកហើយនៅតែម្នាក់ឯង គ្មានប្រពន្ធ គ្រាន់តឹងពាក់អាស្រ័យក្នុងពេលមានទុក្ខធុរៈយប់ថ្ងៃ លំបាកណាស់ដូចទូកមានតែក្បាលឥតកន្ទ្រឹងទៅណាមិនរួច ទ្រាំមិនបានក៏រៀបការនឹងម្ដាយឯងនេះ ដូច្នេះត្រូវតែឯងយកប្រពន្ធទៅកុំប្រកែក ។

ជីប្រែ— ទេ! ចិត្តឯងម្យ៉ាង ចិត្តខ្ញុំម្យ៉ាង ចិត្តមិនដូចគ្នាទេ ។

អ្នកតាកើត អើ! ឯងថាដុះមែនហើយ ចិត្តមនុស្សគ្រប់រូបសុទ្ធតែខុសគ្នា ប៉ុន្តែត្រង់ចិត្តប្រែប្រួលមិនទៀងទាត់ដូចគ្នាទាំងអស់ ដូចជាអ្នកខ្លះកាលខ្លួននៅក្មេងមិនសូវបួលចិត្តបន្ថែមទេ លុះដល់ចាស់ប្រែជាបួលចិត្តបន្ថែមណាស់ទៅវិញ ។

ជីប្រែ ទេ! ចិត្តខ្ញុំមិនប្រែប្រួលដូចគេ ព្រោះខ្ញុំបានរៀនសូត្រចេះដឹងពីរឿងចិត្តគ្រាន់បើដែរ បានជាខ្ញុំហ៊ានសម្រេចចិត្តយ៉ាងដាច់ខាតថា លែងយកប្រពន្ធមួយជាតិ ។

(នៅមានត)

# រឿងចៅតាំងដិល ចោរចៅក្រឹប

## លោក ម៉ាន់-អេង លេខាធិការ

នៃក្រុមប្រឹក្សាព្រះរាជអាណាចក្រ រៀបរៀង

---

ក្នុងកាលកន្លងទៅហើយ នៅស្រុកមួយមានជនពីរនាក់ប្ដីប្រពន្ធ មានកូនស្រី ៧ នាក់ កូនប្រុសប្រុស ៣ នាក់ ។ ឪពុកម្ដាយជាមេគ្រួសារចាស់ៗហើយ ។

កាលនោះ ជារដូវខែបេត្រដើមឆ្នាំជារដូវទំនេរពីរបរស្រូវ-អង្ករអស់ហើយ. គាត់ជាប្ដីក៏ផ្ដើមបបួលយាយជាប្រពន្ធនឹងកូនស្រី-ប្រុសថានឹងទៅច្រូតស្បូវក្នុងព្រៃស្បាតដើម្បីយកមកក្រងប្រក់ផ្ទះ ពីព្រោះដំបូលផ្ទះស្បូវចាស់ពុករលួយធ្លុះធ្លាយអស់ ។ យាយជាភរិយានឹងកូនទាំងអស់ក៏ស្រុះស្រួលព្រមព្រៀងគ្នា ។

ក្នុងវេលាយប់នោះ ម្ដាយបង្គាប់ឲ្យកូនស្រីរៀបចំអង្ករ-អំបិល-ប្រហុក ត្រីងៀត ឆ្នាំងបាយឆ្នាំងសំល្ល បានគ្រឿងដាក់ក្នុងកញ្ជើរួចស្រេចពីល្ងាច ។

ចំណែកឪពុកបង្គាប់ឲ្យកូនប្រុសៗប្រមូលកាំបិត-ពូថៅ នឹងកណ្ដៀវ ទុកឲ្យមូលមួយកន្លែង, រួចគាត់បង្គាប់ឲ្យកូនប្រុសទាំង ៣ នាក់ ចុះទៅទាញរទេះគោចេញពីក្រោមផ្ទះ រកចំណងចងព្រែកបោះស្នៀតកង់កាំនឹងដងទ្រនាម ភ្ជាប់រទេះឲ្យជាប់លាប់ ។

កូនប្រសាទី ១ នឹងទី ៣ នាំគ្នាធ្វើតាមបង្គាប់ឪពុកក្មេកទាំងអស់ ។ ឯកូនប្រសាទី ២ គ្រាន់តែចុះបាត់ពីលើផ្ទះ ដើរទ្រលទ្រល ៗ ទៅឯណោះ បន្តិច ឯណោះបន្តិច លុះគេធ្វើរួចស្រេច, ទើបឡើងទៅលើផ្ទះវិញជាមួយនឹងគេដែរ ។

ព្រឹកព្រាងស្វាងព្រះសុរិយាកាលណា, ឪពុកម្តាយមេគ្រួសារ នាំកូនបង្កើត-កូនប្រសាទឹមរទេះផ្ទុកអង្ករឈើព្រៃដាក់លើរទេះមួយបរសំដៅទៅកាន់ព្រៃស្បាត, ដល់ហើយនាំគ្នាដាក់រទេះ ដោះគោយកទៅចងឲ្យស៊ីស្មៅ ។ ឯកន្លែងប្រួតស្បូវនោះ មានតែស្បូវ-ស្មៅនឹងកូនឈើតូចតាចបន្តិចបន្តួច រកម្លប់ជ្រកគ្មានទេ ។

ឪពុកដឹងថាមុខជាក្តៅណាស់ ព្រោះរដូវខែចេត្រផង ទើបគាត់ហៅកូនប្រសាទាំង ៣ នាក់មកប្រើថា៖ កូនឯងនាំបងប្អូនទៅរកកាប់កូនឈើខ្លះនឹងប្រួតស្បូវខ្លះ ពោចវល្លិ៍ពោចរពាក់ខ្លះ យកមកចងប្រក់ធ្វើជាដំរំមួយគ្រាន់ជ្រក ព្រោះដល់ពេលថ្ងៃឡើងក្តៅណាស់ ។

កូនប្រសាទី ១ នឹងទី ៣ ទទួលថាបាទ ៗ ហើយស្រវាចាប់កាំបិតពូថៅនឹងកណ្តៀវ នាំគ្នាទៅរកក្លាម ។

ឯកូនប្រសារទី ២ ធ្វើទឹមទាម ៗ ស្ទើរទៅស្ទើរនៅ ក៏ដើរលយតាមគេទៅព្រៃដែរ, ប៉ុន្តែលុះទៅដល់ព្រៃពុំបានធ្វើអ្វីទីទៃគេទេ ទៅពួនអង្គុយ

សំកុកយកដៃប្របាច់ពោះថ្ងូរថា "ឈឺពោះណាស់ ធ្វើអ្វីមិនកើតទេ" ។

កូនប្រសា ២ នាក់ខំកាប់-ពោច-ច្រូត-ឈើឫស្សីល្វើនឹងស្បូវបាន គ្រប់គ្រាន់ ក៏នាំគ្នាកងលីយកមកចងប្រក់ ធ្វើជំរំមួយបានហើយស្រេច ទើបនាំគ្នាទៅខំច្រូតស្បូវ, លុះដល់ថ្ងៃខ្ពស់ជិតដល់ពេលបាយ ក៏នាំគ្នាមក ឈប់សម្រាក ខ្លះដាំបាយ ។ ឪពុកបង្គាប់កូនខ្លះឲ្យទៅដងទឹក ខ្លះ ទៅរកអុសមកដុត ។ កូនឯទៀត ៗ គេទៅធ្វើបានសម្រេចអស់តាម បង្គាប់ឪពុក ។

ចំណែកចៅចុកពោះមិនគិតជួយធ្វើអ្វីគេទេ, ចេះតែគេចមុខទៅឯ-ណោះបន្តិចឯណោះបន្តិច, លុះដល់ត្រូវកំដៅថ្ងៃខ្លាំង គាត់ទ្រាំឈរនៅ កណ្ដាលវាលមិនបាន ហើយគាត់មិនហ៊ានចូលជ្រកក្លាម ពីព្រោះពុត គាត់ខ្ជិលមិនបានជួយធ្វើនឹងគេ គាត់គ្រាន់តែដើរកាប់ពងក្បែរ ៗ ជំរំនោះ បែកញើសហោមជាមពាសពេញមុខមាត់ ហើយគាត់ចេះតែទន្ទេញថា "តិចផុតឥឡូវ ៗ" ៗ គាត់ថាច្រើនដង ប៉ុន្តែគ្មានអ្នកណាស្ទិតហៅ ឲ្យចូលជ្រកសោះ សូម្បីតែនាងជាប្រពន្ធខ្លួននោះក៏មិនហ៊ានផង ព្រោះ ខ្លាចឪពុក ៗ ទើបម្ដាយក្មេកគាត់ក្រឡេកមើលទៅ ឃើញដូចជាវេទនា ក្មេកគាត់ពេក គាត់ក៏ហៅថា "លោកកូនឯណោះ នៅឈរហាលថ្ងៃ ដល់ណាទៀត ម៉េចក៏មិនចូលមកជ្រកទៅ" ៗ ចៅនោះក៏ចូលមកជ្រក

ទាំងញញើតញញើម ៗ តាទឹងកូនឯទៀត គេមិនមាត់ទាំងអស់គ្នា ៗ គ្រួសារនោះនាំគ្នាសម្រាកមួយស្របក់ ក៏នាំគ្នាទៅប្រូតស្បូវទៀត ខ្លះនៅដាំបាយ ឪពុកក៏ប្រើចៅចុកៈពោះឲ្យទៅជួយរកឧសមកថែមជាមួយកូនប្រុសា ១ នាក់ទៀត, ចៅចុកៈពោះគ្រាន់តែចេញទៅឲ្យបាត់ពីមុខតាប៉ុណ្ណោះ ប៉ុន្តែពុំបានជួយរកឧសគេទេ ៗ

ចំណែកឯតាវិញ ភ្នែកគាត់ចេះតែរំពៃលួចគន់មើលដំណើរចៅនោះ គាត់ដឹងច្បាស់ក្នុងចិត្តគាត់ថា “ អានោះជាមនុស្សវិលមិនមែនជាឈើទេ, ត្រូវបង្អត់បាយវាកុំឲ្យវាធ្លាប់ អាមនុស្សខូច” ៗ និមិត្តតែដល់បាយនឹងម្ហូបឆ្អិនអស់ហើយ គាត់បង្អកហៅប្រមូលកូនឯទៀតៗ ឲ្យមកជួបជុំគ្នានឹងបរិភោគបាយ, គាត់ក៏ហាមប្រពន្ធនឹងកូនឯទៀតថា “នែវុយ! នរណាកុំហៅអាមួយនោះមកស៊ីឲ្យសោះ ឲ្យវាស្គាល់ចិត្តឪម្តងមើល! ” ម្តាយនឹងកូនទាំងអស់គ្នាក៏នៅស្ងៀម ៗ គេក៏នាំគ្នាអង្គុយរាតវង់ ជួសដោះបាយបរិភោគយ៉ាងសប្បាយ, ស្រាប់តែឃើញចៅកំជិលដើរចេញពីក្នុងព្រៃស្បាតយ៉ាងរួតរះសំដៅមកជំរំ ប៉ុន្តែពុំហ៊ានចូល គ្រាន់តែដើរក្រឡឹងជុំវិញ ចាំឲ្យគេហៅដូចមុនទៀត ៗ

ទោះបីចៅនោះដើរក្រឡឹងជំរំដល់ទៅ ១០ ជុំ ក៏គ្មាននរណាគេហៅសោះ, មើលទៅមុខគាត់ក្រៀមក្រោះបាក់ពោះសង្វៃ កាន់តែឃ្លាន

បាយខ្ទាំង គាត់អត់ទ្រាំពុំបាន ក៏ឆ្លាយសំដីថា៖ "គិចគ្រីបឥឡូវ ៗ បានជាគ្រីប គ្រីបឲ្យអស់" ។ ឪពុកក្មេកឮដូច្នោះ គាត់ថាឲ្យវិញថា "គិចផសឥឡូវ ៗ! បានជាផស ផសឲ្យឆាប់" ។

ចៅកំជិលដឹងខ្លួន ក៏អៀនខ្មាសអស់បងប្អូនថ្លៃនឹងប្រពន្ធណាស់, ប្រាសប្រោលក៏ដើរហូតដល់ផ្ទះទាំងអត់បាយដេកសន្លឹកសន្លៃ ទន្ទឹងចាំតែដល់ពេលព្រលប់គេវិលមកពីច្រូតស្រូវវិញ ទើបបានចុះយបរិភោគ ។

អំពីនេះតមកទៀត ចៅគ្រីបស្បថប្រាំបាន កងចាលមួយអាយុ លែងខ្ជិលលែងមានពុតត្បុតដូចមុនទៀត, ខំធ្វើការរកស៊ីដូចជនទាំងពួង ជាមួយកិរិយាដកបដល់អស់ជីវិតរៀងខ្លួន, ប៉ុន្តែគេក៏ហៅឈ្មោះចៅគ្រីប អ្នកស្រុកគេនាំគ្នាដំណាលទៅជាប់រហូតតមកដល់សព្វថ្ងៃ ។

---

# រឿងព្រេងប្រទេស មុិះហាវ្រិកា

ចែងអំពីឆ្កែព្រៃ នឹងក្រុមឆ្កែស្រុក


## ភិក្ខុ ម៉ែន - វៀម

*សិស្សពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ*


ប្រែពីភាសាអង់គ្លេស

---

*នេះគឺជារឿងឆ្កែព្រៃ ដែលជាសត្វបោកប្រាស ហើយជាសត្វក្ញើផង ៗ ចំពោះសត្វនេះ, សត្វដទៃទៀតបាននិយាយដោយពិតថា ការឈ្លាសវាងវៃរបស់វា មានទំហំស្មើនឹងដំណើរក្ញើល្ញើរបស់វាដែរ ៗ*

*ថ្ងៃមួយ ឆ្កែព្រៃនេះ កំពុងតែត្រាច់ចរតាមជ្រលងភបុចនោះក្ដី ស្រាប់តែឆ្កែស្រុកពីរធំ ៗ ដែលបោលរកដេញខាំខ្លួនវាយូរហើយនោះ បានលោតពីក្រោយមហាសិលាពីរផ្ទាំងមក ៗ ឆ្កែព្រៃយើង ក៏ដាក់មេផាយយ៉ាងលឿនឆ្ពោះទៅរកព្រៃ ៗ ប៉ុន្តែ ឆ្កែស្រុក ទៅជាវៃស្មានថា វាបោលទៅរកទីវាលចំការវិញ ៗ កាលដែលឆ្កែព្រៃបោលជុំវិញព្រៃស៊ុមទ្រុម លោតផ្លោះរំលងថ្ម រំលងព្រែកឥតទឹក បង្ហុយធូលីទ្រលោមឡើងពីក្រោយនោះ វាស្មានថាមុខជាបានរួចពីកណ្ដាប់ដៃឆ្កែស្រុកហើយ ដោយបានឮសូរសំឡេងព្រុះយ៉ុះ! យ៉ុះ! យ៉ុះ! នៃឆ្កែស្រុក យ៉ាងខ្សោយពីចម្ងាយមក ៗ វាដង្ហក់ រួចមៀងមើលជុំវិញខ្លួនរកជម្រកដ៏ល្អសំរាប់សំរាក ៗ*

*ប៉ុន្តែកាលដែលវាកំពុងតែសំរេចចិត្តដូច្នេះ ស្រាប់តែលេចឆ្កែស្រុក*

ពីរទៀត មិនដឹងជាមកពីកន្លែងណា ស្ទុះដេញព្រមគ្នាតែម្ដង ៗ ពេលនោះ ខ្លែងព្រៃ ក៏ត្រូវខ្លែងស្រុកប្ដីទាំងពីរនោះ បំផាយឲ្យត្រឡប់ទៅកន្លែងដើមរបស់ខ្លួនវិញ ៗ ពួកខ្លែងស្រុកចេះតែប្រដេញពីមុខក្រោយៗ ធ្វង កាត់ពីលខ្ទប់ ដរាបដល់វាហេវអស់កំឡាំង យ៉ាងខ្លាំងរកបោលឲ្យឆ្ងាយតទៅទៀតមិនបាន ៗ ខ្លែងស្រុកពីរនៅខាងក្រោយ កាន់តែជិតមក ៗ ហើយនៅខាងមុខឯណោះ មានខ្លែងស្រុកពីរទៀតនោះ កំពុងតែរង់ចាំខ្លួន ម្ល៉ោះហើយវាដឹងថា ត្រូវតែធ្វើការឲ្យរហ័សរហួនទើបរួចខ្លួន ៗ

នៅលើចំហៀងភ្នំ ខ្លែងព្រៃបានឃើញសភាពខ្មៅងងឹតកងមូលមួយកន្លែង នាំឲ្យវាមានសេចក្ដីក្លាហានឡើងវិញ ៗ វាស្មានថា សភាពខ្មៅនោះ កាន់តែជិតមកខ្លួនវាហើយ គឺជាគុហា (Cave) មួយ ៗ ហើយឥឡូវ វាមើលទៅឃើញខ្លែងស្រុកដែលនៅខាងមុខទាំងពីរនោះហើយ ថែមទាំងឮសូរស្ទុះ ខ្លែងស្រុកខាងក្រោយថែមទៀតផង ៗ វាបានបោលគេចយ៉ាងរហ័សក្លៀត ហើយស្ទុះបោលសំដៅជើងភ្នំឲ្យផុតពីកណ្ដាប់ដៃពួកខ្លែងស្រុក, ប៉ុន្ដែពួកនេះ បោលដេញយ៉ាងលឿនអស្ចារ្យ ហើយកាន់តែជិតចូលទៅជិតខ្លែងព្រៃបន្ដិចម្ដង ១ ជិតដល់ខ្លែងព្រៃពួកគេពិភាក្សាគ្នាថាតើឲ្យនរណាមួយ ចូលចាប់ខ្លួនវា ៗ ឥឡូវ វាបោលចូលទៅជិតគុហានោះ តែវាភ័យដោយគិតថា បើវាចូលទៅក្នុងគុហា គុហានោះល្មម

ឲ្យពួកឆ្កែស្រុកចូលដេញតាមបានមិនទាន់ ។ ប៉ុន្តែ ឥឡូវ ឆ្កែស្រុកបាន ដោលមកជិតប្រកិតនឹងកន្ទុយរបស់វា, ម្ល៉ោះហើយ ដោយការលោតដូច នោះ វាក៏បានជាន់ចុះទៅក្នុងមាត់គុហា ផុតពីកណ្តាប់ដៃឆ្កែស្រុកភ្លាម ៗ

ឆ្កែព្រៃ ជាសត្វមានភ័ព្វ ដោយមាត់គុហានោះតូចមិនល្មមឲ្យពួកឆ្កែស្រុកចូលតាមបានឡើយ, ហើយវាបោលយ៉ាងឆ្ងាយពីមាត់គុហា ដែលអាចទៅឆ្ងាយបាន ។

ខាងក្រៅគុហា ពួកឆ្កែស្រុករត់ប្រាស់ប្រាល់ កោះនាយកោះអាយ ដព្រ្ឈាំដើរជុំវិញមាត់គុហា, មួយសន្ទុះក្រោយមក ទើបបាត់ស្ងូរ ៗ

នេះជាសេចក្តីតក់ស្លុតមួយដ៏អាក្រក់បំផុត ដែលឆ្កែព្រៃស្រាប់តែបានជួបប្រទះដោយស្រួល ៗ ។ ប៉ុន្តែ គ្រាដែលបានជួបនិរទុក្ខ ខាងក្នុងគុហាហើយ វាក៏មានសេចក្តីក្លាហានឡើងវិញ ។ វាបែកគំនិតផ្តើមគិតថា តួខ្លួនវាជាមិត្តម្នាក់របស់វា ដែលអាចរើខ្លួនរួចស្រឡះពីពួកឆ្កែស្រុក, ហើយការដែលអវយវៈដ៏ល្ហិតល្ហៃ របស់វា បានសំរាកស្រួលហើយ, បំណាងខាងអួតសរសើរខ្លួន ក៏កើតឡើងដល់វា, ប៉ុន្តែគ្មាននរណាមួយក្នុងគុហា និយាយជាមួយវាសោះ, ម្ល៉ោះហើយ វាចាប់ផ្តើមព្រោកប្រាជ្ញជាមួយនឹងអវយវៈផ្សេង ៗ របស់វា ដែលមានអវយវៈខ្លះ បានប្រណាំងជាមួយពួកឆ្កែស្រុកនោះថា ៖

- ដើង ! តើដើងឯងបានធ្វើការអ្វីខ្លះ ? , ( កនិយាយដោយពោល ក្អែកមើលទៅដើងទាំងប្អូនរបស់ក ) ។

ដើងឆ្លើយដោយមាត់របស់កថា៖

- ពួកយើង បាននាំខ្លួនអ្នកឯង ឲ្យឃ្លាតឆ្ងាយមកកាន់ទីនេះ, យើងបន្ថយធូលីឲ្យហុយទ្រលោមឡើង ដើម្បីធ្វើឲ្យខ្វាក់ភ្នែកក្អែកស្រុកចង្រៃ, យើងលោតផ្លោះថ្ម, ផ្លោះព្រៃស៊ិមទ្រុម ហើយនាំខ្លួនអ្នកឯងមកដល់គុហានេះ ! ។

- អើល្អ ! ល្អ ! ដើងឯងធ្វើការល្អណាស់ ! ។

- ចុះត្រចៀក ? ត្រចៀកឯងបានធ្វើអ្វីដែរ ? ។

- យើងស្តាប់ផ្លូង-ស្តាំ, ស្តាប់ឲ្យដឹងចម្ងាយដែលឆ្កែស្រុកបោលដេញពីក្រោយ ដើម្បីឲ្យសញ្ញាដល់ដើងដែលត្រូវបង្កើនល្បឿនប៉ុន្មាន ៗ ទើបផុតពីអន្តរាយ ។

- អើ ! អស្ចារ្យមែន ! ។

- ចុះភ្នែក, ឯងធ្វើការអ្វីដែរ ? ។

- យើងបង្ហាញផ្លូវ ឲ្យដឹងកន្លែងថ្ម ព្រៃស៊ិមទ្រុម ជ្រលងជងអូរ, យើងគយគន់ទៅឆ្ងាយ ដើម្បីរកកន្លែងនិរទុក្ខឲ្យអ្នក ហើយយើងឃើញគុហានេះ ! ។

- អើ! ខ្ញុំមែន! ។

ផ្កាព្រៃ និយាយសួរខ្លួនឯង ឆ្លើយខ្លួនឯង យ៉ាងនេះហើយ ក៏សើចសប្បាយចិត្តយ៉ាងអស្ចារ្យ ដោយបន្ទឹសំដីថា៖

- ចុះភ័ព្វអីអញ ក៏មានមិត្តភ័ក្តិល្អៗដូចជាក្អែកត្រចៀកយ៉ាងហ្នឹងហ្ន៎!។

ផ្កាព្រៃ ដែលមានជ័យជំនះ ដោយសារអវិយវៈខ្លួនបានធ្វើការគ្រប់បែបគត់ទាំងនៅក្នុងជីវិតដូច្នេះហើយ, ក៏ងើបក្បាលបែរទៅក្រោយ ប៉ងនឹងទះខ្នងខ្លួន (បែបផ្សេងដែលគាប់ចិត្តចំពោះអ្នកតូចណាមួយហើយ ទះខ្នងអ្នកនោះតិចៗ) ។ ស្រាប់តែឃើញកន្ទុយខ្លួនឯង ក៏លាន់មាត់ថា៖

- អ៊ូកន្ទុយ! អញរកកល់តែនឹងភ្លេចឯងទៅហើយ! មក! ប្រាប់អញមើល៍ តើឯងបានធ្វើអ្វីខ្លះ ប្រឆាំងនឹងផ្កាស្រក ក្នុងជ័យជំនះរបស់យើងនេះ ? ។

កន្ទុយ ក៏និយាយប្រាប់ដោយសំឡេងផ្កាព្រៃឯងថា៖

- អ្នកឯងមិនសូវជាគិតដល់ខ្ញុំប៉ុន្មានទេ! ។ ដូច្នេះហើយ បានជាកន្ទុយគ្មានបម្លើយថាដូចម្តេចឡើយ ។

វានិយាយទៅរកកន្ទុយទៀតថា៖

- ដោយទួទៅ អាឯងនេះ គ្រាន់តែជាអវិយវៈបន្ទែមមួយ ឥតផលដល់យើង, អាឯងនាំឲ្យយើងថយក្រោយ ជាងអ្វីៗ ទៅទៀត, ថែមទាំង

វ៉ះតែឲ្យគេចាប់ខ្លួនអញបានផងទៀត ; អាឯង នាំឲ្យពួកខ្មែរស្រុក ចាប់ចុះអាឯងកន្ត្រាក់ទៅក្រោយ ; ប៉ុន្តែ យើងចាំស្តាប់ពីគាត់ឯងមុន, និយាយមក ! អាឯងបានធ្វើអ្វីខ្លះ ? ។

ខ្ញុំបានធ្វើអ្វីទៅ ? គឺខ្ញុំបានបក់ចុះ-ឡើងយ៉ាងនេះទៅរកពួកខ្មែរស្រុក, ហើយប្រាប់ពួកវាឲ្យមកចាប់អ្នកឯង; កាលអ្នកកំពុងតែបោល ខ្ញុំនៅខាងក្រោយអ្នក បង្ខំពួកខ្មែរស្រុកឲ្យវាបោលកាន់តែជិតមក, ទុកណាជាមានធូលីហុយឡើងក៏ដោយពួកវានៅតែអាចឃើញខ្ញុំ ដោយសារបលនាពណ៌សរបស់ខ្ញុំ ។

មុខក្រញូវរបស់ខ្មែរព្រៃ កាន់តែខ្មៅឡើង ៗ ហើយស្រែកគំហករកាក់រអួល ដាប់ ៗ ដោយកំហឹងថា ៖

- ស្ងៀមទៅ ! កុំមាត់ ! អាឯងនិយាយបែបហ្នឹងតើវាមានន័យយ៉ាងម៉េច ?

ពេលនោះ វាបែរទៅរកខ្ទង់ រួចគប់កន្ទុយយ៉ាងធ្ងន់មួយដៃ ដោយពាក្យថា ៖

- អាឯង មិនត្រូវនៅក្នុងគុហានេះ ជាមួយអាយវៈដ៏សេសរបស់យើងទៀតទេ ! អាឯងនេះ ជាអ្នកក្បត់ ! ។

ថាៈហើយខ្មែរព្រៃក៏ញាក់កន្ទុយជូនខ្ពោះទៅទ្វារគុហា :

– ទៅក្រោយ! កុំនៅជាមួយអញ! ទៅក្រៅទៅ, គ្មានបន្ទប់ឯណាសំរាប់អាចង្រៃឯងក្នុងទីនេះទេ, អាឯងត្រូវតែទៅនៅខាងក្រៅ ព្រោះអាឯងជាបក្សពួកខាងខ្លែស្រុក, អាឯងជួយគេឲ្យចាប់អញ រួចហើយអាឯងអួតសរសើរពើក!, ទៅក្រៅទៅ! ។

ខ្លែព្រៃ បានចង្អុលទៅកន្ទុយខ្លួនដោយដៃម្ខាង ហើយចង្អុលទៅទ្វារគុហាដែលមានពន្លឺថ្ងៃចាំងចូលមក ដោយដៃម្ខាងទៀត ។

– ទៅក្រៅទៅ! ។

ពេលនោះ ក៏បានរុញកន្ទុយឲ្យចេញទៅខាងក្រៅទ្វារដែលជាល-ហអាកាស ។ ពួកខ្លែស្រុក ដែលចាំស្តាប់ការនិយាយរបស់ខ្លែព្រៃខាងក្នុងគុហា បានលាក់ខ្លួនពួននៅខាងក្រៅ, កាលបានឃើញកន្ទុយខ្លែព្រៃលេចធ្លុយចេញមកតាមទ្វារគុហាដូច្នោះ ក៏នាំគ្នាទៅចាប់ទាញឡើង ៗ ម្ល៉ោះហើយ ខ្លែព្រៃនោះ ក៏ត្រូវពួកខ្លែស្រុកទាំងអស់ កន្ត្រាក់ទាញចេញមកក្រៅគុហា ពីព្រោះតែកន្ទុយនោះឯង ។

---

## តាមឯកសាររបស់ក្រុមជំនុំជំនៀមទម្លាប់ខ្មែរ

### រឿងអ្នកតាក្រហមក
### នៅខេត្តកំពង់ធំ

នៅក្នុងវត្តកំពង់ធំ មានរូបអ្នកតាមួយធ្វើពីថ្មហៅថា អ្នកតាក្រហមក ជាអ្នកតាមានឫទ្ធានុភាពយ៉ាងពូកែ អ្នកស្រុកទីងនាហ្នឹងក្នុងខេត្តកំពង់ធំតែងកោតខ្លាចពន់ពេក ។

រឿងរ៉ាវអ្នកតានោះ ដូចមានអធិប្បាយខាងក្រោមនេះ :

ប្រមាណជាជាង ១០០ ឆ្នាំមកហើយ មានបុរសមួយនាក់ជាតិខ្មែរឈ្មោះជ័យ ប្រពន្ធឈ្មោះនាងខុង ។ មានបាវក្មេងប្រុសម្នាក់នៅក្មេងជំទង់ឈ្មោះយ៉ែត ផ្ទះនៅក្បែរភ្នំសន្ទុក ក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ ។ ចៅជ័យ ជាគ្រូសិល្បសាស្ត្រយ៉ាងពូកែ ធ្វើជាគ្រូពេទ្យហ្មផង ជាអ្នករកទទួលតានរែកលក់ផង ។ ចៅជ័យនោះ តែងចេញរែកលក់ជាមួយនឹងចៅយ៉ែត ៗ ពេលព្រឹកព្រលឹមចេញដំណើរពីផ្ទះទៅភ្នំសន្ទុក ទៅលក់តាន់នៅស្រុកជីក្រែង(១) ដល់ពេលព្រលប់ត្រឡប់មកផ្ទះវិញ ៗ ចម្ងាយផ្លូវទៅមកក្នុងមួយថ្ងៃ ៗ ចំនួនជា ២០០ គីឡូម៉ែត្រ ។

មានថ្ងៃមួយ ចៅជ័យរែកអម្រែក បណ្ដើរចៅយ៉ែតចេញពីស្រុកជីក្រែង ប៉ងនឹងត្រឡប់ទៅផ្ទះខ្លួនវិញ តែមកដល់ត្រឹមវត្តកំពង់ធំ អស់

---

១ ស្រុកជីក្រែង កាលពីដាច់មុខនៅក្នុងខេត្តកំពង់ធំ ទើបតែនឹងបាត់បញ្ចូលទៅក្នុងខេត្តសៀមរាប ក្នុងពេល[illegible]

កម្លាំងពេកទៅទៀតពុំរួច ក៏ចូលទៅក្នុងវត្ត រកលោកគ្រូចៅអធិការ ដែលជាភ្ញៀវនឹងគ្នាកាលនៅពីក្មេង ធ្លាប់បួសរៀនជាមួយគ្នា ។ គ្រូជ័យនោះចូលដល់កុដិហើយក៏ដាក់អម្រែកចុះ ឡើងទៅថ្វាយបង្គំលោកគ្រូចៅអធិការ ។ ក៏សាកសួរសព្វគ្រប់តាមភាពមនុស្សធ្លាប់ស្គាល់ស្និទ្ធស្នាលនឹងគ្នា ។ រួចស្រេច ចៅជ័យនិយាយផ្តាំលោកគ្រូថា " ដល់ឆាន់ហើយសុំឲ្យទុកបាយឲ្យទទួលទានផង " ។ ជាតែប៉ុណ្ណោះ ក៏ចុះទៅទទួលទានដំណេកក្នុងវិហារលក់ទៅ ។ ចៅយ៉តក៏នៅលេងជាមួយនឹងលោកគ្រូឯកុដិ ។

នៅពេលដែលបុរសនេះដេកលក់ មានរស្មីព្រះអាទិត្យចាំងចូលតាមជម្លួលវិហារ(១)ទៅលើបុរសនោះ ស្រាប់តែមានពស់នាគពជមួយដែលនៅក្នុងទីវត្តនោះ ចេញទៅវៀនឆ្វាយរង្វើលនៅពីលើក្បាលបុរស ហើយបើកពពារក្បាល ៤ ចាំង កុំឲ្យកំដៅព្រះអាទិត្យចាំងទៅលើបុរសនោះ ជាភេទអស្ចារ្យណាស់ពេក ។ ដល់ចាំងយូរទៅ បណ្តាលឲ្យទឹកមាត់ពស់នាគពជហៀរហូរពីមាត់ធ្លាក់ទៅលើកបុរសដែលដេកលក់ ។

ដល់ពេលលោកឆាន់ហើយ លោកគ្រូចៅវត្តបានឲ្យលោកភិក្ខុ ១ អង្គទៅហៅចៅជ័យពីក្នុងវិហារមកបរិភោគបាយ ក៏ស្រាប់តែលោកជាបំរើចូលដល់មាត់ទ្វារ ក្រឡេកទៅឃើញពស់បើកពពារលើចៅជ័យ ក៏ភ្ញាក់

១ - កាលជាន់នោះ វិហារសង់ពីឈើ ប្រក់ស្លឹកធំវែង គឺជាបន្ទះក្តារធ្វើរបៀបដូចជាក្បឿងសព្វថ្ងៃ, តែខុសគ្នាត្រង់ : ធ្វើពីគន្លឹះ ? ធ្វើពីឈើអារជាបន្ទះក្តារតូច ៗ ។

ខ្ញុំនៅស្រែកឡើងថា " ពស់ធំណាស់ ៗ នៅក្នុងវិហារ " ។ ពេលនោះ លោកសង្ឃផ្សេងៗទៀត ក៏ដើរមកមើល ។ ឯពស់ក៏លូនចុះពីវិហារចូលរូងវាងក្រោមវិហារនោះបាត់ទៅ ។ បុរសដែលបើកលក់ ក៏ភ្ញាក់ស្មើនម៉ឹង ភិតភ័យរន្ធត់ញាប់ញ័រ តែដោយសារនឹងប្រាស់ថាពស់នាគពុជមកបើក ពពារបាំងពន្លឺព្រះពេទ្យឱ្យខ្ញុំ ហើយនឹកឃើញសិល្បសាស្ត្រការពារ បំបាត់ភ័យខ្លាចតទៅ រួចក៏ចុះពីវិហារមករកបាយបរិភោគតទៅ ។

លុះចៅដ៏យបរិភោគបាយហើយ ក៏សាកសួរលោកគ្រូថា ធ្វើដូចម្តេចឱ្យជ្រុះទឹកមាត់ពស់ចេញពីក តែចៅដ៏យនឹកថា ខ្ញុំមុខជាមានបុណ្យ។ ចំណែកលោកគ្រូក៏នឹកថា "ដ៏យមុខជាមានបុណ្យដែរ ព្រោះពស់នាគ-រាជនេះ ពុំដែលចេញមកបើកពពារបាំងឱ្យមនុស្សណាសោះ ទើបតែពេលម្តងនេះចេញមកបាំងឱ្យ ។ បើអញឱ្យថ្នាំលាបលាងទឹកមាត់ពស់ឱ្យជ្រុះអស់ចេញ មុខជាគ្មានបុណ្យបារមីអ្វីទេ " ។ លោកក៏ប្រាប់ថា "អាដ៏យឯង បើចង់ឱ្យអស់ទឹកមាត់ពស់ពីកឯង ៗ ត្រូវយកទឹកនោមអញទៅលាប បើពុំជ្រុះចេញទេ ឯងជាប់ទឹកមាត់ ១ ជីវិតហើយ " ។ ចៅដ៏យតបទៅលោកគ្រូវិញថា " គ្មាននរណាយកទឹកនោមលោកលាបទេ បើជាប់ក៏ជាប់ទៅចុះ " ។ ចៅដ៏យថាតែប៉ុណ្ណោះ ក៏ថ្វាយបង្គំលាលោកគ្រូត្រឡប់ទៅផ្ទះខ្លួន ជាមួយនឹងចៅយ៉ីតទៅ ។

លុះមកដល់ផ្ទះ បុរសនោះក៏និទានដំណើរប្រាប់ប្រពន្ធ ទាំងឡាយ

ជាប្រពន្ធនឹកឆ្ងល់ថា ប្តីខ្លួនមុខជាមានបុណ្យស័ក្តិអ្វីមួយជាមិនខាន ។

បីថ្ងៃក្រោយមក ករបស់ចៅជ័យ ដែលពស់នាគពជបង្ហៀរទឹកមាត់ដាក់មកលើក៏ឡើងជាកណ្តាប់ មានពណ៌ក្រហមដូចប្រឡាក់ឈាម ធ្វើដូចម្តេចក៏ពុំជ្រះ ប្រែទៅជាមនុស្សក្រហមក ។

ប្រមាណជា ៧ ថ្ងៃពីនោះមកទៀត មានពួកកងទ័ពបះបោរនៅប៉ែកស្រុកពោធិ៍រៀង បឹងល្វា បំណងចូលមកលុកលុយក្រុងកំពង់ធំ ។ បណ្តាជន នឹងនាហ្មឺននៅទីក្រុងនោះ ច្របូលច្របល់ភិតភ័យ រត់ចោលផ្ទះសម្បែងសឹងតែគ្រប់គ្នា ។ ទើបលោកតេជោ(១) ហ្លួ ធ្វើចុតហ្មាយបង្គាប់ទៅគ្រប់លោកដីមឿង(២)ក្នុងខេត្ត ឲ្យរកគេណាមនុស្សខ្លាំងពូកែយកទៅតស៊ូសង្គ្រាមជាមួយនឹងពួកខ្មាំង ។ ដីមឿងឯទៀត ៗ រកអ្នកខ្លាំងពូកែពុំបាន មានតែដីមឿងសន្ទុក ១ ប៉ុណ្ណោះ, ទើបធ្វើសំបុត្របកបឹងមកលោកតេជោវិញថា "សឹកសង្គ្រាមដែលមានបះបោរនៅពោធិ៍រៀង នឹងបឹងល្វានោះ ខ្ញុំខ្ញុំប្របាទរកមនុស្សខ្លាំងពូកែបានម្នាក់ឈ្មោះជ័យ ហើយគេស្ម័គ្រចិត្តធ្វើជាមេកងទ័ព ហើយបានអ្នកស្រុក ៗ សន្ទុកចំនួន ៣០០ នាក់ទៀតគេស្ម័គ្រចិត្តទៅជាមួយផង ។ តាមសំបុត្របកបឹងទៅលោកតេ-ជោនោះថា "ខ្ញុំដីមឿងខ្ញុំប្របាទមានសង្ឃឹមលើរូបចៅជ័យមេកងថា មុខ

---

១ - ងារនេះជាប់ជាងារចៅហ្វាយខេត្រកំពង់ធំរហូតមក ហៅថាអ្នកតាញ៉ាតេជោបុរាណកជ។

២ - ដីមឿង ជាគោរម្យងារនាហ្មឺនស្រុកក្រោមទំនោះ ។ ដីមឿងមានឋានន្តរសក្តិស្មើនឹងចៅហ្វាយស្រុកសព្វថ្ងៃ ។ ឯតេជោស្មើនឹងចៅហ្វាយខេត្តសព្វថ្ងៃ ។

ជានឹងនាំយកជ័យជំនះមកបានជាមិនខាន, ព្រោះចៅជ័យនោះចេះសិល្បសាស្ត្រលើសអស់អ្នកស្រុកឯទៀតៗ ឥតមានឈ្មោះណាហ៊ានតតាំងទេ" ។

លោកតេជោក៏តបទៅជីមឿងវិញថា " យល់ព្រមឲ្យចាត់ចៅជ័យនឹងអ្នកស្រុក ៣០០ នាក់ទៅតទល់ចុះ " ។

បីថ្ងៃមុនលើកទ័ពចេញទៅ អ្នកឡុងជាប្រពន្ធចៅជ័យ រៀបរណ្តាប់ប្រសិទ្ធឲ្យប្តី ហើយសាកមើលតាមចំណាំខ្លួន ដែលជាស្រីចេះសិល្បសាស្ត្របន្តិចបន្តួចដែរ ក៏បង្គាប់ឲ្យមនុស្សយកឫស្សីបានចំនួនមួយពាន់ដើម មកគរដាក់ជាគំនរលើគ្នា ហើយនាងឡុងឡើងអង្គុយនោមដាក់លើគំនរឫស្សីនោះ ។ លុះនោមរួចស្រេច ក៏បានចាត់ឲ្យគេពិនិត្យមើលឫស្សីទាំងមួយពាន់ដើម ឃើញថាបែកប្រេះទាំងអស់ ក៏គាត់ប្រាប់ប្តីគាត់ថា ចេញទៅធ្វើសឹកសង្គ្រាមចុះ មុខជាមានជ័យជំនះហើយ ។ ក៏បង្គាប់ឲ្យប្តីគាត់លើកទ័ពចេញទៅភ្លាម ។

ចៅជ័យនិងអ្នកស្រុកបីរយនាក់ក៏ចេញទៅ តែពេលនោះបាវប្រុសឈ្មោះយ៉ត ក៏ទៅតាមផងដែរ ។ លុះទៅជិតដល់ពោធិ៍កេងបឹងល្វា ពួកខ្មាំងនេះបានយាមត្រៀមត្រា ទាំងយប់ទាំងថ្ងៃ ។ ពេលយប់ ចៅជ័យនាំទ័ពលុកចូលកាប់សម្លាប់ពួកខ្មាំងៗនោះ ក៏បាក់បបខ្ទបខ្ទាចដោយពិណរាប់សម្លាប់ពួកមេៗក៏បានអស់ ។ រីឯពលដែលសេសសល់ខកខានទាំងប៉ុន្មាន ក៏តែថ្ងាត់ដើរសព្រាត ។

ដល់មានជ័យជំនះហើយ នាយជ័យជាមេកងទ័ព នាំរេហ៍ពលខ្លួន ចូលមកស្រុកវិញ រួចចូលដំរាបប្រាប់ដីមឿងស្រុកសន្ទុក ។ ធ្វើសំបុត្រ បកប្តឹងទៅលោកតេជោនៅកំពង់ធំ ។ មានសេចក្តីសរសើរមេកងជ័យជា ក្រៃលែង ហើយលើកឲ្យធ្វើជាដីមឿងសន្ទុក តែចៅជ័យប្រកែកកំអាក់ ខានធ្វើទៅ ។

កន្លង ១ ឆ្នាំតមកទៀត មានទ័ពពួកខ្មាំងស្រុកកញ្ជប (ស្រុកឆែប) ព្រហ្មទេព-ជាំខ្សាន ចូលមកលុកលុយខែត្រកំពង់ធំម្តងទៀត សម្លាប់ លោកតេជោហ៊ូស្លាប់ទៅ ។ ទើបបានមានដំណឹងជ្រាបដល់ព្រះករុណាជា ម្ចាស់ជីវិតគង់នៅវាំងឧត្តុង្គមានជ័យ ។ ទ្រង់ក៏ស្រាវជ្រាវរកមនុស្សខ្លាំង ពូកែ ក្នុងខែត្រកំពង់ធំ ដែលបានច្បាំងឈ្នះពួកបះបោរលើកមុន នៅ ពោធិ៍ពេង-បឹងល្វា ក៏ទ្រង់ជ្រាបថា មេកងទ័ពឈ្មោះជ័យនៅក្នុងសន្ទុក ។ ទ្រង់មានព្រះរាជឱង្ការត្រាស់បង្គាប់ឲ្យនាំយកខ្លួននាយជ័យ ទៅកាន់ព្រះ បរមរាជវាំង ។ នាយជ័យទៅដល់ក្រាបថ្វាយបង្គំទូលតាមដំណើរសព្វ គ្រប់ តែទ្រង់ត្រាស់បន្ទូលថា " ម្តងណេះបើឈ្នះ អញឲ្យឯងធ្វើជាតេជោ ជំនួសតេជោហ៊ូ តែបើជាចាញ់វិញនោះត្រូវអញប្រហារជីវិតឯង " ។ នាយជ័យទទួលព្រះរាជឱង្ការដម្កល់លើត្បូង ។ ពេលនោះ ព្រះរាជអគ្គ- មហេសីព្រះនាមអាំ មានប្អូនប្រុសម្នាក់ធ្វើចាងហ្វាងក្នុងព្រះបរមរាជវាំង ក្រាបបង្គំទូលព្រះរាជា សុំផ្ញើប្អូនឲ្យទៅរៀនធ្វើចម្បាំងជាមួយផង ។

នាយជ័យសុខចិត្តទទួលឥតប្រកែក តែបានទូលស្នងសុំព្រះករុណាថា “ សូមទ្រង់ព្រះមេត្តាប្រោស ! សូមទ្រង់ជ្រាបជាបុនថា ! ទ័ពមុខទូលព្រះបង្គំជាខ្ញុំសូមប្តូរជីវិត យកឈាមក្រាលផែនដីកប់វង តែត្រង់ទ័ពក្រោយបើមានសេចក្តីធាំធ្ពង ទូលព្រះបង្គំជាខ្ញុំ សូមមេត្តាប្រោសអនុញ្ញាតទោស” ។ ព្រះករុណាមានព្រះរាជដម្រាស់ត្រាស់តបវិញ “ មិនអីទេ ! ទ័ពក្រោយនឹងអនុញ្ញាតឲ្យបាន ” ។ រួចហើយ ព្រះរាជាទ្រង់ព្រះរាជទានកងទ័ពឲ្យនាយជ័យមួយពាន់នាក់ ទាំងឲ្យចាងហ្វាងជាប្អូនព្រះអគ្គ-មហេសីធ្វើជាពលទាំងជាមេកងរង ទៅក្រោមបង្គាប់មេកងជ័យ ។

កងទ័ពចេញពីទុត្តង្គ កាត់ទៅខេត្តកំពង់ឆ្នាំង ចូលទៅខេត្តកំពង់ធំ ។ លុះរៀបចូលដល់ទីក្រុងកំពង់ធំ នាយជ័យជាមេកងបានឲ្យកេណ្ឌអ្នកស្រុកជាច្រើនឲ្យកាប់ឫស្សីទុកតាំងមែកទុកតាំងស្លឹក ប្រគល់ឲ្យពួកកងទ័ពអូសប្រាសចុង ។ គ្រានោះ ជារដូវរំហើយភ្លើងទើបនឹងឆេះព្រៃថ្មី ៗ ។ លុះកងទ័ពនាយជ័យអូសឫស្សីប្រាសពីចុង ក៏កំទេចផេះដែលនៅលើដីហុយហើរឡើងទៅលើអាកាស ។ តែពេលនោះ លោកចាងហ្វាងជាមេកងរងពុំព្រមឲ្យកងទ័ពខ្លួនអូសឫស្សីប្រាសចុងទេ ថាពិបាក ។ នាយជ័យជាមេកងធំ បញ្ជាឲ្យចាប់ខ្លួនមេកងរងប្រហារជីវិតនៅទីនោះទៅ ។ មេកងជ័យ មានប្រាជ្ញាណាស់ ដែលឲ្យពួកទ័ពអូសឫស្សីប្រាសចុងនោះ ដើម្បីឲ្យពួកខ្មាំងស្មានថាគ្នាច្រើន ។ លុះកងទ័ពឈប់សំចតឲ្យយកឫស្សីនោះ

ស្រះព័ទ្ធឡើងជិត កុំឲ្យសត្រូវមើលកងទ័ពខ្លួនឃើញបាន ។

លុះកងទ័ពនោះ ធ្វើដំណើរទៅដល់ខេត្តកំពង់ធំហើយ កងទ័ពខាងសត្រូវដែលទៅនៅខេត្តកំពង់ធំ ក៏ភ្ញាក់ផ្អើលដោយសារឃើញផ្សែង និងដីហុយឡើងទៅលើអាកាសច្រើនពេក ទើបនឹកស្មានថា ទ័ពខ្លួនតិចជាងទ័ពគេ ក៏បាក់ទ័ពបរាជ័យក្នុងពេលនោះទៅ ខ្លះក៏រត់ទៅស្រុកដើមកំណើតគឺស្រុកជាំខ្សាន · កព្មោប · ម្លូព្រៃអស់ទៅ ។

ទ័ពមេកងជ័យមិនឈប់ ក៏ដេញតាមរហូតទៅគ្រាំតពួកខ្មាំងសត្រូវធ្លងក្នុងដងរៃក កាត់ទៅស្រុកសៀមបាត់អស់ ។

ក្រោយដែលមានជ័យជំនះមក មេកងជ័យនឹងពួកទ័ពក៏វិលចូលទៅចតុង្គមានជ័យថ្វាយបង្គំគាល់ព្រះករុណា ។ តែមុនចូលដល់ព្រះបរមរាជ-វាំងមេកងជ័យមានប្រាជ្ញាគិតថា ខ្លួនបានសម្លាប់លោកចាងហ្វាងជាប្អូនព្រះរាជអគ្គមហេសី រួចក៏បង្គាប់ពួកកងទ័ពឲ្យយកច្រវាក់៣ខ្សែមកដាក់ខ្លួន គឺ ១ ខ្សែឲ្យដាក់ក, ១ ខ្សែទៀតឲ្យដាក់បង្កេះនឹងដៃ, ១ ខ្សែទៀតឲ្យដាក់ជើងទាំង ២ បណ្ដើរចូលគាល់ព្រះរាជា ។ ដល់ចំពោះព្រះភក្ត្រព្រះរាជា មេកងជ័យទុនកាយថ្វាយបង្គំហើយក៏ក្រាបថា បម្រាំងមុខទូលព្រះបង្គំមានជ័យជំនះហើយ តែបម្រាំងក្រោយទូលព្រះបង្គំសូមជ្រកកោនក្រោមម្លប់ព្រះបារមីល្អងធូលីព្រះបាទ សូមទុកជីវិត ។

គ្រានោះ ព្រះរាជាមានព្រះបន្ទូលថា "អាណាដាក់ច្រវាក់ឯង ត្រូវ

ដោះលេញឲ្យទាប់ ក៏គ្មានទោសពៃរ៍អ្វីទេ រះច្បាំងឈ្នះហើយ" ។ ព្រះពជរក្តមហេសី កាលបើពុំបានឃើញប្អូនក៏យំទួញថា "ច្បាស់ជាស្លាប់ក្នុងចម្បាំងហើយ ឯស្លាប់នោះគឺដោយសារឈ្មោះជ័យសម្លាប់" ។ មេកងជ័យក៏ទូលតបទៅវិញថា "ទូលព្រះបង្គំជាខ្ញុំសម្លាប់មែន ព្រោះមុខទ័ពពុំព្រមស្តាប់បង្គាប់ បើទុកទៅនឹងមានជំទាស់ក្នុងចម្បាំងធំ ហើយមុខជាបរាជ័យពុំខាន ។ ដូច្នេះហើយ, បានជាទូលព្រះបង្គំជាខ្ញុំ ធ្វើឃាដឲ្យហើយមុន ។ មួយទៀត សូមក្រាបបង្គំទូលថា បើទ័ពទូលព្រះបង្គំជាខ្ញុំចាញ់ហើយ មុខជាសត្រូវប៉ុលមកលុកលុយក្នុងនគរ មិនដឹងជាបែបណាទេ" ។ ពេលនោះ ព្រះករុណាទ្រង់ឈ្វេងយល់ ទ្រង់វិនិច្ឆ័យថា "មេកងជ័យត្រូវរួចខ្លួន ត្រូវតាំងឲ្យធ្វើជាតេជោ ជាជំនួសលោកតេជោហ៊ូដែលខ្មាំងសម្លាប់បាត់ទៅ ។

ចាប់តាំងពីមេកងជ័យបានឡើងធ្វើជាតេជោ វេលាណាមក ខេត្តកំពង់ធំបានសុខសប្បាយរហូតមក ឥតមានខ្មាំងសត្រូវណាហ៊ានលុកលុយបានឡើយ ។ ព្រះរាជាទ្រង់ឲ្យពង្រីកខេត្តនេះឲ្យធំ គឺខាងជើងទល់ត្រឹមស្រុកដីក្រែង ដែលសព្វថ្ងៃនៅក្នុងខេត្តសៀមរាប ។ ខាងត្បូងទល់នឹងខេត្តកំពង់ចាម, ខាងកើតទល់នឹងក្រចេះ, ខាងលិចទល់នឹងទន្លេសាប ។

តេជោជ័យ មានអំណាចមានឫទ្ធានុភាពយ៉ាងសម្បើម បណ្តាជនក៏ចេះតែខ្សឹបខ្សៀវគ្នា ហៅតែលោកតេជោក្រហមក ព្រោះតែលោកមាន

ពណ៌ក្រហមដូចប្រឡាក់ឈាម តាមស្នាមទឹកមាត់រាល់នាគពជដូចនិទាន ខាងដើម ។ ឯបំណែកនាងឡុងជាប្រពន្ធក៏ឡើងជាជំទាវឡុង ។ ឈ្មោះយ៉ាតជាបារលោកតេជោក្រហមក គ្រាន់តែជាបាវស្និទ្ធស្នាលតែប៉ុណ្ណោះ ឥតមានបុណ្យស័ក្តិអ្វីទេ ។

លោកតេជោក្រហមកនេះ មានអាយុវែងប្រហែលជាជាង ៩០ ឆ្នាំ ទើបទទួលអនិច្ចកម្ម ។ ហេតុដែលបណ្តាលឲ្យលោកទទួលអនិច្ចកម្ម គឺមកពីលោកទៅមានសហាយជាមួយនឹងកូនស្រីចិនមួយនាក់ នៅក្នុងខេត្តកំពង់ធំ ។ នាងនោះមានរូបឆោមលោមពណ៌ល្អលើសលប់ស្រីឯទៀតក្នុងខេត្តនោះ ។ លុះបានរួមរក្សនឹងនាងនេះទៅ លោកតេជោក៏ស្រឡាញ់គាប់ចិត្តជាទីបំផុត ។ មានថ្ងៃមួយលោកប្រឡែងលេងនឹងនាងជាប្រពន្ធក្រោយនេះ នាងនោះកំពុងតែកាន់ម្ជុលដេរអាវ ។ លុះលោកយកដៃបបោសអង្អែល នាងនោះយកម្ជុលចាក់ដៃ លោកក៏ភ្ញាក់ព្រើត ៗ ។ នាងនោះនិយាយលេងថា " គោតណាស់ លោកជា មទ័ពយ៉ាងធំ ហ៊ានពូកែ ឥតខ្លាចដាវលំពែង ; ប៉ុន្តែកាលញ៉ាំង ប្រហែលជាញ្ញែតែគេឲ្យទៅមុខទេះមើលទៅ ? ប្រើតែពួករហ័ពលឲ្យកាប់សម្លាប់ទេមើលទៅ ? " ។ នាងនោះថាតែប៉ុណ្ណោះ លោកតេជោក្តៅឈួលក្នុងចិត្ត ក្រោកអង្គុយលែងស្តីនិយាយរកប្រពន្ធសំណប់ ។ បែរទៅហៅអាយ៉ាតវិញថា " អាយ៉ាត ! ឯងមកណេះ មកៈទៅជាមួយនឹងអញ រួចចុះទៅដីហើយថា អញ

មុខជាអស់អាយុថ្ងៃនេះហើយ , នៅរស់តទៅទៀតពុំបានទេ ខ្ញុំសូមពាក្យស្រីនិយាយបង្អាប់ណាស់, អាឯងធ្លាប់ដើរតាមអញទៅច្បាំងហើយ អញគ្មានហានបែបណា ពេលនេះ ត្រូវតែឯងសម្លាប់អញឲ្យស្លាប់បែបនោះ" ។

នាយយ៉ក្សថា "ខ្ញុំពុំហ៊ានសម្លាប់ទេលោកតា" ។ លោកតេជោថា "អញធ្វើសំបុត្រចុតហ្មាយឲ្យឯង គ្មាននរណាហ៊ានធ្វើទុក្ខធ្វើបាបឯងទេ ក្រៅពីឯងគ្មាននរណាសម្លាប់អញឲ្យស្លាប់បាន ទាល់តែឯងជាអ្នកបានរៀនសិល្បសាស្ត្រពីអញច្រើនណាស់ បានសម្លាប់អញបាន" ។

នាយយ៉ក្សថា "ដូនតាខ្ញុំសាសន៍ពួង តែចាស់ហើយគេតែងសម្លាប់គាត់ធ្វើបុណ្យ គេមិនទុកឲ្យស្លាប់ឯងៗ ដូចខ្មែរទេ តែលោកតាឲ្យខ្ញុំសម្លាប់លោកតាដោយលោកតាទុកចុតហ្មាយឲ្យខ្ញុំកាន់បែបនេះ ខ្ញុំត្រេកអរណាស់" ។

នាយយ៉ក្សសួរថែមទៀតថា "ចុះលោកតាឲ្យខ្ញុំសម្លាប់បែបណា ?" ។ លោកតេជោក្រហមកធ្លើយថា "នែ! អាយ៉ក្ស, ឯងដឹងអញស្រាប់ហើយ, ខ្លួនអញគេកាប់មិនមុត បាញ់មិនចេញទេ ចូរឯងដុតអញចុះ ឯងធ្វើឥឡូវនេះទៅ" ។ នាងប្រពន្ធចុងមកឃាត់សុំទោសតែយ៉ាងណាក៏ពុំស្តាប់ សុខចិត្តតែពីស្លាប់ ។

លុះគេខុសបានច្រើនមកគរជាគំនរហើយ លោកតេជោឡើងទៅអង្គុយលើគំនរខុសនោះ ទើបនាយយ៉ក្សដាក់ភ្លើងដុត ឆេះសុសលោកតេជោក្រហមក នៅពេលនោះទៅ ។

ព្រះរាជាទ្រង់ជ្រាបថា លោកតេជោក្រហមក ត្រូវបាវព្ទង់ឈ្មោះ យ៉តផុតសម្លាប់ដូច្នោះ ក៏ត្រាស់បង្គាប់ឲ្យចាប់ខ្លួននាយយ៉តទៅធ្វើទោស ៗ ឈ្មោះនោះបានថ្វាយសំបុត្របុះកិច្ចសន្យានោះសុំកុំឲ្យធ្វើទោសខ្លួន ទ្រង់ជ្រាបសព្វសេចក្ដីហើយ ក៏ទ្រង់តាំងនាយយ៉តឲ្យធ្វើជាតេជោ ជំនួសលោកតេជោក្រហមក ដ្បិតនាយយ៉តពិតមែនជាជាតិព្ទង់ តែចូលមកនៅស្រុកខ្មែរយូរណាស់ហើយ ដោយគេចាប់មកលក់តាំងពីតូច ដល់ធំឡើង បានរៀនសិល្បសាស្ត្រពីលោកតេជោក្រហមក បានទៅធ្វើចម្បាំងជាមួយគ្នាជាច្រើនលើក បានជាព្រះករុណាទ្រង់សព្វព្រះរាជហឫទ័យតាំងឲ្យនាយយ៉តធ្វើជាតេជោឡើង ។

នាយយ៉តក៏បានឡើងជាតេជោ ។ នៅពេលដម្បូង មានមន្ត្រីកងខេត្តជាច្រើន ពុំស្ដាប់បង្គាប់គាត់ដោយអនទ់ចិត្តថា នាយយ៉តជាតិព្ទង់ហើយគ្មានចេះសិល្បសាស្ត្រអ្វីផង, នាយយ៉តក៏ចាប់កាប់សម្លាប់ចោលអស់ទៅ ។

ដើម្បីឲ្យអ្នកផងអស់សង្ស័យ តេជោយ៉តឲ្យយកក្ដារស្ពានចាស់ដែលអ្នកផងធ្លាប់ដើរជាន់គ្រប់គ្នាមកឲ្យជាងឆ្លាក់ធ្វើជាព្រះពុទ្ធរូបតូច ១ ព្រះអង្គ ហើយធ្វើបុណ្យអភិសេកឡើង ។ នៅពេលដែលអ្នកផងមកជួបជុំធ្វើបុណ្យនោះហើយ តេជោយ៉ត សួរទីប្រជុំថា " ព្រះពុទ្ធរូបនេះពីដើមជាអ្វី ? " ។ ទីប្រជុំឆ្លើយថា " ពីដើមជាក្ដារស្ពាន " ។ តេជោយ៉តថា " កាល

ទៅជាគារស្ពានគេដើរជាន់ ឥឡូវជាព្រះពុទ្ធរូបគេថ្វាយបង្គំ ដូចខ្លួនយើង ពីដើមជាបាវលោកតេជោក្រហមក គ្មានរណាគោរពយើងទេ ឥឡូវនេះ យើងជាតេជោត្រួតខែត្រនេះហើយ អ្នកទាំងអស់គ្នាត្រូវតែកោតខ្លាចយើង គោរពយើង មើលងាយយើងពុំបានជាដាច់ខាត បើមើលងាយយើង ។ នឹងសម្លាប់ឥតត្រាប្រណី ,, ។

តាំងពីនោះមក លោកតេជោយ៉តធ្វើការត្រួតត្រាខែត្របានយ៉ាង ស្រួល ឥតមានខ្មាំងសត្រូវមកលុកលុយឡើយ រហូតដល់លោកអស់ អាយុសង្ខារទៅ ។

រូបដំណាងលោកតេជោយ៉ត ក៏មានធ្វើទុកក្នុងវត្តកំពង់ធំសព្វថ្ងៃនេះ ដែរ តែឥតពូកែដូចរូបលោកតេជោក្រហមកដែលហៅថា អ្នកតាក្រហមក ទេ ។ មកដល់សព្វថ្ងៃនេះ ពួកនាហ៊ានទាំងធំទាំងតូច គ្មានលោកណា មួយហ៊ានចូលវិហារវត្តកំពង់ធំពីទ្វារមុខទេ ហ៊ានចូលតែតាមទ្វារក្រោយ ដោយខ្លាចអំណាចអ្នកតាក្រហមក ។

ចំណែកលោកតេជោ ហ៊ូ ដែលពួកខ្មាំងក៏សម្លាប់នៅក្នុងបន្ទាយនោះ សព្វថ្ងៃនេះ អ្នកជិតខាង ហៅភូមិត្រង់កន្លែងបន្ទាយលោកតេជោហ៊ូនោះ ថាភូមិព្រៃតាហ៊ូ ។ ភូមិព្រៃតាហ៊ូនោះ នៅពីខាងក្រោយវត្តកំពង់ធំ ។

---

## ផ្នែកកំណត់និងប្រវត្តិការណ៍

### ពិធីទទួលសៀវភៅជាអំណោយបណ្ឌិតសភា ពុទ្ធសាសនសិក្សាចិនប្រជាមានិត ដល់ពុទ្ធិក-មហាវិទ្យាល័យ ព្រះសីហនុរាជ

---

កាលពីថ្ងៃ ៧ ខែមេសា ១៩៦១ នៅពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ មានធ្វើពិធីទទួលសៀវភៅពុទ្ធសាសនាជាភាសាចិន និងភាសាអង់គ្លេស ជាអំណោយរបស់បណ្ឌិតសភាពុទ្ធសាសនសិក្សា នៃប្រទេសចិនប្រជាមានិត ។

ម៉ោង ៨, ៣០ នៃថ្ងៃនោះ, ឥស្សរសមណៈ និងឥស្សរជនជាច្រើន បាននិមន្តបានអញ្ជើញមកជួបជុំគឺ :

ផ្នែកព្រះសង្ឃជាអាទិ៍គឺ: ព្រះទេពសត្ថាថាង - អ៊ុត តំណាងសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ, សម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយ, ព្រះពោធិវង្សហួត-តាត អគ្គាធិការពុទ្ធិកសិក្សា, ព្រះមហាព្រហ្មមុនី ទេព - អ៊ូ ចាងហ្វាងវងនៃពុទ្ធិកវិទ្យាល័យ ព្រះសុភម្រឹត ព្រមទាំងព្រះថេរានុត្ថេរៈពជាគណៈឋានានុក្រម និងព្រះសង្ឃសាស្ត្រាចារ្យជាច្រើនអង្គទៀត ។

ផ្នែកគ្រហស្ថគឺ: សហាជីវិន ស៊ិន ប៊ុយកា រដ្ឋលេខាធិការក្រសួងធម្មការ, លោក កួង-សន នាយកការិយាល័យ, លោក លឹម - ងួនសេង

នាយខុទ្ទកាល័យ, ព្រះអគ្គម្ចាស់ស៊ីសុវត្ថិ-សាក់រ៉េត នាយការិយាល័យបុគ្គលិក, លោក ព៉យ-ប៊ុក នាយការិយាល័យសាសនសិក្សាធិការ នៃក្រសួងធម្មការ, លោក តៃ-ម៉េង-ហាប់ អគ្គលេខាធិការ នៃពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ, លោក ថាច់-សេរ៉ាញ ទីប្រឹក្សាបច្ចេកទេស ព្រមទាំងបុគ្គលិកក្រសួងធម្មការ-ពុទ្ធសាសនបណ្ឌិត្យ-ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ជាច្រើនទៀតបាននិមន្ត បានអញ្ជើញមកជាកិត្តិយស ក្នុងពិធីនេះ ។

ម៉ោង ៩, ឯកឧត្តម រ៉េង-យូតឹង ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋចិនប្រជាមានិត ប្រចាំប្រទេសកម្ពុជា ជាតំណាងនៃបណ្ឌិតសភាពុទ្ធសាសនសិក្សាចិន ដោយមានសហការីរបស់លោក ៤ នាក់ជូនដំណើរផង បានអញ្ជើញមកដល់ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ដោយនាំយកមកនូវសៀវភៅ សរមោធាឧធម្មបវត្តន៍ ជាភាសាចិន ៤៨ ក្បាល, ជាភាសាអង់គ្លេស ១ ក្បាល ដែលសុទ្ធតែជាសៀវភៅនិយាយអំពីព្រះពុទ្ធសាសនា មកជូនទុកជារតនសម្បត្តិរបស់ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ។

ក្រោយពីការ ធ្វើគារវកិច្ចចំពោះព្រះសង្ឃ ទឹងឥស្សរជនទាំងឡាយរួចហើយ ឯកឧត្តម រ៉េង-យូតឹង បានថ្លែងនូវសុន្ទរកថាជាភាសាចិន ដោយមានអ្នកបកប្រែជាភាសាខ្មែរដូចតទៅនេះ ៖

## សុន្ទរកថា

### នៃ ឯកឧត្តម ភីង-យូពឹង

សូមនមស្ការ សម្ដេចព្រះសង្ឃនាយកទាំង ២ គណៈ !

សូមនមស្ការ ព្រះថេរានុត្ថេរៈ !

ឯកឧត្តម-អស់លោក !

ខ្ញុំព្រះករុណា-ខ្ញុំបាទ ពោរពេញដោយក្ដីសំណាង នឹងកិត្តិយសដ៏ជ្រាលជ្រៅក្រៃលែង ដែលមានតំណាងបណ្ឌិតសភា ពុទ្ធសាសនសិក្សានៃប្រទេសចិនមកផ្ទេរជូនដល់ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ នូវ សមោធានធម្មបរិវត្ត ដែលជាស្នាព្រះហស្តនៃព្រះតេជព្រះគុណ ហ៊ាន់ចាន់ ។ ព្រមជាមួយនេះ ខ្ញុំព្រះករុណា-ខ្ញុំបាទក៏សូមសំដែងនូវសេចក្ដីអំណរគុណ ប្រគេននឹងជូនដល់ព្រះអង្គ ឯកឧត្តម នឹងអស់លោក ដែលបានប្រទាននឹងផ្ដល់នូវព្រះទ័យ នឹងទឹកចិត្តរាប់អានចំពោះខ្លួនខ្ញុំព្រះករុណា-ខ្ញុំបាទ ។

តាំងពី ១ ពាន់ឆ្នាំមកហើយម៉្លេះ គឺតាំងពីពេលដែលប្រជាជននៃប្រទេសយើងទាំងពីរ បានចាប់ផ្ដើមឡើងនូវការរាប់រកគ្នាជាប្រពៃណីមក, ការប្រាស្រ័យទាក់ទងគ្នាខាងផ្លូវវប្បធម៌ពុទ្ធសាសនារវាងប្រទេសយើងទាំង ២ ក៏បានប្រព្រឹត្តទៅនូវដំណើរយ៉ាងរួសរាន់, ហើយក្នុងរយៈកាលដ៏យូរអង្វែងនោះ ប្រជាជននៃប្រទេសយើងទាំង ២ បានសុខដុម

ជាមួយនឹងគ្នា, ពុទ្ធសាសនិកជននៃប្រទេសយើងទាំង ២ បានខំព្យាយាមតស៊ូ នឹងពុះពារទូវគ្រប់ឧបសគ្គ បានលុកលុយនូវសមុទ្រសាគរ នឹងកាត់កាលធ្លងព្រៃ បំពេញនូវការចងស្ពានមេត្រីនឹងគ្នា ព្រមទាំងបកប្រែនូវធម្មវិន័យដែលជាសារប្រយោជន៍ ដល់ព្រះពុទ្ធសាសនសិក្សា ។ ព្រឹត្តិការណ៍ទាំងនេះបានចងក្រងរៀបរៀងដោយយ៉ាងច្បាស់លាស់ នឹងមានឧទាហរណ៍ដ៏រស់រវើកនៅក្នុងឯកសារប្រវត្តិសាស្ត្ររបស់ចិន ដូចជានៅដើមសតវត្សរ៍ទី ៦ នៃគ្រឹស្តសករាជ មានព្រះភិក្ខុសង្ឃនៃប្រទេសហ្វូណន ២ ព្រះអង្គ គឺព្រះនាមសង្ឃបាលៈ ១ នឹងព្រះនាមមន្ទសេនៈ ១ ព្រះអង្គបាននិមន្តទៅកាន់ក្រុងណាន់កាំងនៃប្រទេសចិន បានបំពេញនូវការប្រែធម្មវិន័យអស់រយៈពេល ១៧ ឆ្នាំ ; ព្រះត្រៃបិដកដែលប្រែសម្រាយជាភាសាចិន ហើយសព្វថ្ងៃបានតំកល់ទុកជាកេនសម្បត្តិ នៅឯប្រទេសចិននោះ គឺជាស្នាព្រះហស្ត នៃព្រះភិក្ខុសង្ឃទាំង ២ អង្គនេះ ; ក្រៅពីនេះនៅមានព្រះសង្ឃខ្មែរ ១ ព្រះអង្គទៀត ព្រះនាមសុពោធិ ក៏ព្រះអង្គបានបំពេញនូវការប្រែធម្មវិន័យខាងផ្លូវមហាយានជាច្រើនក្បាល ក្នុងកាលដែលព្រះអង្គនិមន្តទៅស្នាក់នៅក្នុងវត្តដ៏កេរ៍ ស្រុកអាំជីវ នៃរជ្ជកាលឈឺន ។ ជិត ១ សតវត្សរ៍មកនេះ ដោយប្រទេសយើងទាំង ២ បានជួបប្រទះនូវសេចក្តីអកុសល , មិត្តភាពនៃប្រទេសយើងទាំង ២ ក៏បានត្រូវទទួលការរាំងរា, ឥតការស្រាវជ្រាវទាក់ទងគ្នាខាងវប្បធម៌ពុទ្ធសាសនា

និងការចងស្ពានមេត្រីនឹងគ្នា រវាងពុទ្ធសាសនិកជននៃប្រទេសយើងទាំង២ ក៏ពុំអាចនឹងរួចខ្លួនផុតពីគ្រោះថ្នាក់នេះដែរ ។ តែគួរជាទីរីករាយពេកណាស់ ចំពោះយើងទាំងអស់គ្នា ដោយយើងទាំងអស់គ្នា បានឈានដំណើរមកកាន់សម័យ ម៉ៅ-សេទុង និងសីហនុពជ ។ គឺសម័យហ្នឹងហើយដែលធានាអះអាងដល់ការស្ដាបនាឡើងវិញ និងពង្រីកឲ្យទូលាយឡើងទៅទៀត នូវសម្ពន្ធមេត្រីរវាងប្រទេសយើងទាំង ២ ។ សម័យហ្នឹងដែរ ដែលបានសម្រេចជាសមិទ្ធិយ៉ាងប្រសើរ ដល់ការប្រាស្រ័យទាក់ទងគ្នា រវាងពុទ្ធសាសនិកជននៃប្រទេសយើងទាំង ២ ។ ក្នុងករណីយ៍ដែលនេះ, ខ្ញុំព្រះករុណា-ខ្ញុំបាទ ក៏ពុំអាចនឹងបំភ្លេចបានឡើយ នូវដំណើរទស្សនាការមកកាន់ប្រទេសកម្ពុជាកាលពីឆ្នាំ ១៩៥៧ នៃគណៈប្រតិភូពុទ្ធសាសនាចិន និងទស្សនកិច្ចនៃគណៈប្រតិភូពុទ្ធសាសនាខ្មែរ ដែលមានព្រះពោធិវង្ស ហួត-តាត ជាប្រធាន ដែលបានទៅកាន់ប្រទេសចិន កាលពីឆ្នាំ ១៩៥៨ ។ គឺជាកិច្ចទស្សនាទាំងនេះហើយ ដែលបានផ្តល់ជាគាតមានមួយយ៉ាងប្រសើរ ដល់ការចងស្ពានមេត្រីរវាងប្រជាពលរដ្ឋ និងពុទ្ធសាសនិកជននៃប្រទេសយើងទាំង ២ ។

សម្តេចសង្ឃជាទីគោរព ! ព្រះថេរានុត្ថេរៈទាំងឡាយ !

ឯកឧត្តម ! អស់លោក !

ឥឡូវនេះ ខ្ញុំព្រះករុណា-ខ្ញុំបាទ សូមតាងនាមនៃបណ្ឌិតសភាពុទ្ធ-

សាសនសិក្សាចិន សូមចាប់ផ្ដើមនូវការជូនសៀវភៅធម៌ ដែលជាគេន-សម្បត្តិយ៉ាងថ្លៃថ្លា ខាងវប្បធម៌អតីតកាលនៃប្រទេសចិន ចំពោះពុទ្ធិក-មហាវិទ្យាល័យ ព្រះសីហនុរាជ ៗ ខ្ញុំព្រះករុណា-ខ្ញុំបាទ ជឿជាក់ថា: ការជូននូវសៀវភៅធម៌នេះ ជាសក្ខីភាពសបញ្ជាក់នូវមនោមិត្តភាពជាតិយេក្រា-ភាពនៃប្រជាជននឹងពុទ្ធសាសនិកជនចិន ចំពោះប្រជាជននឹងពុទ្ធសាស-និកជនខ្មែរ ៗ

ជាអវសានកថា ខ្ញុំព្រះករុណា-ខ្ញុំបាទ សូមប្រសិទ្ធិនូវស័ព្ទសាធុការពរសូមឲ្យ:

- ការប្រាស្រ័យទាក់ទងគ្នា ខាងផ្លូវវប្បធម៌រវាងប្រទេសយើងទាំង ២ បានចំរើនជាមិនដាច់តទៅទៀត ៗ

- សូមឲ្យមិត្តភាពរវាងពុទ្ធសាសនិកជនចិន នឹងកម្ពុជាប្រកបដោយយុវភាពអស់កាលជាយូរអង្វែងត ទៅ ៗ

- សូមជ័យមង្គល នឹងសេចក្ដីចំរើនគ្រប់ប្រការបូលមានដល់សម-ណសិស្ស នៃពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ៗ

លុះចប់សុន្ទរកថារបស់ឯកឧត្ដម ពាង-យូពីង ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋចិនប្រជាមានិត ប្រចាំប្រទេសកម្ពុជា នឹងជាតំណាងនៃបណ្ឌិតសភាពុទ្ធសាសនសិក្សាចិនហើយ សហជីវិនសុន-ប៊ុយកោ រដ្ឋលេខាធិការក្រសួងធម្មការ នឹងសាសនសិក្សាធិការ បានថ្លែងនូវសុន្ទរកថា

មួយ ដែលមានអ្នកបកប្រែម្នាក់ប្រជាកាសាចិនដូចតទៅនេះ ៖

សុន្ទរកថា

នៃសហជីវិន ស៊ុន-ប៊ុយកោ

សូមនមស្ការ សម្ដេចទាំងពីរព្រះអង្គ !

សូមនមស្ការ ព្រះថេរានុត្ថេរៈ ទាំងឡាយ !

សូមជំរាប ឯកឧត្តម - លោកអ្នកទាំងឡាយ !

ក្នុងនាមនៃក្រសួងធម្មការ និងសាសនសិក្សាធិការ និងក្នុងនាមខ្ញុំព្រះករុណា-ខ្ញុំ, ខ្ញុំព្រះករុណា ខ្ញុំ សូមថ្លែងនូវសោមនស្សយ៉ាងខ្លាំងខ្លស់ចំពោះសម្ដេចទាំងពីរព្រះអង្គ - ព្រះថេរានុត្ថេរៈ - ឯឧត្តម ព្រមទាំងអស់លោកទាំងឡាយ ដែលបាននិមន្ត-អញ្ជើញមកជាកិត្តិយសដ៏ប្រសើរ ក្នុងឱកាសពិធីទទួលសៀវភៅជាអំណោយនៃបណ្ឌិតសភាចិនចំពោះបណ្ណា-ល័យពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជនេះ ។

ខ្ញុំព្រះករុណា - ខ្ញុំ សូមអនុញ្ញាតពីសំណាក់សម្ដេច ព្រះថេរានុត្ថេរៈទាំងឡាយ ឯកឧត្តម និងអស់លោក ដើម្បីថ្លែងនូវមនោសញ្ចេតនាយ៉ាងស្មោះស្ម័គ្រ ព្រមទាំងកតញ្ញុតាធម៌យ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម ឯក-អគ្គរដ្ឋទូតប្រទេសចិនប្រជាមានិត ប្រចាំប្រទេសកម្ពុជា ដែលបានអញ្ជើញមកប្រគល់សៀវភៅ ដល់បណ្ណាល័យនៃពុទ្ធិកមហាវិទ្យាល័យ ព្រះ-សីហនុរាជយើង ក្នុងពេលនេះ ។

ឯកឧត្តម -

ខ្ញុំមានបសន្នចិត្តជាយ៉ាងពន់ពេក ដោយខ្ញុំបានទទួលភារៈ ធ្វើជាអធិបតីក្នុងការទទួលសៀវភៅដែលជាអំណោយបណ្ឌិតសភាចិន ហើយដែលឯកឧត្តមបាននាំមកដំកល់ទុកនៅចំពោះមុខយើងខ្ញុំនេះ ដើម្បីជារតន-សម្បត្តិនៃបណ្ណាល័យ សម្រាប់ឲ្យសិស្សទាំងឡាយសិក្សាតទៅអនាគត ។

សៀវភៅនេះ ទុកជាឯកសារដ៏វិសេសវិសាល ដែលឯកឧត្តមនឹងបណ្ឌិតសភាចិន បានផ្តល់ដល់ពុទ្ធិកមហាវិទ្យាល័យ ។ ឯកសារទាំងនេះអាចផ្សាយនូវវិជ្ជាទាំងឡាយចំពោះនិស្សិតគ្រប់ ៗ គ្នា ដែលត្រូវការបំពេញវិជ្ជាបានបរិបូណ៌តទៅអនាគត នឹងជួយឧបត្ថម្ភបណ្ណាល័យឲ្យមានវឌ្ឍនភាព នឹងសម្បូរណភាព ។ កុសលចិត្តដ៏ប្រពៃដែលទុកជាស្រែបុណ្យសម្រាប់បណ្តុះនូវពូជដ៏ល្អគឺវិជ្ជានេះឯង នាំឲ្យខ្ញុំព្រះករុណា -ខ្ញុំនឹកឃើញដល់សុភាសិត ១ កន្លែងដែលលោកសុត្តន្តប្រើជា ៩ក្ខុ បានបង់ក្រងជាពាក្យកាព្យក្នុងសៀវភៅ លោកនីតិបករណ៍ : ថា:

មានទ្រព្យមិនស្មើមានវិជ្ជា វិជ្ជាចោរលួចយកមិនបាន

វិជ្ជាទុកជាមិត្តកាល្យាណ សន្តានជួយពឹងពុំនឹងអើយ ៗ

ម្យ៉ាងវិញទៀត ខ្ញុំព្រះករុណា-ខ្ញុំ សូមសម្តេច-ឯកឧត្តម-លោកអ្នកមេត្តាអនុញ្ញាតឲ្យខ្ញុំជំរាបបន្តិច អំពីប្រវត្តិដោយសង្ខេបនៃពុទ្ធិកមហាវិទ្យា-ល័យព្រះសីហនុរាជនេះ ។

ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជនេះ បានកើតឡើងក្នុងឆ្នាំ ១៩៥៥ សព្វថ្ងៃឋិតនៅក្នុងការឧបត្ថម្ភនៃរាជរដ្ឋាភិបាល ។ គោលបំណងនៃពុទ្ធិកមហាវិទ្យាល័យនេះ គឺដើម្បីពង្រីកពុទ្ធិកសិក្សាដែលមានឋានៈពុំទាន់សមល្មមនៅឡើយ ។ ការពង្រីកនេះ សូមជ្រាបថាពុំមែនចំពោះតែពុទ្ធិកសិក្សាទេ គឺពង្រីកទាំងការសិក្សាខាងវិជ្ជាផ្លូវលោក នឹងភាសាជាន់បុរាណផងៗ សព្វថ្ងៃនៅក្នុងមហាវិទ្យាល័យនេះ មានការបង្រៀនភាសាបាលី-សំស្រ្កឹត អង់គ្លេស—បារាំង នឹងវិជ្ជាទំនើបផ្សេង ៗ ទៀត ដោយមធ្យ័ត ។ នៅឆ្នាំក្រោយប្រហែលជានឹងមានបង្រៀនភាសាហិណ្ឌីដែលជាភាសាសម្រាប់រដ្ឋឥណ្ឌាទៀត ។ មហាវិទ្យាល័យនេះ មានសាស្រ្តាចារ្យយ៉ាងចំណានៗ ខាងភាសាដូចពោលមកខាងលើនេះ ។

ក្នុងរយៈកាលដ៏ខ្លីតែប៉ុណ្ណេះ ឃើញថាវឌ្ឍនភាពនៃមហាវិទ្យាល័យនេះ បេះតែជឿនលឿនទៅមុខជាដរាប ហើយនឹងមានសេចក្តីសង្ឃឹមយ៉ាងមាំថា តទៅអនាគតនឹងរីករឹតតែចម្រុងចម្រើនជាកិយោភាពជាងនេះទៅទៀត នៅក្រោមការដឹកនាំនៃព្រះតេជព្រះគុណ ព្រះពោធិវង្ស អគ្គាធិការពុទ្ធិកសិក្សា ក្នុងព្រះរាជអាណាចក្រកម្ពុជា ។

ឯកឧត្តម !

សៀវភៅទាំងនេះ ជាអំណោយមួយដ៏ប្រសើរបំផុតមានប្រយោជន៍ច្រើនពេកណាស់ ព្រោះជាសៀវភៅដែលពុទ្ធិកមហាវិទ្យាល័យកំពុងតែ

ត្រូវការ ៗ ជនជាតិចិនតែងតែមានសទ្ធាបរិច្ចាគធនធានធ្វើបុណ្យទានដូចពុទ្ធសាសនិកជនខ្មែរយើងដែរ ៗ ប្រជាជនខ្មែរពុំដែលភ្លេចដល់ម្តងសោះឡើយថា មហាប្រទេសចិន ជាប្រទេសដែលមានការប្រាស្រ័យទាក់ទងនឹងប្រទេសកម្ពុជាតាំងពីបុរាណកាលមក ៗ ដោយអាស្រ័យហេតុនេះ កម្ពុជាទុកប្រទេសចិនដូចជាបងប្អូនរួមសាច់ឈាមជាមួយគ្នា ៗ ម្យ៉ាងទៀត ក្នុងសម័យនេះ ប្រទេសចិនជាមិត្តដ៏ឧត្តមរបស់ប្រទេសកម្ពុជា ៗ

នៅទីបំផុតនេះ ក្នុងនាមនៃរដ្ឋាភិបាលខ្មែរ នឹងក្នុងនាមនៃព្រះសង្ឃទាំងអស់ ដែលមានសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ ជាមគ្គទេសក៍ ព្រមទាំងក្នុងនាមផ្ទាល់របស់ខ្ញុំ ខ្ញុំសូមថ្លែងម្តងទៀតនូវសេចក្តីត្រេកអរជាភិយ្យោភាពចំពោះអំណោយដ៏ថ្លៃថ្លានេះ ៗ សូមឯកឧត្តមមេត្តាទទួលនូវឥដ្ឋមនុញ្ញផលដ៏ខ្ពង់ខ្ពស់ នឹងសមានចិត្តដ៏ជ្រាលជ្រៅអំពីខ្ញុំ ដើម្បីនឹងរឹតចំណងមិត្តភាពរវាងប្រទេសទាំងពីរ ដែលមានគោលបំណងតែមួយដូចគ្នា គឺសន្តិភាពឲ្យបានរឹងរឹតតែជិតស្និទ្ធ ជាស្ថានពរតរៀងទៅ ៗ

លុះចប់សុន្ទរកថានេះហើយ ព្រះសង្ឃក៏បានជយន្តោប្រសិទ្ធិពរជ័យជូនចំពោះវរជនទាំងពីរផ្នែក នឹងជាកិច្ចបញ្ចប់ពិធីប្រគល់សៀវភៅនេះ ៗ

---

តពីនោះ ព្រះបិតាជាតិទ្រង់ប្រគេនសញ្ញាប័ត្រតាំងព្រះតេជព្រះគុណ ធេរ្ហា·ឈាក់ (សុជម្មត្ថេរ) ឲ្យឡើងកាន់ឋានៈ ជាព្រះមង្គលទេព្យ-លោករង្សី មេគណខេត្តតាកែវ ជាជំនួសព្រះសពគតទៅ ។

បន្ទាប់មក សម្តេចព្រះបិតាជាតិ ទ្រង់ប្រគេនទេយ្យទានចំពោះ សម្តេចព្រះសង្ឃនាយក ព្រមទាំងបវារណាបច្ច័យ ចូលក្នុងពិធីបុណ្យ ៩០០០៛ នឹងប្រគេនលោកគ្រូចៅអធិការ ៩០០០៛ សម្រាប់ចាត់ចែង តាមត្រូវការក្នុងវត្ត ។